# អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព



# បទពិសោធន៍រៀនសូត្រស្តីអំពី ការចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិច

## ភូមិភាគឦសាន នៅភូមិឡាអិន ខេត្តរតនគីរី

# អារម្ភកថា

កម្មវិធីអភិវឌ្ឍន៍សហគមន៍ចម្រុះខេត្តរតនគិរី គឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីអភិវឌ្ឍន៍សហគមន៍ចម្រុះនៅក្នុងខេត្តចំនួនបួនរបស់អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (**ឌីភីអេ**) ដែលបានចាប់ផ្តើមអនុវត្តគំរោងរបស់ខ្លួនតាំងពី ឆ្នាំ១៩៩៤។

កម្មវិធីនេះធ្វើការងារសំខាន់ដោយផ្តោតទៅលើការគ្រប់គ្រងធនធានធម្មជាតិ និងសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិចដោយរួមបញ្ចូលទាំងការរៀបចំសហគមន៍ព្រៃឈើ និងការចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិច។ តាមរយៈកិច្ចប្រឹងប្រែងក្នុងការអនុវត្តការងារឱ្យបានជោគជ័យ ជាលទ្ធផលយើងឃើញថាសហគមន៍ជនជាតិដើមភាគតិចទំពួន នៅភូមិឡាអិន ខេត្តរតនគិរីបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីសមូហភាពស្របច្បាប់ ដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ តាមរយៈការទទួលបាននេះ ជនជាតិដើមភាគតិចទំពួននៅភូមិឡាអិន នឹងមានសិទ្ធិស្របច្បាប់ក្នុងការថែរក្សាធនធានដីធ្លី និងព្រៃឈើជៀសវាងនូវការរំលោភបំពាន និងការទន្ទ្រានកាន់កាប់ដីដោយខុសច្បាប់។

លើសពីនេះ សមិទ្ធិផលនេះមិនអាចសំរេចទៅបានឡើយ ប្រសិនបើគ្មានការជួយជ្រោមជ្រែងពីសំណាក់ម្ចាស់មូលនិធិ ការគាំទ្រ និងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយបណ្តាមន្ទីរ ក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ជាពិសេស គឺការចូលរួមរបស់សហគមន៍ជនជាតិដើមភាគតិចទំពួននៅភូមិឡាអិន និងកិច្ចប្រឹងប្រែងរបស់បុគ្គលិកអង្គការ **ឌីភីអេ** ទាំងអស់គ្នា។

ទន្ទឹមនឹងនេះ អង្គការ **ឌីភីអេ** បានទទួលមូលនិធិពីអង្គការ **ត្រូកៃ** (Trocaire) សំរាប់ចងក្រងនូវបទពិសោធន៍ រៀនសូត្រស្តីអំពីដំណើរការនៃការចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិចនៅភូមិឡាអិន ខេត្តរតនគិរី។ ការចងក្រងបទពិសោធន៍រៀនសូត្រនេះធ្វើឡើង គឺមានគោលបំណងលើកកំពស់ចំណេះដឹង និងចែករំលែកបទពិសោធន៍ដល់សហគមន៍ជនជាតិដើមភាគតិច ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ ដែលមានបំណងស្នើសុំចុះបញ្ជីដីសមូហភាពឱ្យយល់ដឹងអំពី ដំណើរការនៃការចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិច ការរៀបចំឯកសារ ការទំនាក់ទំនងជាមួយនឹងស្ថាប័នជំនាញ ការប្រឈមផ្សេងៗ ដែលសហគមន៍ជួបប្រទះនៅក្នុងដំណើរការនេះ និងដំណោះស្រាយទាំងឡាយក្នុងការឆ្លើយតបទៅនឹងបញ្ហា និងការប្រឈមទាំងនោះ។

ដូច្នេះ ឯកសារនេះអាចជាឯកសារជំនួយស្មារតីសំរាប់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធស្វែងយល់អំពីដំណើរការនៃការចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា។

**ភ្នំពេញ, ខែវិច្ឆិកា ឆ្នាំ២០១២**

**អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (ឌីភីអេ)**

# សេចក្តីថ្លែងអំណរគុណ

ការចងក្រងបទពិសោធន៍រៀនសូត្រនេះ គឺជាសមិទ្ធិផលមួយដែលផ្តើមចេញពីការប្តេជ្ញាចិត្ត ការលះបង់ពេលវេលា និងការរួមវិភាគទានទាំងកំលាំងកាយ និងចិត្តពីសំណាក់មនុស្សជាច្រើន។ អង្គការ **អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (ឌីភីអេ)** ដើម្បីឆ្លើយតបទៅនឹងកិច្ចប្រឹងប្រែងនេះ សូមសម្តែងការដឹងគុណ និងកោតសរសើរចំពោះអស់លោក និងលោកស្រីគ្រប់រូបដែលបានចូលរួមចំណែកនៅក្នុងការចងក្រងឯកសារនេះ។

យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសចំពោះសមាជិកសហគមន៍ជនជាតិដើមភាគតិចទំពួននៅភូមិឡាអិន ដែលបានចំណាយពេលវេលាក្នុងការផ្តល់ព័ត៌មាននិងការចូលរួម ដែលទាក់ទងទៅនឹងការចុះបញ្ជីដីធ្លីជាសម្ហូហភាពនៅក្នុងសហគមន៍របស់ពួកគាត់ ទោះបីពួកគាត់ថិតនៅក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយ។

ឆ្លៀតក្នុងឱកាសនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមការងារសម្របសម្រួល និងចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច ស្ថាប័នពាក់ព័ន្ធ ក៏ដូចជារដ្ឋអំណាចមូលដ្ឋាន ដែលបានចែករំលែកនូវគំនិត ទស្សនៈ និងបទពិសោធន៍របស់ខ្លួនពាក់ព័ន្ធនឹងការចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិច។

យើងខ្ញុំក៏សូមសម្តែងនូវការកោតសរសើរ និងថ្លែងអំណរគុណផងដែរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់បុគ្គលិកកម្មវិធីអភិវឌ្ឍន៍សហគមន៍ចម្រុះអង្គការ **ឌីភីអេ_ខេត្តរតនគិរី** ដែលបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្របសម្រួលនៅក្នុងដំណើរការនៃការចុះបញ្ជីដីធ្លីសម្ហូហភាពសំរាប់សហគមន៍ជនជាតិដើមភាគតិចនៅភូមិឡាអិន។

ជាទីបញ្ចប់ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ **ត្រូកែរ (Trocaire)** ដែលបានផ្តល់មូលនិធិក្នុងការគាំទ្រចំពោះការចងក្រងឯកសារនេះឡើង។

# មាតិកាអត្ថបទ


អារម្ភកថា........................................................................១

សេចក្តីថ្លែងអំណរគុណ..........................................................២

មាតិកាអត្ថបទ.....................................................................៣

ជំពូកទី១ : សេចក្តីផ្តើម..........................................................៥

១. សាវតាគំរោង...................................................................៥

២. វិធីសាស្ត្រក្នុងការសិក្សា......................................................៦

ជំពូកទី២ : ក្របខ័ណ្ឌច្បាប់ និងនីតិវិធីសំរាប់ការចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិច.........៧

២.១. ច្បាប់ និងគោលនយោបាយពាក់ព័ន្ធ.......................................៧

២.១.១. ច្បាប់ភូមិបាល (ឆ្នាំ២០០១)...............................................៧

២.១.២. គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍជនជាតិដើម...................៧

២.១.៣. អនុក្រឹត្យស្តីពី នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច.........................៨

២.១.៤. វិធានការការពារបណ្តោះអាសន្ន..........................................៩

២.២. ដំណើរការចុះបញ្ជីដីសាកល្បង..............................................១០

ជំពូកទី៣ : បទពិសោធន៍រៀនសូត្រក្នុងការចុះបញ្ជីនៅភូមិឡាអិន ខេត្តរតនគីរី..........................១២

១. ភាពជោគជ័យរបស់គំរោង....................................................១២

២. បញ្ហាប្រឈម....................................................................២៤

២.១. ការប្រឈមរបស់សហគមន៍ជនជាតិ...........................................២៤

២.២. ការប្រឈមរបស់ក្រុមការងារសំរបសំរួលក្នុងការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច ខេត្តរតនគីរី......២៩

២.៣. ការប្រឈមរបស់អង្គការ ឌីភីអេ ជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូផ្សេងទៀត........................៣០

៣. ដំណោះស្រាយចំពោះការប្រឈមកន្លងមក....................................៣១

សេចក្តីសន្និដ្ឋាន..................................................................៣២

អនុសាសន៍.........................................................................៣៣

ឯកសារយោង.......................................................................៣៥

ឧបសម្ព័ន្ធ..........................................................................៣៦

ឧបសម្ព័ន្ធទី១.....................................................................................៣៧
ឧបសម្ព័ន្ធទី២.....................................................................................៤២
ឧបសម្ព័ន្ធទី៣.....................................................................................៤៩
ឧបសម្ព័ន្ធទី៤.....................................................................................៥៧

# ជំពូកទី១ ៖ សេចក្តីផ្តើម

## ១. សាវតាគំរោង

គំរោងសាកល្បងចុះបញ្ជីដីធ្លីសម្រាប់សហគមន៍ជនជាតិដើមភាគតិច គឺជាមូលដ្ឋានគ្រឹះមួយក្នុងការកំណត់ដំណោះស្រាយជម្លោះដីធ្លីដែលបានកើតឡើង។ បើប្រជាជនដែលជាជនជាតិដើមភាគតិចទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីរួចហើយ នោះបញ្ហាចំរូងចំរាសនៃការលក់ដូរដីខុសច្បាប់ (ជាពិសេសការលក់ដូរដែលមានទ្រង់ទ្រាយធំ) ទំនាស់ព្រំប្រទល់ និងលំហូរចូលនៃប្រជាជនពីខាងក្រៅនឹងមានការថយចុះ។ ជាលទ្ធផល ជនជាតិដើមភាគតិចទាំងនោះនឹងអាចរក្សាព្រៃឈើ ទំនៀមទំលាប់ និងធនធានធម្មជាតិ ដែលមាននៅក្នុងសហគមន៍របស់ពួកគេបាន។

អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍នានា បានបង្កើតគំរោងសាកល្បងមួយចាប់ផ្តើមតាំងពីខែធ្នូ ឆ្នាំ២០០៣ លើការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិចនៅក្នុងសហគមន៍ចំនួនបី នៅក្នុងខេត្តរតនគិរី គឺភូមិឡាអឺនក្រែងនិងភូមិឡាអិន និងខេត្តមណ្ឌលគិរី គឺភូមិអណ្តូងក្រឡឹង។ នៅក្នុងចំណោមភូមិគោលដៅចំនួនពីរនៅក្នុងខេត្តរតនគិរី ភូមិឡាអិនគឺស្ថិតនៅក្នុងតំបន់គោលដៅរបស់អង្គការ **ឌីអ៊ីអេ_ខេត្តរតនគិរី**។ ភូមិឡាអិននេះ ស្ថិតនៅក្នុងឃុំតឺន ស្រុកកូនមុំ ខេត្តរតនគិរី ដែលមានផ្ទៃដីសរុបចំនួន ១.២១៨,៥៦ហិចតា និងមានគ្រួសារ ចំនួន ១៤០គ្រួសារ ស្មើនឹង ៦៣៨នាក់ ក្នុងនោះមានស្ត្រី ៣១៧នាក់ ហើយភាគច្រើនជាជនជាតិទំពួន។

ការចុះបញ្ជីដីធ្លីជាសមូហភាពនៅភូមិឡាអិនត្រូវបានចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៣ ហើយរហូតមកដល់ពេលនេះ គឺមានរយៈពេលប្រាំបួនឆ្នាំមកហើយ ដែលអង្គការ **ឌីអ៊ីអេ_ខេត្តរតនគិរី** បានសហការជាមួយនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងមហាផ្ទៃ មន្ទីររៀបចំដែនដីនគរូបនីយកម្មនិងសំណង់ និងសុរិយោដីខេត្តរតនគិរី មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី និងអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ដើម្បីអនុវត្តផែនការចុះបញ្ជីដីធ្លីជាសមូហភាពនេះ។ ជាលទ្ធផល សហគមន៍ជនជាតិដើមភាគតិចទំពួននៅក្នុងភូមិឡាអិនបានទទួលនូវប័ណ្ណកម្មសិទ្ធិ ស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីរបស់ខ្លួននៅចុងខែធ្នូ ឆ្នាំ២០១១។ ការទទួលស្គាល់ជាផ្លូវការនេះ គឺជាសមិទ្ធិផលមួយដ៏ត្រចះត្រចង់ ដែលសហគមន៍ជនជាតិដើមភាគតិចក្នុងភូមិគោលដៅរបស់អង្គការ **ឌីអ៊ីអេ_ខេត្តរតនគិរី** ទទួលបាន។

អាស្រ័យហេតុនេះ ការចងក្រងឯកសារដែលពាក់ព័ន្ធទៅនឹងកិច្ចប្រឹងប្រែងរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងដំណើរការចុះបញ្ជីដីធ្លីនេះ វាពិតជាមានសារៈសំខាន់ណាស់។ តាមរយៈឯកសារមួយនេះ វានឹងបង្ហាញអំពីការរកឃើញសំខាន់ៗ ដែលបានបង្ហាញអំពីជំហាននិងនីតិវិធីនៃការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ការចុះបញ្ជី សហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល

និងការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច ។

ជាចុងក្រោយ ផ្អែកទៅតាមការសិក្សាមួយនេះ វានឹងអាចផ្តល់នូវមេរៀននិងបទពិសោធន៍ល្អៗជាក់ស្តែង ក៏ដូចជា អនុសាសន៍មួយចំនួនសំរាប់ជាការពិចារណា ដើម្បីយកទៅអនុវត្តកម្មវិធីការងារដែលពាក់ព័ន្ធនឹងការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច ។

## ២. វិធីសាស្ត្រនៅក្នុងការសិក្សា

វិធីសាស្ត្រចំរុះត្រូវបានប្រើប្រាស់ក្នុងការប្រមូលទិន្នន័យ វិភាគ និងចងក្រងជាឯកសារ ។ វិធីសាស្ត្រទាំងនោះរួមមាន ការពិនិត្យឡើងវិញនូវទិន្និន័យបឋម ទិន្នន័យមានស្រាប់ផ្សេងទៀតដែលពាក់ព័ន្ធទៅនឹងការចុះបញ្ជីដីធ្លី និងការសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះក្នុងការចងក្រងឯកសារនេះ ។ ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមរយៈ ការជួបប្រជុំជាមួយនឹងអ្នកផ្តល់ព័ត៌មានសំខាន់ៗនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរួមមាន បណ្តាក្រសួង និងមន្ទីរពាក់ព័ន្ធ បុគ្គលិកដែលពាក់ព័ន្ធ និងប្រជាសហគមន៍មួយចំនួននៅក្នុងភូមិឡាអិន ។ ទិន្នន័យដែលប្រមូលបាន ត្រូវបានយកមកវិភាគ និងផ្ទៀងផ្ទាត់ជាមួយអ្នកពាក់ព័ន្ធ រួចចងក្រងជាឯកសារនេះឡើង ។

# ជំពូកទី២ ៖ ក្របខណ្ឌច្បាប់ និងនីតិវិធីសំរាប់ការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច

## ២.១. ច្បាប់ និងគោលនយោបាយពាក់ព័ន្ធ

### ២.១.១. ច្បាប់ភូមិបាល (២០០១)

ការអនុវត្តចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិចនៅក្នុងគំរោងសាកល្បងនេះ ត្រូវបានផ្តួចផ្តើមឡើងដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលចាប់ផ្តើមពីខែធ្នូ ឆ្នាំ២០០៣ ក្រោយពីការចេញច្បាប់ភូមិបាលឆ្នាំ២០០១ ដែលច្បាប់នេះមានគោលបំណងការពារ និងចុះបញ្ជីអចលនទ្រព្យរបស់សហគមន៍ជនជាតិដើមភាគតិច និងអនុក្រឹត្យលេខ ១១៨ អ.ន.ក/ប.ក ចុះឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២៣ នៃច្បាប់ភូមិបាល បានចែងថា "សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះ-រាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដី ដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទំលាប់ នៃការប្រើប្រាស់ដីជាសមូហភាព។"

តាមរយៈដំណើរការនេះ យើងឃើញថា ភាពជានីតិបុគ្គលរបស់សហគមន៍ជនជាតិដើមភាគតិច គឺជាលក្ខខណ្ឌដំបូង ដែលតម្រូវឱ្យមាន ដើម្បីចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច។ ដូច្នេះហើយចាប់តាំងពីខែឧសភា ឆ្នាំ២០០៨ មកក្រសួងមហាផ្ទៃ តាមរយៈនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងការិយាល័យរដ្ឋបាលមូលដ្ឋានខេត្តរបស់ខ្លួន បានចូលរួមនៅក្នុងដំណើរការនៃការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល ដោយអនុវត្តទៅតាមលិខិត លេខ ៤៧៤/១៩៩៤ របស់ ក្រសួងមហាផ្ទៃ។ ទន្ទឹមនឹងនេះ គេជឿជាក់ផងដែរថា អត្តសញ្ញាណរបស់សហគមន៍ជនជាតិដើមភាគតិច គឺជាលក្ខខណ្ឌដំបូង ដែលតម្រូវឱ្យមានមុនពេលធ្វើការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល។

### ២.១.២. គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិច

នៅក្រោយការបោះឆ្នោតជាទូទៅនាឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវ "គណៈកម្មាធិការអន្តរក្រសួងសំរាប់ធ្វើការជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិក្នុងការរៀបចំគំរោងអភិវឌ្ឍន៍ជនជាតិដើមភាគតិច" ដែលមានក្រសួងអភិវឌ្ឍន៍ជនបទជាប្រធាន និងជាភ្នាក់ងារអនុវត្ត និងក្រោយមកទៀត ក៏បានបង្កើតឡើងនូវ "នាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច" ចំណុះអោយក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងគោលបំណងលើកស្ទួយកម្រិតជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច ព្រមទាំងថែរក្សា

វប្បធម៌ ប្រពៃណីល្អ ទំនៀមទំលាប់ និងជំនឿរបស់ពួកគេ។ ក្នុងកិច្ចខិតខំប្រឹងប្រែងអោយសំរេចគោលបំណងខាងលើ និងដើម្បីអោយការអនុវត្តប្រព្រឹត្តទៅមានភាពរលូនស៊ីចង្វាក់គ្នាលើគ្រប់វិស័យនោះ រាជរដ្ឋាភិបាលក៏បានរៀបចំឡើងនូវគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍជនជាតិដើមភាគតិច" នេះ។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិចរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុម័តនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ ដោយក្នុងនោះ បានកំណត់អណត្តិរបស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅក្នុងការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ដោយសហការណ៍ជាមួយនឹងក្រសួងមហាផ្ទៃ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ជនជាតិដើមភាគតិចនេះ មានគោលដៅដូចខាងក្រោម :

- ជនជាតិដើមភាគតិចទាំងអស់ត្រូវមានជីវភាពរស់នៅចាកផុតពីភាពអត់ឃ្លាន និងភាពក្រីក្រធ្ងន់ធ្ងរ។
- ជនជាតិដើមភាគតិចទាំងអស់ ត្រូវបានផ្តល់ការអប់រំយ៉ាងតិចកម្រិតមូលដ្ឋាន៩ឆ្នាំ និងត្រូវបានផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈសមស្របទៅនឹងតំរូវការ និងផ្អែកលើទីតាំងភូមិសាស្ត្ររស់នៅរបស់បងប្អូន។
- សុខភាពរបស់ជនជាតិដើមភាគតិចត្រូវបានថែទាំអោយល្អប្រសើរ។
- វប្បធម៌របស់ជនជាតិដើមភាគតិចត្រូវបានការពារ និងថែរក្សាអោយមានភាពល្អប្រសើរ។

### ២.១.៣. អនុក្រឹត្យស្តីពី នីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច

អនុក្រឹត្យលេខ៨៣ អនក្រ/បក ស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចត្រូវបានអនុម័តនៅខែ មេសា ឆ្នាំ២០០៩ ដោយរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ អនុក្រឹត្យនេះ មានគោលដៅកំណត់គោលការណ៍ នីតិវិធី និងយន្តការសម្រាប់ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព។

គោលបំណងសំខាន់នៃអនុក្រឹត្យនេះ គឺមានគោលបំណងផ្តល់សិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីដល់សហគមន៍ជនជាតិដើមភាគតិច ធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី និងការពារកម្មសិទ្ធិសមូហភាព ដោយរក្សានូវអត្តសញ្ញាណកម្ម វប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីល្អរបស់សហគមន៍ជនជាតិដើមភាគតិច។

ដោយឡែក អនុក្រឹត្យនេះ ក៏បានកំណត់យ៉ាងច្បាស់ពីតួនាទីរបស់អ្នកពាក់ព័ន្ធនៅគ្រប់កំរិតនៅក្នុងដំណើរការនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចដោយរាប់ចាប់ពីសហគមន៍ ក្រុមប្រឹក្សាឃុំ ក្រុមការងារដីរដ្ឋស្រុក ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ស្រុក អភិបាលស្រុក រដ្ឋបាលសុរិយោដី គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត និងអភិបាលខេត្តជាដើម។

### ២.១.៤. វិធានការការពារបណ្តោះអាសន្ន

ដើម្បីប្រសិទ្ធភាពអនុវត្តនូវគោលនយោបាយ ច្បាប់ និងក្របខណ្ឌគតិយុត្តផ្សេងៗនៅក្នុងក្របខណ្ឌទូទាំងប្រទេស ក្រោយពីគម្រោងសាកល្បងស្តីពី ការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច ត្រូវបានបញ្ចប់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ លើជ្រុងនៃកំណែទម្រង់ដីធ្លី បានកំណត់អោយមានការដាក់ចេញនូវវិធានការការពារបណ្តោះអាសន្ន ចំពោះក្បាលដីរបស់សហគមន៍ជនជាតិដើមភាគតិចទាំងឡាយ ដែលបានបង្កើត និងមានការទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ រហូតដល់ការចុះបញ្ជីដីជាកម្មសិទ្ធិសមូហភាពជូនសហគមន៍ត្រូវបានចប់សព្វគ្រប់តាមនីតិវិធី។ លើមូលដ្ឋាននៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្មនេះ និងលិខិតលេខ ៥២៥ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្រ្តីស្តីពីសំណើសុំគោលការណ៍ដាក់ចេញនូវវិធានការការពារបណ្តោះអាសន្ននូវដីរបស់សហគមន៍ រួមទាំងរបាយការណ៍វាយតម្លៃលទ្ធផលនៃការអនុវត្តគម្រោងសិក្សាសាកល្បងការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចរបស់ខេត្តទាំងពីរ **ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តី ក្រសួងមហាផ្ទៃ** និង**ទេសរដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** សម្រេចដាក់ចេញនូវសារាចរនេះ ដើម្បីណែនាំការអនុវត្តដូចតទៅ :

នៅពេលបានទទួលពាក្យស្នើសុំចុះបញ្ជីដីរបស់សហគមន៍ជាកម្មសិទ្ធិសមូហភាព ពីសហគមន៍ជនជាតិដើមភាគតិចណាមួយ អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត នៃខេត្តដែលសហគមន៍ជនជាតិដើមភាគតិចជាសាមីនោះរស់នៅ **ត្រូវរៀបចំសេចក្តីព្រាងដីកាដាក់ជូនក្រុមប្រឹក្សាខេត្ត ពិនិត្យ និងអនុម័តជាបន្ទាន់** ដើម្បីអនុវត្តនូវវិធានការការពារដីដែលស្ថិតក្នុងតំបន់ដីរបស់សហគមន៍ស្នើសុំចុះបញ្ជីដីនោះ ដោយណែនាំដល់ :

១. ប្រជាពលរដ្ឋ អោយផ្អាកជាបណ្តោះអាសន្ននូវការទិញ ការលក់ ការជួល ឬ ការផ្ទេរតាមគ្រប់រូបភាព។

២. អាជ្ញាធរក្រោមឱវាទនៃដែនសមត្ថកិច្ចរបស់ខ្លួន អោយផ្អាកនូវការបញ្ជាក់លើលិខិតយថាភូតនានាទាក់ទងនឹងករណី នៃចរន្តការដី នូវរាល់ក្បាលដីដែលសហគមន៍ស្នើសុំចុះបញ្ជី និងក្បាលដីផ្សេងទៀត ដែលមានព្រំប្រទល់ជាប់ក្បាលដី ដែលសហគមន៍ស្នើសុំចុះបញ្ជី រហូតដល់ក្បាលដីរបស់សហគមន៍ជនជាតិដើមភាគតិចនោះត្រូវបានចុះបញ្ជីដីធ្លីចប់សព្វគ្រប់តាមនីតិវិធី។

ប៉ុន្តែការទប់ស្កាត់ជាបណ្តោះអាសន្នទាំងពីរករណីដូចបានលើកឡើងខាងលើ ត្រូវបានលើកលែងចំពោះក្បាលដីទាំងឡាយ ដែលនៅមុនពេលនៃការដាក់ចេញនូវវិធានការនេះ ជាក្បាលដីរបស់រដ្ឋដែលរាជរដ្ឋាភិបាលមានគោលការណ៍អោយវិនិយោគ ឬ អភិវឌ្ឍន៍ដើម្បីចៀសវាងផលប៉ះពាល់ដល់សិទ្ធិកម្មសិទ្ធិឯកជន និងសាធារណៈលើដីដែលបានកាន់កាប់ និងមានគោលការណ៍ច្បាស់លាស់ ត្រឹមត្រូវតាមច្បាប់ជាធរមានរួចហើយ។

## ២.២. ដំណើរការនៃការចុះបញ្ជីដីសាកល្បង

[១]ដំណើរការនៃការចុះបញ្ជីដីនេះ ត្រូវបានកំណត់ឡើងមកចាប់តាំងពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានផ្តួចផ្តើមគំរោងចុះបញ្ជីដីសាកល្បងនៅក្នុងសហគមន៍ចំនួន៣ក្នុងខេត្តរតនគីរី និងមណ្ឌលគីរី នៅខែធ្នូ ឆ្នាំ២០០៣។ ទន្ទឹមនឹងនេះ ស្ថាប័នរដ្ឋាភិបាលផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងគំរោងសាកល្បងនេះដែររួមមាន : រដ្ឋបាលព្រៃឈើ, ក្រសួងមហាផ្ទៃ និងក្រសួងអភិវឌ្ឍន៍ជនបទ។ មានអង្គការជាតិ និងអន្តរជាតិជាច្រើន បានចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយគាំទ្រ ទាំងធនធានថវិកា និងបច្ចេកទេសសំរាប់គំរោងសាកល្បងទាំងបី ក៏ដូចជាដំណើរការនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ដែលបាន និងកំពុងដំណើរការនាពេលបច្ចុប្បន្ន។ បណ្តាអង្គការទាំងនោះរួមមាន : កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ/ដៃគូអភិបាលកិច្ចមូលដ្ឋាន អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍន៍ និងសាមគ្គីភាព-ស៊ីដសេ (ឥឡូវមកជាអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព-ឌីភីអេ) មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ អង្គការសមាគមអភិរក្សសត្វព្រៃកម្ពុជា (WCS) សមាគមខ្មែរលើ ជីធីហ្សិត (GTZ) អង្គការពលកម្មអន្តរជាតិ ដានីដា (Danida) និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។

ការរៀបចំផែនការប្រើប្រាស់ដីដោយមានការចូលរួម (PLUP) គឺជាផ្នែកមួយយ៉ាងសំខាន់នៅក្នុងដំណើរការនៃការអនុវត្តគំរោងចុះបញ្ជីដីសាកល្បង។ ក្រុម PLUP ត្រូវបានសំរបសំរួលដោយ គណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត និងគណៈកម្មការដោះស្រាយទំនាស់ដីធ្លី ដោយសហការជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយ។

ដំណើរការនៃការចុះបញ្ជីដីសាកល្បងសំរាប់សហគមន៍ជនជាតិដើមភាគតិចនៅក្នុងឆ្នាំ ២០០៤ មានចំនួន ១២ ជំហាន ដូចខាងក្រោម :

១. ការជ្រើសរើសភូមិគោលដៅ

២. ការបង្កើតក្រុមការងារចុះបញ្ជីថ្នាក់ខេត្ត

៣. ការផ្សព្វផ្សាយច្បាប់ភូមិបាល

៤. សហគមន៍ដាក់ពាក្យសុំចុះបញ្ជីដីជាសមូហភាព

៥. រដ្ឋបាលស៊ុរិយោដីស្រុកធ្វើការពិនិត្យឡើងវិញលើការរៀបចំផែនការប្រើប្រាស់ដីដោយមានការចូលរួម (PLUP)

៦. បណ្តុះបណ្តាលមន្ត្រីវិនិច្ឆ័យ និងកំណត់ព្រំប្រទល់

[១] យោងតាមរបាយការណ៍ ម៉ែន ប្រាជ្ញវុទ្ធី (Men Prachvuthy) "ការទទួលបានដីធ្លី ដោយតួអង្គក្រៅមូលដ្ឋាន និងសារៈសំខាន់នៃការអភិវឌ្ឍន៍មូលដ្ឋាន : ផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ចលើជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច នៅតំបន់ ភូមិភាគឦសាន នៃប្រទេសកម្ពុជា" ខែមីនា ឆ្នាំ២០១១" *("Land Acquisition by Non-Local Actors and Consequences for Local Development: Impacts of Economic Land Concession on the Livelihoods of Indigenous Communities in Northest Province of Cambodia", March 2011)*

៧. ការរៀបចំសហគមន៍អោយក្លាយជានីតិបុគ្គល

៨. ការវាស់វែង, កំណត់ព្រំប្រទល់ ការវិនិច្ឆ័យ និងការវិភាគ

៩. ការដាក់តាំងបង្ហាញជាសាធារណៈនូវឯកសារវិនិច្ឆ័យ

១០. ការដោះស្រាយទំនាស់

១១. ចុះហត្ថលេខាជាមួយអ្នកពាក់ព័ន្ធ

១២. ចេញប័ណ្ណដោយក្រសួងរៀបចំដែនដី

ទោះបីជាយ៉ាងណាក៏ដោយ ជំហាននៅក្នុងអនុវត្តការចុះបញ្ជីដីជាសមូហភាពសំរាប់សហគមន៍ជនជាតិដើមភាគតិច គឺមានការផ្លាស់ប្តូរជាច្រើនលើក ដោយនៅក្នុងនោះនៅឆ្នាំ២០០៧ គេបានប្តូរពី១២ជំហាន មកចំនួន៨ ជំហានវិញ។

– **ដំណើរការនៃការអនុវត្តគំរោងចុះបញ្ជីដីសាកល្បងនៅក្នុងឆ្នាំ២០០៧មានចំនួន៨ជំហានដែលរួមមាន ៖**

១. ការផ្សព្វផ្សាយច្បាប់ និងគោលនយោបាយពាក់ព័ន្ធការចុះបញ្ជីដីសហគមន៍ដល់សហគមន៍

២. សិក្ខាសាលាស្តីពីការស្វែងយល់ចំណេះដឹង និងសាក្ខីភាពនៃជំរើសសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគ តិច

៣. រៀបចំសហគមន៍ និងលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិច

៤. ការដាក់ពាក្យស្នើសុំចុះបញ្ជីដីសមូហភាពដោយសហគមន៍

៥. ពិនិត្យព្រំប្រទល់រដ្ឋបាលឃុំ និងកសាងគំនូសព្រាងផែនទីប្រើប្រាស់ដីភូមិ/ឃុំ

៦. ធ្វើអត្តសញ្ញាណកម្ម ផែនទី និងចំណាត់ថ្នាក់ដីរដ្ឋ

៧. អនុវត្តនីតិវិធីចុះបញ្ជីដីសហគមន៍ដោយផ្អែកតាមនីតិវិធីចុះបញ្ជីដីជាច់ដោយដុំ និង

៨. ការចេញប័ណ្ណកម្មសិទ្ធិដីធ្លីដល់សហគមន៍

# ជំពូកទី៣ ៖ បទពិសោធន៍រៀនសូត្រក្នុងការចុះបញ្ជីដីធ្លី នៅភូមិឡាអិន ខេត្តរតនគិរី

## ១. ភាពជោគជ័យរបស់គំរោង

*តើអ្វីខ្លះដែលអង្គការ **ឌីភីអេ** និងក្រុមការងារធ្វើទៅបានជោគជ័យ ហើយមានកត្តាអ្វីខ្លះក្នុងការជួយជំរុញ?*

[២]ដោយមានគំនិតផ្តួចផ្តើមពីរាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តគំរោងចុះបញ្ជីដីធ្លីសាកល្បង សំរាប់សហគមន៍ជនជាតិដើមភាគតិច ដោយនៅក្នុងនោះសហគមន៍ចំនួនបីត្រូវបានជ្រើសរើស ។ បន្ទាប់ពីការកំណត់នូវតំបន់ជាក់លាក់ហើយនោះ ក្រុមការងារអន្តរក្រសួងមួយត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លីនៅក្នុងឆ្នាំ២០០៤ ដើម្បីធ្វើការសិក្សាទៅលើការស្នើសុំចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច (Inter-Ministerial Task Force for the Study of the Registration of Indigenous Land Rights).[៣]

ក្រុមការងារអន្តរក្រសួងនេះ បានចុះសិក្សានៅខេត្តរតនគិរី នៅអំឡុងខែឧសភា ឆ្នាំ២០០៤ ហើយព្រមជាមួយគ្នានេះ នៅខែវិច្ឆិកា ឆ្នាំ២០០៤ ក្រុមការងារអន្តរក្រសួងបានយករូបភាពវីឌីអូមួយ ដែលឆ្លុះបញ្ចាំងអំពីបទពិសោធន៍នៃដំណើរការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចនៅប្រទេសហ្វីលីពីន មកធ្វើការដាក់បញ្ចាំងបង្ហាញដល់សហគមន៍ជនជាតិដើមភាគតិច នៅខេត្តរតនគិរី ជាពិសេសសហគមន៍នៅភូមិគោលដៅទាំងពីរ ។ ជាលទ្ធផល យើងឃើញថាប្រជាសហគមន៍ភាគច្រើនមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើរូបភាពវីឌីអូនោះ ។ បន្ទាប់ពីនោះមក ក្រុមការងារអន្តរក្រសួងបានសហការជាមួយនិង អង្គការជាតិ និងអន្តរជាតិដែលជាដៃគូ ធ្វើការផ្សព្វផ្សាយអំពីការចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិច នៅភូមិគោលដៅទាំងបី (ពីរភូមិនៅក្នុងខេត្តរតនគិរី គឺឡាអិន និងឡាអឺនក្រែង និង១ភូមិនៅខេត្តមណ្ឌលគិរី គឺភូមិអណ្តូង ក្រឡឹង) ដែលនៅក្នុងនោះ អង្គការ **ឌីភីអេ_ខេត្តរតនគិរី** ធ្វើការគាំទ្រ និងជួយសម្របសម្រួលដល់ការចុះបញ្ជីដីធ្លីនៅ ភូមិឡាអិន ឃុំតឺន ស្រុកកូនមុំ ខេត្តរតនគិរី ។[៤]

### ដំណើរការនៃការចុះបញ្ជីដីធ្លីនៅភូមិឡាអិន

ការប្រកបមុខរបរចិញ្ចឹមជីវិតសំខាន់របស់ជនជាតិដើមភាគតិចនៅក្នុងភូមិនេះ គឺពឹងផ្អែកទាំងស្រុងទៅលើការធ្វើស្រែ និងចំការវិលជុំ ។ កន្លងមក ប្រជាសហគមន៍នៅក្នុងភូមិឡាអិនបានទទួលរងនូវការបាត់បង់ដីធ្លីដោយសារ ការលក់ដីធ្លីទៅឱ្យអ្នកផ្សេង និង

---

[២] យោងតាមឯកសាររបស់អង្គការពលកម្មអន្តរជាតិ (ILO) *"ការអភិវឌ្ឍលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិច"*

[៣] ក្រុមការងារអន្តរក្រសួងនេះមានការចូលរួមពីតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ រដ្ឋបាលព្រៃឈើ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

[៤] យោងតាមឯកសាររបស់អង្គការពលកម្មអន្តរជាតិ (ILO) *"ការអភិវឌ្ឍលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិច"*

ការកាប់ទន្រ្ទានព្រៃដើម្បីពង្រីកយកដីពីសំណាក់អ្នកមកពីខាងក្រៅភូមិអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ទង្វើទាំងអស់នេះបានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើនិរន្តរភាព នៃការប្រើប្រាស់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ។

*ក្នុងនាមជាសមាជិកម្នាក់នៅក្នុងភូមិឡាអិន* ***លោក ណាត់ ច្រូង*** *បានមានប្រសាសន៍ថា "ដីមានសារៈសំខាន់ណាស់ ដែលយើងទាំងអស់គ្នាត្រូវចូលរួមថែរក្សាឱ្យបានគង់វង្ស ពីព្រោះអ្វីៗទាំងអស់គឺកើតចេញមកពីដី ដែលរួមមាន : ច្បាប់ ជំនឿ ប្រពៃណី និងការសាមគ្គីភាពគ្នានៅក្នុងសហគមន៍ ។ រាល់ជំនឿ ការបូជា និងការសែនព្រេនគ្រប់យ៉ាង គឺទាក់ទងយ៉ាងសំខាន់ ទៅនឹងដី ព្រៃ ចំការ និងអូរ ។ ដី គឺបានបង្កើតសហគមន៍ និងជីវិតគ្រួសារ ។"*

ការផ្តួចផ្តើមសកម្មភាពដំបូងនៅក្នុងភូមិឡាអិន គឺបានចាប់ផ្តើមឡើងតាមរយៈជំនួបពិភាក្សារវាងគណៈកម្មការគ្រប់គ្រងនៃស៊ីដសេ-កម្ពុជា (បច្ចុប្បន្ន ឌីភីអេ) ជាមួយនឹងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ខេត្តរតនគីរី ស្តីអំពីកិច្ចសហប្រតិបត្តិការគ្នាទៅវិញទៅមក នៅក្នុងអំឡុងពេលនៃដំណើរការចុះបញ្ជីដីសំរាប់សហគមន៍ជនជាតិដើមភាគតិចនៅក្នុង ភូមិឡាអិន ។ ស្របពេលជាមួយគ្នានេះដែរ ការផ្តួចផ្តើមសកម្មភាពដំបូង ក៏បានចាប់ផ្តើមឡើង តាមរយៈការសាកសួរសមាជិកសហគមន៍ថា តើតំបន់ណាមួយនៅក្នុងភូមិរបស់ពួកគាត់ ដែលពួកគាត់ចង់រក្សាទុកសំរាប់ធ្វើកសិកម្មវិលជុំនៅពេលអនាគត ។ កិច្ចពិភាក្សានេះ ក៏បានធ្វើឡើងដោយមានការចូលរួមពីគណៈកម្មាធិការគ្រប់គ្រងដីធ្លី អ្នកដឹកនាំភូមិ ក៏ដូចជាបានរៀបចំពង្រាងផែនទីតំបន់សំរាប់ចុះបញ្ជីផងដែរ ។

ទោះបីជាយ៉ាងណាក៏ដោយ ការងារនេះហាក់ដូចជាត្រូវបានគេទុកចោលមិនយកចិត្តទុកដាក់ ពីព្រោះទំហំនៃការលក់ដូរដីទ្រង់ទ្រាយធំបានកើតមានឡើងគួរអោយកត់សម្គាល់ ។ កត្តានេះ បានធ្វើអោយរាំងស្ទះដល់ដំណើរការនៃការចុះបញ្ជីដី ខណៈពេលដែលព្រំប្រទល់ភូមិនៅតែបន្តផ្លាស់ប្តូរទៀតនោះ ។

នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤ ស៊ីដសេ បានរៀបចំកិច្ចប្រជុំជាមួយអ្នកភូមិឡាអិនចំនួន ៣០ នាក់ ។ នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំនេះ អ្នកភូមិបានផ្តល់ព័ត៌មានផ្សេងៗទាក់ទងនឹងដំណើរការនៃការចុះបញ្ជី និងបញ្ជាក់ពីតំបន់មួយណាដែលពួកគាត់ចង់ចុះបញ្ជី ។ ស្របពេលជាមួយគ្នានេះដែរ អ្នកភូមិបានអោយដឹងទៀតថា មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់នឹងរៀបចំធ្វើកិច្ចប្រជុំមួយដើម្បីសាកសួរអំពីជំរើសរបស់អ្នកភូមិថាតើ ពួកគាត់ជ្រើសរើសការចុះបញ្ជីជាលក្ខណៈបុគ្គល ឬ ជាសមូហភាពសំរាប់ទុកធ្វើកសិកម្ម , សាងសង់លំនៅដ្ឋាន និងតំបន់ព្រៃវប្បធម៌ ។

អ្នកភូមិបានអោយដឹងថា នៅក្នុងឆ្នាំ២០០២ និងដើមឆ្នាំ២០០៣ មិនមានការលក់ដូរដីជាលក្ខណៈទ្រង់ទ្រាយធំនោះទេ ប៉ុន្តែនៅចុងឆ្នាំ២០០៣ និងដើមឆ្នាំ២០០៤ ការលក់ដូរដីមានការកើនឡើងយ៉ាងគំហុក ដែលពិបាកក្នុងការគ្រប់គ្រងមែនទែន ។ ដោយសារ

មានបញ្ហាបាត់បង់ដីធ្លីបែបនេះហើយ ទើបប្រជាជននៅភូមិឡាអិន បានផ្តួចផ្តើមគំនិតរៀបចំបង្កើតផែនការប្រើប្រាស់ដីធ្លី ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ភូមិ-ឃុំ ដើម្បីថែរក្សាការពារដីធ្លីនេះទុកសំរាប់ប្រើប្រាស់តកូនតចៅទៅជំនាន់ក្រោយ។ ទន្ទឹមនឹងនេះផងដែរ ការចុះបញ្ជីដីធ្លី គឺមានសារៈសំខាន់ណាស់សំរាប់សហគមន៍ដើម្បី :

- ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីប្រកបដោយស្ថេរភាព
- ធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាសហគមន៍
- ការពារបាននូវបរិស្ថាន និងធនធានធម្មជាតិដែលជាការចូលរួមកាត់បន្ថយភាពរិចរិល និងហិនហោច
- ជួយរដ្ឋាភិបាលក្នុងការគ្រប់គ្រង និងទប់ស្កាត់ការរំលោភបំពានយ៉ាងអាណាធិបតេយ្យលើការកាន់កាប់ដីធ្លីខុសច្បាប់
- បន្តថែរក្សាការពារដីធ្លីដែលនៅសេសសល់ ដើម្បីកុំឱ្យបាត់បង់ថែមទៀត និង
- កាត់បន្ថយការលក់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច។

ហេតុនេះ ដើម្បីដោះស្រាយទៅនឹងបញ្ហាស្មុគស្មាញទាំងអស់នេះ និងក្រោយពីបានពិភាក្សាជាមួយស៊ីដសេ-ឌីភីអេ យើងបានឃើញថា ការរៀបចំអោយមានជាអ្នករៀបចំសហគមន៍ (ស៊ីអូ) ឡើងនៅក្នុងភូមិគឺមានសារៈសំខាន់ណាស់ ដើម្បីធ្វើការងារពាក់ព័ន្ធនឹងការចុះបញ្ជីដីនេះ។ គំរោងគ្រប់គ្រងធនធានធម្មជាតិ អាចជួយថែរក្សានូវធនធានធម្មជាតិទាំងអស់នោះ អោយមានភាពល្អប្រសើរឡើងសំរាប់ប្រើប្រាស់បានយូរអង្វែង តាមរយៈការចូលរួមក្នុងដំណើរការរៀបចំធ្វើផែនទី និងប្រើប្រាស់ដីដោយមានការចូលរួម។ មួយវិញទៀត គំរោងនេះក៏បានជួយដល់បងប្អូនជនជាតិដើមភាគតិចនៅតាមមូលដ្ឋាន ក្នុងការរៀបចំផែនការប្រើប្រាស់ដីអោយកាន់តែប្រសើរឡើងសំរាប់ការធ្វើកសិកម្មវិលជុំ និងដំណាំស្រូវ ហើយនិងអាចកាត់បន្ថយការបំផ្លិចបំផ្លាញព្រៃឈើ និងអាចជួយការពារការដុតបំផ្លាញព្រៃសំរាប់ធ្វើចំការវិលជុំ ដែលជួនកាលធ្វើអោយបាត់បង់នូវគុណភាពដី។

ដោយឡែក **ឌីភីអេ-រតនគិរី** បានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមការងារគ្រប់គ្រងការរៀបចំផែនការប្រើប្រាស់ដីខេត្ត (Provincial Task Force of Land Use Planning Management) ក្នុងការអនុវត្ត និងពិនិត្យឡើងវិញ ទៅលើលក្ខខិកៈ នៃការគ្រប់គ្រង និងការរៀបចំផែនការប្រើប្រាស់ដីនៅភូមិឡាអិន។

## ក. ការកសាងសមត្ថភាពដល់សហគមន៍

ការចុះបញ្ជីដីធ្លីជាសមូហភាពសំរាប់សហគមន៍ជនជាតិដើមភាគតិច គឺជាបញ្ហារសើបមួយ។ ហេតុនេះ វាជាការចាំបាច់ណាស់ដែលសហគមន៍ជនជាតិដើមភាគតិចខ្លួនឯងត្រូវមានការយល់ដឹងជាមូលដ្ឋានអំពីសិទ្ធិក្នុងការប្រើប្រាស់ដីធ្លី និងការចូលរួមនូវគ្រប់ជំហាន និងដំណាក់កាល នៃការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល

និងការចុះបញ្ជីដីធ្លីជាសម្ហូភាព។ ហេតុនេះ ក្នុងនាមជាអ្នកគាំទ្រ និងសម្របសម្រួលនៅក្នុងដំណើរការចុះបញ្ជីដីធ្លីជាសម្ហូភាពសំរាប់សហគមន៍ជនជាតិដើមភាគតិចនៅភូមិឡាអិន អង្គការ **ឌីភីអេ-ខេត្តរតនគិរី** បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ចំណេះដឹងដល់សហគមន៍ឱ្យយល់ដឹងអំពីសិទ្ធិរបស់ខ្លួន ក្នុងការកាន់កាប់ និងប្រើប្រាស់ដីធ្លីដោយស្របច្បាប់ប្រកបដោយនិរន្តរភាព។

ដំណើរការនៃការចុះបញ្ជីដីធ្លីជាសម្ហូភាពសំរាប់សហគមន៍ជនជាតិដើមភាគតិច គឺជាដំណើរការមួយដ៏ស្មុគស្មាញ និងត្រូវការពេលវេលាច្រើន។ ដូច្នេះ ដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិស្របច្បាប់ និងទទួលស្គាល់ជាផ្លូវការពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ សហគមន៍ជនជាតិដើមភាគតិចចាំបាច់ត្រូវរៀបចំ និងកសាងនូវសំណុំឯកសារ ព្រមទាំងមានការគាំទ្រពីសំណាក់ក្រុមការងារសម្របសម្រួលនិងចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចទាំងនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងការចូលរួមគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ។

តាងនាមឱ្យសហគមន៍ជនជាតិដើមភាគតិចនៅភូមិឡាអិន អង្គការ **ឌីភីអេ-ខេត្តរតនគិរី** បានយកចិត្តទុកដាក់បំផុតក្នុងការកសាងសមត្ថភាពដល់សហគមន៍ ជាពិសេសសមាជិកគណៈកម្មាធិការសហគមន៍។ ការកសាងសមត្ថភាព គឺជាកត្តាចម្បងមួយ ដើម្បីលើកកម្ពស់ចំណេះដឹងដល់សមាជិកសហគមន៍ ដោយសារតែការយល់ដឹងរបស់ពួកគាត់មានកម្រិតទាបនៅឡើយ ជាពិសេសទាក់ទងទៅនឹងសិទ្ធិ គោលនយោបាយ និងច្បាប់មូលដ្ឋានផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹងសហគមន៍ជនជាតិដើមភាគតិច។ តាមការអនុវត្តជាក់ស្តែង យើងសង្កេតឃើញថា ការលើកកំពស់ការយល់ដឹងដែលប្រកបដោយប្រសិទ្ធភាព គឺត្រូវបានកំណត់ដោយវគ្គបណ្តុះបណ្តាល និងការហ្វឹកហាត់ជាបន្តបន្ទាប់ដល់គណៈកម្មាធិការសហគមន៍ (អាជ្ញាធរប្រពៃណី) នៅក្នុងការរៀបចំផ្សព្វផ្សាយ ដើម្បីលើកកំពស់ការយល់ដឹងជាសាធារណៈនៅក្នុងសហគមន៍។ ជាក់ស្តែង កន្លងមកនេះ អង្គការ **ឌីភីអេ-ខេត្តរតនគិរី** បានផ្តល់វគ្គបណ្តុះបណ្តាល និងការហ្វឹកហាត់ជាច្រើនដល់គណៈកម្មាធិការសហគមន៍ និងតំណាងសហគមន៍នៅភូមិឡាអិន។

តួយ៉ាង [៥] នៅក្នុងឆ្នាំ២00៤ **ឌីភីអេ-រតនគិរី** បានសហការជាមួយនឹងក្រុមការងារគ្រប់គ្រងការរៀបចំផែនការប្រើប្រាស់ដីខេត្ត រៀបចំវគ្គបណ្តុះបណ្តាលចំនួន៦វគ្គ នៅភូមិឡាអិន។ វគ្គបណ្តុះបណ្តាលទាំងអស់នោះរួមមាន ៖ កម្មសិទ្ធិដីធ្លី ច្បាប់ភូមិបាល និងសិទ្ធិមនុស្ស ដែលមានអ្នកចូលរួមសរុបចំនួន ១៩២ នាក់ (ស្ត្រី៩៤នាក់ ស្មើនឹង ៤៩%)។ ដូចគ្នាផងដែរ **ឌីភីអេ-រតនគិរី** បានធ្វើការគាំទ្រសហគមន៍ឡាអិនរៀបចំវគ្គបណ្តុះបណ្តាលមួយស្តីពី ម្ចាស់កម្មសិទ្ធិដីធ្លី ដោយមានអ្នកចូលរួមសរុបចំនួន ៣១នាក់ (ស្ត្រី១៥នាក់ ស្មើនឹង ៤៨%)។ ដោយឡែក សហគមន៍ឡាអិន បានរៀបចំកិច្ចប្រជុំមួយ ក្នុងគោលបំណងធ្វើការពិភាក្សាទាក់ទងទៅនឹងដំណើរការ និងការរៀបចំបញ្ជូនលក្ខន្តិកៈនៃការគ្រប់គ្រង និងការរៀបចំផែនការប្រើប្រាស់ដីនៅភូមិឡាអិន ទៅការិយាល័យសុរិយោដី

[៥] របាយការណ៍ប្រចាំឆ្នាំ ២00៤-២00៥ នៃគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះខេត្តរតនគិរី អង្គការឌីភីអេ



ស្រុក ដើម្បីស្នើសុំការអនុម័តយល់ព្រម។ ជាលទ្ធផល យើងឃើញថា លក្ខន្តិកៈនៃការគ្រប់គ្រង និងការរៀបចំផែនការប្រើប្រាស់ដីនៅ ភូមិឡាអិន ត្រូវបានទទួលស្គាល់ពីអភិបាលខេត្ត និងមន្ទីរបរិស្ថាន កសិកម្ម និងគ្រប់គ្រង និងរៀបចំផែនការប្រើប្រាស់ដី នៅខែមីនា ឆ្នាំ ២០០៤។ លក្ខន្តិកៈនេះត្រូវបានថតចម្លងជូន និងផ្សព្វផ្សាយទៅដល់ភូមិជិតខាងដើម្បីទុកជាព័ត៌មាន បន្ទាប់ពីមានការទទួលស្គាល់ជាផ្លូវការរួចមក។

ក្នុងគោលបំណងដើម្បីលើកកម្ពស់ចំណេះដឹង និងការយល់ដឹងរបស់សហគមន៍ជនជាតិដើមភាគតិចទាក់ទងទៅនឹងសិទ្ធិមនុស្ស **ឌីភីអេ-រតនគិរី** បានសហការជាមួយនឹង **អង្គការ អាដហុក** ដែលជាអង្គការសិទ្ធិមនុស្សក្នុងស្រុកមួយ រៀបចំវគ្គបណ្តុះបណ្តាលចំនួនបួនវគ្គស្តីពី សិទ្ធិមនុស្ស។ វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងសំរាប់៤ភូមិនៅក្នុងឃុំតឹន ដែលមានអ្នកចូលរួមសរុបទាំងអស់ចំនួន ១០៧ នាក់ (ស្ត្រី ៣៩នាក់)។ តាមរយៈវគ្គបណ្តុះបណ្តាលនេះ អ្នកចូលរួមទាំងអស់បានសិក្សាទាក់ទងទៅនឹងសិទ្ធិមនុស្ស និងបញ្ហាផ្សេងៗទាក់ទងទៅនឹងការដណ្តើមដីធ្លី ការកាប់បំផ្លាញព្រៃឈើ និងសិទ្ធិក្នុងការការពារដីធ្លី និងធនធានព្រៃឈើ។ យោងតាមលទ្ធផលនៃការសំភាសន៍ដោយប្រយោលជាមួយនឹងអ្នកចូលរួម យើងពិនិត្យឃើញថា អ្នកចូលរួមចំនួន៨នាក់ ស្មើនឹង៦៦ ភាគរយ នៃភូមិទាំង ៤ បាននិយាយថាពួកគាត់បានសរសេរពាក្យបណ្តឹងទៅសមាជិកក្រុមប្រឹក្សាឃុំ អង្គការអាដហុក និងស៊ីដសេ ក៏ដូចជាអាចសរសេរទៅកាន់ស្ថាប័នមានសមត្ថកិច្ច និងមន្ទីររដ្ឋាភិបាលពាក់ព័ន្ធទាក់ទងទៅនឹងការដណ្តើមដីធ្លី និងការកាប់ឈើដោយខុសច្បាប់ជាដើម។

*"ពីមុន អ្នកភូមិមិនទាន់យល់ថាអ្វីដែលជាការលក់ដូរដី ការដណ្តើមដីធ្លី និងសារៈសំខាន់នៃធនធានធម្មជាតិនោះទេ។ ដោយសារតែភាពក្រីក្រ ហើយអ្នកភូមិត្រូវការលុយដើម្បីផ្គត់ផ្គង់គ្រួសារ ហេតុនេះពួកគេចាប់ផ្តើមលក់ដីរបស់ខ្លួន។ ស្របពេលជាមួយគ្នានេះដែរ ចាប់តាំងពីមានអ្នកមានអំណាចមួយចំនួនតូចមកពីក្រុងបានលុង បាននិយាយថាផ្លូវតាមបណ្តោយភូមិនេះនឹងត្រូវធ្វើការជួសជុលឡើងវិញចាប់ពីបានលុងទៅដល់ព្រំប្រទល់ប្រទេសវៀតណាម។ ក្រោយមកទៀត ពួកគេទាំងអស់បានចាប់ផ្តើមដណ្តើមដីធ្លីពីភូមិរបស់ខ្ញុំ។ អ្នកភូមិឡាអិនជាច្រើនបានជឿជាក់ថាដីនៅក្នុងភូមិរបស់ពួកគេ នឹងមានការបាត់បង់បន្ថែមទៀត។ ហេតុនេះ ពួកយើងបានស្នើសុំអោយស៊ីដសេ-ឌីភីអេ ជួយពួកយើងដើម្បីការពារបញ្ហាផ្សេងៗដែលកើតមានឡើង។ យើងបានចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំផែនការប្រើប្រាស់ដីធ្លី ដែលរួមមាន: ការ វាយតម្លៃការគ្រប់គ្រងប្រើប្រាស់ដីធ្លី ការគូសផែនទី ការរៀបចំលក្ខន្តិកៈ និងធ្វើការបង្ហាញនៅគ្រប់លំដាប់ថ្នាក់។ យើងសប្បាយរីករាយណាស់ នៅពេលដែលដឹងថាលក្ខន្តិកៈនៃការគ្រប់គ្រង និងរៀបចំផែនការប្រើ-ប្រាស់ដីធ្លីភូមិឡាអិន ត្រូវបានគេទទួលស្គាល់បែបនេះ។"*

***លោក ណាត់ ច្រួង ជនជាតិដើមភាគតិចទំពួន នៃភូមិឡាអិន***

ម្យ៉ាងវិញទៀត **ឌីភីអេ-រតនគីរី** បានរៀបចំអោយមានដំណើរទស្សនកិច្ចសក្សាដល់អ្នកភូមិឡាអិនផងដែរ ដើម្បីទទួលបានមេរៀន និងបទពិសោធន៍ល្អៗពីសហគមន៍ផ្សេង ក៏ដូចជាផ្តល់បណ្តុះបណ្តាលផ្សេងៗដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា ច្បាប់ភូមិបាល ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ បច្ចេកទេសនៅក្នុងការកំណត់ព្រំប្រទល់ (ជីភីអេ-GPS) វិធីសាស្ត្រក្នុងការដោះស្រាយទំនាស់ ដែលទាក់ទងនឹងវិវាទព្រំប្រទល់ និងការចរចារ ក៏ដូចជាការដោះស្រាយវិវាទជាមួយនឹងអ្នកខាងក្រៅ ដែលរំលោភបំពាន (ឈ្មួញ ឬ ក្រុមហ៊ុនជាដើម ។ល។

## ខ. ជំរើសសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច

ដើម្បីស្វែងយល់ពីចំណេះដឹង និងធ្វើការបញ្ជាក់ជាចុងក្រោយនូវសំណើរបស់សហគមន៍នៅចំពោះមុខអាជ្ញាធរ និងស្ថាប័ន-ជំនាញពាក់ព័ន្ធលើជំរើសសិទ្ធិកាន់កាប់ដីធ្លីដែលសហគមន៍ស្នើសុំ **ឌីភីអេ-រតនគីរី** បានធ្វើការសហការជាមួយនឹងមន្ត្រី មកពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរតនគីរី តាមរយៈការិយាល័យដែនដី នគរូបនីយកម្ម និងសំណង់ថ្នាក់ភូមិ រៀបចំសិក្ខាសាលាមួយស្តីពីការស្វែងយល់ចំណេះដឹង និងសាក្ខីភាពនៃជំរើសសិទ្ធិកាន់កាប់ដីធ្លីរបស់ សហគមន៍ជនជាតិដើមភាគតិចទំពួននៅភូមិឡាអិន ដោយមានការចូលរួមពីអាជ្ញាធរឃុំ ស្រុក ខេត្ត មន្ទីរជំនាញពាក់ព័ន្ធ និងសហគមន៍មកពីភូមិឡាអិន ។

អាជ្ញាធរប្រពៃណី បានដើរតួនាទីយ៉ាងសំខាន់ ក្នុងនាមជាអ្នកសំរបសំរួលក្នុងកិច្ចពិភាក្សាអំពីជំរើសសិទ្ធិកាន់កាប់ដីធ្លី ហើយជាគោលការណ៍ថាតើសហគមន៍សម្រេចចិត្តជ្រើសរើសយកការចុះបញ្ជីជាកម្មសិទ្ធិឯកជន ឬ កម្មសិទ្ធិសមូហភាព? បន្ទាប់ពីកិច្ចពិភាក្សាបានបញ្ចប់ អាជ្ញាធរប្រពៃណីត្រូវធ្វើការបង្ហាញលទ្ធផលនៃកិច្ចពិភាក្សាដល់អ្នកចូលរួមទាំងអស់នៅក្នុងសិក្ខាសាលា ។

បន្ទាប់ពីកិច្ចពិភាក្សាបានបង្ហាញអោយឃើញថា អ្នកភូមិភាគច្រើនបានទទួលស្គាល់ថា ការរក្សាអត្តសញ្ញាណ ការចុះបញ្ជីសហគមន៍ជានីតិបុគ្គល និងការចុះបញ្ជីដីធ្លីជាសមូហភាព គឺជាវិធានការមួយដ៏មានសារៈសំខាន់សំរាប់ការពារដីធ្លីរបស់ពួកគេកុំឱ្យបាត់បង់ ។ ពួកគេមានការយល់ដឹងយ៉ាងច្បាស់អំពីភាពខុសគ្នា និងសារៈសំខាន់នៃការចុះបញ្ជីដីធ្លីជាសមូហភាព និងការចុះបញ្ជីដីធ្លីជាលក្ខណៈឯកជននោះ ។ ការចុះបញ្ជីដីធ្លីជាសមូហភាព អាចធានាបាននូវសុវត្ថិភាពក្នុងការកាន់កាប់ដីធ្លី និងការពារកម្មសិទ្ធិសមូហភាពដោយអាចរក្សាបាននូវអត្តសញ្ញាណ វប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីដ៏ល្អរបស់ជនជាតិដើម ភាគតិចទំពួនរបស់ពួកគេបាន ហើយកម្មសិទ្ធិនេះ មិនមែនជាកម្មសិទ្ធិឯកជនដោយឡែកៗរបស់សមាជិកសហគមន៍ណាម្នាក់នោះឡើយ ។

### គ. ស្វ័យអត្តសញ្ញាណ និងការវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច

ទន្ទឹមគ្នានឹងការកសាងសមត្ថភាព យើងឃើញថា ការឯកភាព និងស្រុះស្រួលឆន្ទៈបង្កើតសហគមន៍ ក៏ជាកត្តាមួយសំខាន់ផងដែរ ពីព្រោះវាជួយជំរុញឱ្យមានភាពប្រសើរឡើងនៅក្នុងដំណើរការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ការធ្វើផែនទីភូមិ និងការគ្រប់គ្រងការប្រើប្រាស់ដីធ្លីតាមបែបប្រពៃណី។

ម្យ៉ាងវិញទៀត ការប្រកាសស្វ័យអត្តសញ្ញាណ ក៏ជាការបង្ហាញនូវការឯកភាព និងស្រុះស្រួលឆន្ទៈក្នុងការបង្កើតសហគមន៍ពិសេស គឺបង្ហាញនូវអត្តសញ្ញាណជនជាតិដើមភាគតិចនីមួយៗ ដើម្បីជូនដំណឹងដល់ស្ថាប័នមានសមត្ថកិច្ចឱ្យទទួលស្គាល់អត្តសញ្ញាណរបស់ក្រុមជនជាតិដើមភាគតិចរបស់ពួកគេ។ ការប្រកាសអត្តសញ្ញាណ គឺតម្រូវឱ្យមានការរៀបចំនៅក្នុងសហគមន៍ ដែលពួកគេកំពុងរស់នៅជាក់ស្តែង ដោយមានការចូលរួមពីគ្រប់សមាជិកសហគមន៍ទាំងអស់ និងមានការចូលរួមដឹងឮពីសាមីអាជ្ញាធរឃុំ។ បន្ទាប់មកទៀត ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិចនៃក្រសួងអភិវឌ្ឍន៍ជនបទ នឹងបន្តចុះពិនិត្យ និងវាយតម្លៃផ្ទាល់ដល់សហគមន៍តាមនីតិវិធី និងលក្ខខណ្ឌចាំបាច់នានា។

ក្នុងអំឡុងពេលនៃការចុះសិក្សា និងវាយតម្លៃអត្តសញ្ញាណសហគមន៍ពីក្រុមការងារនាយកដ្ឋាននេះ វាជាការចាំបាច់ណាស់ដែលពួកគាត់ (សហគមន៍ឡាអិន) ត្រូវរៀបចំខ្លួនឯងអោយបានរួចជាស្រេច ដើម្បីបង្ហាញអោយគេដឹងថាពួកគាត់ គឺជាជនជាតិទំពួនពិតប្រាកដ។ ហេតុនេះ ពួកគាត់ត្រូវដឹង និងយល់ច្បាស់លាស់ទៅលើជាតិពន្ធ សំលៀកបំពាក់ ជំនឿ និងវប្បធម៌ ប្រពៃណីរបស់ជនជាតិទំពួនថាតើមានអ្វីខ្លះ ការប្រើប្រាស់ភាសា តំណម និងការសែនព្រេនជាដើម។

### ឃ. សហគមន៍ដាក់ពាក្យស្នើសុំចុះបញ្ជី

បន្ទាប់ពីសហគមន៍ជនជាតិដើមភាគតិចទំពួនភូមិឡាអិន បានធ្វើការសំរេចចិត្តជ្រើសរើសការចុះបញ្ជីដីជាសម្ហូហភាព **ឌីភីអេ-រតនគិរី** បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសំរបសំរួល និងគាំទ្រពួកគាត់ដើម្បីដាក់ពាក្យស្នើសុំចុះបញ្ជីដីជាសម្ហូហភាព។ ហេតុនេះ **ឌីភីអេ-រតនគិរី** បានសហការយ៉ាងជិតស្និទ្ធជាមួយនឹងមន្ទីររដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីកសាងសមត្ថភាពសហគមន៍ទាក់ទងទៅនឹងការបំពេញទម្រង់ស្នើសុំចុះបញ្ជីដី។

### ង. ពិនិត្យឡើងវិញលើការរៀបចំផែនការប្រើប្រាស់ដីដោយមានការចូលរួម (PLUP)

អង្គការ DANIDA តាមរយៈអង្គការ ILO បានគាំទ្រការធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម (PLUP) ដែលនេះ

គឺជាផ្នែកមួយ នៃលក្ខខណ្ឌសម្រាប់កំណត់ស្វ័យអត្តសញ្ញាណសហគមន៍នៅក្នុងសហគមន៍សាកល្បងទាំងបី គឺភូមិឡាអិន ភូមិឡាអឺនក្រែង និងភូមិអណ្ដូងក្រឡឹង។ ការរៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម (PLUP) បានបង្កើតការគ្រប់គ្រងការប្រើប្រាស់ដី និងការកំណត់ព្រំប្រទល់រវាងសហគមន៍ និងសហគមន៍។

ព្រឹត្តិប័ត្រសារពតិមានរបស់អគ្គលេខាធិការដ្ឋានគោលនយោបាយដីធ្លីស្ដីពី គោលនយោបាយចុះបញ្ជីដីធ្លីនៅកម្ពុជាបានលើកឡើងថា "ការផ្ដល់សុវត្ថិភាពដីធ្លីដោយការចុះបញ្ជីដីធ្លីរបស់ជនជាតិដើមភាគតិចដោយ រួមបញ្ចូលជាមួយការធ្វើផែនទីប្រើប្រាស់ដីធ្លីគឺជាវិធីមួយដ៏ល្អបំផុត ដើម្បីទប់ទល់នឹងការគំរាមកំហែងបាត់បង់ដី និងឆ្ពោះទៅរកគោលដៅរយៈពេលវែងគឺ កាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។" ហេតុនេះក្រុមជំរុញការងារផ្នែកកម្មសិទ្ធរបស់ សហគមន៍ជនជាតិដើមភាគតិចត្រូវបានបង្កើតឡើងមក ហើយគំរោងសាកល្បងសំរាប់ការធ្វើអត្តសញ្ញាណកម្មដីកម្មសិទ្ធិរបស់ជនជាតិដើមភាគតិច ត្រូវបានចាប់ផ្ដើមធ្វើនៅខេត្តមណ្ឌលគីរី និងខេត្តរតនគីរី។

នៅក្នុងឆ្នាំ២០០៦ ដំណើរការនៃការចុះបញ្ជីដីនៅភូមិឡាអិន ត្រូវបានពន្យាពេល ដោយសារតែក្រសួង និងមន្ទីរពាក់ព័ន្ធមិនទាន់ច្បាស់លាស់ទៅលើតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងដំណើរការនេះ និងពិបាកធ្វើការសំរបសំរួលជាមួយនឹងខាងរដ្ឋាភិ - បាល។ ហេតុនេះ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ **ឌីភីអេ-រតនគីរី** បានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹង បុគ្គលិកមន្ទីររដ្ឋាភិបាលដែលពាក់ព័ន្ធ ដោយបានស្នើសុំពួកគេធ្វើជាបុគ្គលិកសហការ និងជាទីប្រឹក្សាថ្នាក់មូលដ្ឋាន ដើម្បីធ្វើការងារជាមួយនឹងឌីភីអេ។ នៅក្នុងអំឡុងពេលនៃការអនុវត្ត PLUP យើងឃើញថា ក៏មានការកើតឡើងនូវទំនាស់ព្រំប្រទល់ឃុំជាមួយនឹងឃុំជិតខាងផងដែរ។ បន្ទាប់ពីមានហេតុការណ៍នេះកើតឡើង បុគ្គលិក **ឌីភីអេ-រតនគីរី** បានរៀបចំកិច្ចប្រជុំមួយឡើង ដោយមានការចូលរួមពីចាស់ទុំភូមិ និងអ្នកភូមិពាក់ព័ន្ធ ដើម្បីពិភាក្សាស្វែងរកដំណោះស្រាយផ្សេងៗ ដើម្បីដោះស្រាយបញ្ហាខាងលើនេះ ក៏ដូចជាធ្វើការកំណត់នូវខ្សែបន្ទាត់ព្រំដែន។

ធាតុពិត ដំណើរការ PLUP[៦] មានចំនួន១២ ជំហាន ប៉ុន្តែនៅក្នុងឆ្នាំ២០០៧ នៅសល់តែ៨ជំហានតែប៉ុណ្ណោះ បន្ទាប់ពីមានការពិនិត្យឡើងវិញលើដំណើរការ PLUP នេះ ដោយក្រុមការងារអន្តរក្រសួង (ក្រុម PLUP) ដែលបានធ្វើឡើងនៅខេត្ត ស្ទឹងត្រែង។

ការធ្វើផែនទីប្រើប្រាស់ដីធ្លីដោយមានការចូលរួមនៅក្នុងសហគមន៍ឡាអិន បានចំណាយពេលអស់ជិត១ឆ្នាំដោយមានការចូលរួម និងយល់ព្រមទទួលស្គាល់ពីសំណាក់អ្នកពាក់ព័ន្ធផ្សេងៗ និងសហគមន៍ជិតខាង។ ផែនទីនេះ ត្រូវបានគេប្រើប្រាស់សំរាប់កំណត់ព្រំប្រទល់ក្បាលដី ដែលនេះជាផ្នែកមួយនៃការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច។ មួយវិញទៀត ការធ្វើផែនទីភូមិស្ដីពីការគ្រប់គ្រង និងការប្រើប្រាស់ដីតាមបែបប្រពៃណី តាមរយៈការវាយតម្លៃដោយមានការចូលរួមត្រូវបានប្រើប្រាស់សម្រាប់កំណត់ស្វ័យអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច។ ការធ្វើផែនទីភូមិ តម្រូវឱ្យមានការចូលរួមពី អាជ្ញាធរមូលដ្ឋាន (ក្រុមប្រឹក្សាឃុំ និង

[៦] សូមមើលឧបសម្ព័ន្ធទី១ : ដំណើរការ និងជំហាននៃការរៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម

អាជ្ញាធរភូមិ) អ្នកភូមិគោលដៅ និងអ្នកភូមិជិតខាង ដើម្បីយល់ព្រមទទួលស្គាល់ព្រំ ប្រទល់ភូមិរបស់ខ្លួន។ តាមរយៈការគូសផែនទីភូមិ ការគ្រប់គ្រងការប្រើប្រាស់ដីតាមបែបប្រពៃណី ដែលជាផ្នែកមួយនៃការសិក្សាដោយមានការចូលរួមស្តីពី ការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ត្រូវបានរៀបចំក្នុងរយៈពេលមួយខែ។

តាមរយៈការអនុវត្តជាក់ស្តែងយើងឃើញថា ការបង្កើតផែនទីភូមិតាមរយៈការវាយតម្លៃដោយមានការចូលរួមក្នុងរយៈពេលមួយខែ គឺជាយន្តការគន្លឹះ ដើម្បីអាចឱ្យសហគមន៍ជនជាតិដើមភាគតិចទទួលបានការស្រុះស្រួលគ្នាអំពីអត្តសញ្ញាណរបស់ពួកគាត់ ហើយជាពិសេស គឺការគ្រប់គ្រងការប្រើប្រាស់ដីប្រពៃណីរបស់ពួកគាត់។

ដូចគ្នាដែរ តាមរយៈការអនុវត្តជាក់ស្តែង យើងសង្កេតឃើញថា សហគមន៍នៅភូមិឡាអិន រួមទាំងអាជ្ញាធរប្រពៃណី តំណាងសហគមន៍ និងសមាជិកសហគមន៍ទាំងអស់ បានបង្ហាញនូវភាពម្ចាស់ការនៃដំណើរការ និងការយល់ដឹងច្បាស់អំពី ផលប្រយោជន៍នៃការការពារដីធ្លីរបស់ពួកគាត់។ ការស្ម័គ្រចិត្ត និងការសំរេចចិត្តរបស់សហគមន៍នេះ គឺបានស្តែងចេញ តាមរយៈការប្រជុំសំរេចដោយមានការចូលរួមពីសំណាក់សមាជិកសហគមន៍ និងការចូលរួមដឹងឮពីអាជ្ញាធរមូលដ្ឋានផងដែរ។

មួយវិញទៀត នៅក្នុងឆ្នាំ២០០៧ ដំណើរការនៃការអនុវត្ត PLUP បានជួបប្រទះនូវបញ្ហាមួយចំនួននៅក្នុងខេត្តរតនគិរី។ ទោះបីជាមានការលំបាកទាក់ទងនឹងការងាររដ្ឋបាលក៏ដោយ យើងឃើញថាអ្នកភូមិជាច្រើនមានការកើនឡើងនូវ ការយល់ដឹងច្រើនពីសារៈសំខាន់នៅក្នុងការអនុវត្តដំណើរការនេះ ដែលជាលទ្ធផលយើងឃើញថាការដណ្តើមដីធ្លី គឺត្រូវបានកាត់បន្ថយច្រើន។

## ច. ការរៀបចំសហគមន៍ និងលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិច[៧]

ការបង្កើតផែនការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីសមស្របសំរាប់សហគមន៍ គឺត្រូវតែមានច្បាប់គ្រប់គ្រង និងថែរក្សាការពារធនធានធម្មជាតិ។ ទន្ទឹមគ្នានេះដែរ សហគមន៍ខ្លួនឯងផ្ទាល់ត្រូវមានភាពម្ចាស់ការលើការអនុវត្តច្បាប់ លើការគ្រប់គ្រងអោយមានប្រសិទ្ធភាព និងមាននិរន្តរភាព ដើម្បីជាផលប្រយោជន៍ដល់កូនចៅជំនាន់ក្រោយ។ ហេតុនេះ លក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិចជាបញ្ញត្តិសំរាប់អនុវត្តការគ្រប់គ្រងសហគមន៍ជនជាតិដើមភាគតិច ឱ្យស្របទៅតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល និងច្បាប់។

នៅក្នុងអំឡុងពេលនៃការរៀបចំចងក្រងលក្ខន្តិកៈនេះ អង្គការ **ឌីភីអេ-ខេត្តរតនគិរី** បានសហការជាមួយនឹងក្រុមការងារថ្នាក់ខេត្ត ដើម្បីផ្សព្វផ្សាយអំពីទម្រង់គំរូលក្ខន្តិកៈ និងសម្របសម្រួលក្នុងការបំពេញខ្លឹមសារនៃសេចក្តីព្រាងលក្ខន្តិកៈដោយផ្ទាល់ដល់តំណាងសហគមន៍។ បន្ទាប់ពីយើងបានរៀបចំសេចក្តីព្រាងលក្ខន្តិកៈសំរាប់សហគមន៍រួចហើយមក យើងបានធ្វើការសម្របសម្រួលជា

[៧] សូមមើលឧបសម្ព័ន្ធទី២ : នីតិវិធីក្នុងការបង្កើតសហគមន៍ និងការរៀបចំលក្ខន្តិកៈ

មួយនឹងតំណាងសហគមន៍ក្នុងការពិគ្រោះយោបល់លើ ខ្លឹមសារសេចក្តីព្រាងលក្ខន្តិកៈបឋម ជាមួយនឹងសមាជិកសហគមន៍ ដើម្បីឱ្យមានការឯកភាព និងយល់ច្បាស់លើខ្លឹមសារនៃប្រការនីមួយៗដែលមានចែងនៅក្នុងលក្ខន្តិកៈ។ បន្ទាប់មកទៀត ក្រុមការងារថ្នាក់ខេត្តបានរៀបចំសេចក្តីជូនដំណឹងមួយទៅកាន់ក្រុមការងារថ្នាក់ជាតិអំពី លទ្ធផល នៃការរៀបចំសេចក្តីព្រាងលក្ខន្តិកៈនេះ។ រីឯក្រុមការងារថ្នាក់ជាតិបានចុះទៅធ្វើការវាយតម្លៃលើកំរិតយល់ដឹងភាពជាម្ចាស់ និងការឯកភាពលើខ្លឹមសារនៃលក្ខន្តិកៈរបស់សមាជិកសហគមន៍ទាំងមូល ហើយពួកគាត់ត្រូវបង្ហាញអំពីលទ្ធផលនៃការវាយតម្លៃនេះទៅដល់សហគមន៍សាមុី និងក្រុមការងារថ្នាក់ខេត្ត។

បន្តមកទៀត សហគមន៍បានធ្វើការដឹកនាំ និងរៀបចំការប្រជុំពេញអង្គសហគមន៍មួយ ដោយមានការសម្របសម្រួល ពីអង្គការ **ឌីភីអេ_ខេត្តរតនគិរី** និងមានការចូលរួមពីសំណាក់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។ មានរបៀបវារៈចំនួនបី ដែលបានលើកយកមកពិនិត្យ និងអនុម័តដោយសមាជិកសហគមន៍ទាំងមូល ដែលក្នុងនោះរួមមាន :

- ការពិនិត្យ និងអនុម័តទៅលើសេចក្តីព្រាងលក្ខន្តិកៈសហគមន៍
- ការពិនិត្យ និងអនុម័តទៅលើសមាសភាគគណៈកម្មាធិការសហគមន៍ និង
- ការពិនិត្យ និងអនុម័តទៅលើសមាជិកភាពសហគមន៍។

### ឆ_ ការចុះបញ្ជីសហគមន៍ជានីតិបុគ្គល

ការចុះបញ្ជីសហគមន៍ជានីតិបុគ្គល គឺជាលក្ខខណ្ឌចាំបាច់ដើម្បីឱ្យសហគមន៍ជនជាតិដើមភាគតិចក្លាយជានីតិបុគ្គល ស្របច្បាប់ និងឈានទៅដល់ការស្នើសុំចុះបញ្ជីដីធ្លីសហគមន៍ជាសម្ងហភាពបាន។

បន្ទាប់ពីកិច្ចប្រជុំពេញអង្គដើម្បីអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈ និងសមាសភាពគណៈកម្មាធិការសហគមន៍រួចហើយ ក្រុមការងារថ្នាក់ខេត្តបានសម្របសម្រួលជាមួយនឹងគណៈកម្មាធិការសហគមន៍ ដើម្បីរៀបចំលិខិតស្នើសុំទទួលស្គាល់លើលក្ខន្តិកៈ និងសមាសភាពគណៈកម្មាធិការសហគមន៍ពីក្រុមប្រឹក្សាឃុំ។ នៅពេលដែលសហគមន៍ទទួលបានសេចក្តីសម្រេចទទួលស្គាល់លក្ខន្តិកៈ និងសមាសភាពគណៈកម្មាធិការសហគមន៍ពីក្រុមប្រឹក្សាឃុំរួចហើយ ក្រុមការងារថ្នាក់ខេត្តបានសម្របសម្រួលជាមួយនឹងប្រធានគណៈកម្មាធិការសហគមន៍ និងអង្គការគាំទ្រផ្សេងទៀត ដើម្បីរៀបចំបំពេញពាក្យស្នើសុំចុះបញ្ជីមកក្រសួងមហាផ្ទៃ តាមរយៈអាជ្ញាធរឃុំ-សង្កាត់ ស្រុក ខេត្ត។

ដោយមានការផ្តួចផ្តើម និងជួយជ្រោមជ្រែងពីអង្គការ **ឌីភីអេ** សហការជាមួយនឹងក្រុមការងារថ្នាក់ខេត្ត មន្ទីរគ្រប់ គ្រងដែនដី នគរូបនីយកម្ម និងសំណង់ និងដៃគូអភិបាលកិច្ចមូលដ្ឋាន (PLG - Partnership for Local Governance) ក្រសួងមហាផ្ទៃ ក៏បាន

យល់ព្រមចុះបញ្ជីសហគមន៍ជានីតិបុគ្គលជូនដល់សហគមន៍ជនជាតិដើមភាគតិចទំពួន ក្នុងភូមិឡាអិន នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០០៧។ សេចក្ដីប្រកាសជាសាធារណៈរបស់ក្រសួងមហាផ្ទៃត្រូវបានធ្វើឡើងនៅ ខែមេសា ឆ្នាំ២០០៧ ដោយមានការចូលរួមពីអភិបាលខេត្តរតនគិរី ប្រធានមន្ទីរពាក់ព័ន្ធ អាជ្ញាធរដែនដី តំណាងអង្គការ មិនមែនរដ្ឋាភិបាល និងអ្នកមុខអ្នកការជាច្រើន។

## ង. បទបញ្ជាផ្ទៃក្នុងសំរាប់បែងចែកការប្រើប្រាស់និងគ្រប់គ្រងដីធ្លី[៨]

ដើម្បីគ្រប់គ្រងសហគមន៍ និងការថែរក្សាអចលនវត្ថុសមូហភាពរបស់សហគមន៍ឱ្យមានប្រសិទ្ធភាពនិងដោយរលូន សហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល ត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងដោយមានការពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍។ ខ្លឹមសារនៃបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ ត្រូវតែអនុវត្តទៅតាមយន្តការនៃការធ្វើសេចក្ដីសម្រេចចិត្ត តាមទំនៀមទំលាប់ វប្បធម៌ ប្រពៃណី ស្របទៅតាមគោលនយោបាយ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ពង្រាងបទបញ្ជាផ្ទៃក្នុងសំរាប់បែងចែកការប្រើប្រាស់និងការគ្រប់គ្រងដីធ្លីសហគមន៍ ត្រូវបានផ្ដួចផ្ដើមឡើងដោយ គណៈកម្មាធិការសហគមន៍។ គណៈកម្មាធិការសហគមន៍បានរៀបចំការប្រជុំពិគ្រោះយោបល់អំពីពង្រាងបទបញ្ជាផ្ទៃក្នុង ជាមួយនឹងសមាជិកសហគមន៍ទាំងអស់ ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន ហើយសម្របសម្រួលដោយអង្គការ **ឌីភីអេ_ខេត្តរតនគិរី**

## ឈ. ការវាស់វែង ការកំណត់ព្រំដី ការវិនិច្ឆ័យ និងការវិភាគ (ព្រំប្រទល់ភូមិ)

នៅក្នុងអំឡុងពេលនេះ អង្គការ **ឌីភីអេ_ខេត្តរតនគិរី** បានសហការយ៉ាងជិតស្និទ្ធជាមួយនឹងស្ថាប័នជំនាញ និងពាក់ព័ន្ធទាំងឡាយ ដើម្បីហ្វឹកហាត់ការងារនិងកសាងសមត្ថភាពដល់គណៈកម្មាធិការសហគមន៍ និងតំណាងប្រជាសហគមន៍លើការរៀបចំឯកសារផ្លូវការសំរាប់ស្នើសុំចុះបញ្ជីដីធ្លីសហគមន៍ លើកកំពស់ការយល់ដឹងអំពីការធ្វើអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ការគូសផែនទីចំណាត់ថ្នាក់ដីរដ្ឋ និងដីសហគមន៍ជនជាតិដើមភាគតិច។

នៅក្នុងឆ្នាំ២០០៧ អ្នកភូមិឡាអិនបានរាយការណ៍ថា មិនមានការកើតឡើងនូវការដណ្ដើមដីធ្លីនៅក្នុងភូមិឡាអិនទេ។ ការទទួលបាននូវលទ្ធផលជាវិជ្ជមាននេះ អាចជាផ្នែកមួយនៃការទទួលស្គាល់សហគមន៍ជនជាតិដើមភាគតិចនៅភូមិឡាអិន ជានីតិបុគ្គលស្របច្បាប់។ ព័ត៌មានទាំងអស់នេះ យើងបានធ្វើការផ្សព្វផ្សាយទៅដល់សហគមន៍ អាជ្ញាធរមូលដ្ឋាន ហើយនិងមន្ទីរពាក់ព័ន្ធទាំងអស់ ដើម្បីជ្រាបជាព័ត៌មានផងដែរ។ អាស្រ័យហេតុនេះ ជាលទ្ធផល សហគមន៍អ្នកជិតខាង និងអ្នកខាងក្រៅដឹងថា ពួកគេមិនអាចរំលោភបំពានទៅលើព្រំប្រទល់ភូមិបានទេ ប្រសិនបើគ្មានបទអន្តរាគមន៍ពីអាជ្ញាធរនោះ។ មួយវិញទៀត មន្ត្រីមកពីក្រសួងមហាផ្ទៃ និងក្រសួង

[៨] សូមមើលឧបសម្ព័ន្ធទី៣ : បទបញ្ជាផ្ទៃក្នុង ការគ្រប់គ្រងដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចទំពួន ភូមិឡាអិន

រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ធ្លាប់បានធ្វើទស្សនកិច្ចនៅភូមិឡាអិន និងជំរុញ ក៏ដូចជាលើកទឹកចិត្តអោយអាជ្ញាធរមូលដ្ឋានធ្វើការអះអាងថា អ្នកភូមិទាំងអស់គ្នាសុទ្ធតែបានដឹងថា ភូមិរបស់ពួកគេនឹងទទួលបាននូវប័ណ្ណកម្មសិទ្ធិ កាន់កាប់ដីធ្លីជាសម្ហាភាពនៅពេលខាងមុខនេះ ហើយដែលតំរូវអោយអ្នកទាំងអស់គ្នាត្រូវតែគោរព។ ដោយឡែក ដំណើរការនៃការចុះបញ្ជីដីធ្លីនេះ ក៏បានអប់រំប្រជាពលរដ្ឋទាំងក្នុង និងខាងក្រៅភូមិឡាអិនទាំងអស់ អំពីសារៈសំខាន់នៃការចុះបញ្ជីដីធ្លី ហើយចំណេះដឹងទាំងនេះ ដែលអាចជាផ្នែកមួយ ដើម្បីចូលរួមចំណែកផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់ពួកគេ។

តាមរយៈព័ត៌មាន ដែលទទួលបានពីអ្នកភូមិ បានអោយដឹងថា នៅក្នុងអំឡុងពេលនៃការកំណត់ព្រំប្រទល់នៅភូមិនោះ គឺមានការកើតឡើងនូវការមិនយល់ស្របគ្នាជាមួយនឹងអ្នកភូមិជិតខាងដូចជាភូមិត្រពាំងច្រេស៤ ឃុំត្រពាំងច្រេស និងភូមិតាកែប ឃុំតាអង។ ហេតុនេះ ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើនេះ **ឌីតីអេ_រតនគីរី** បានរៀបចំកិច្ចប្រជុំមួយ ដើម្បីពិភាក្សាស្វែងរកនូវកិច្ចព្រមព្រៀងរួមគ្នាមួយទៅលើព្រំប្រទល់ភូមិ។ ជាលទ្ធផល អ្នកចូលរួមទាំងអស់បានយល់ស្រប និងអនុម័តលើព្រំប្រទល់ដែលបានរៀបចំហើយនោះ។

◊ **ការធ្វើអត្តសញ្ញាណកម្ម និងពិនិត្យឡើងវិញទៅលើព្រំប្រទល់ភូមិឡាអិន ៖**

នៅក្នុងឆ្នាំ២០០៩ ដោយមានការសហការយ៉ាងជិតស្និទ្ធិជាមួយនឹងអង្គការពាក់ព័ន្ធ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរតនគីរី **ឌីតីអេ_រតនគីរី** បានរៀបចំកិច្ចប្រជុំដំបូងមួយនៅថ្នាក់ខេត្ត ដើម្បីធ្វើការពិនិត្យឡើងវិញ ក៏ដូចជាធ្វើអត្តសញ្ញាណកម្មព្រំប្រទល់ភូមិឡាអិន ដោយមានអ្នកចូលរួមចំនួន៤២នាក់ (ស្រី១៣នាក់)។ កិច្ចពិភាក្សានាពេលនេះ គឺផ្តោតសំខាន់ទៅលើអត្ថន័យថាអ្វីទៅជាដីរដ្ឋ ដីសាធារណៈរដ្ឋ និងដីឯកជនរបស់រដ្ឋ ក៏ដូចជា បង្ហាញអំពីរបៀបនៃការធ្វើគំនូសផែនទីភូមិឡាអិន សំរាប់ដាក់ស្នើសុំចុះបញ្ជីជាផ្លូវការ។

ដោយឡែកនៅខែមីនា ឆ្នាំ២០០៩ **ឌីតីអេ_រតនគីរី** បានរៀបចំកិច្ចប្រជុំចុងក្រោយមួយ ស្តីពីការពិនិត្យព្រំប្រទល់ភូមិឡាអិន ឡើងវិញ។ នៅក្នុងកិច្ចប្រជុំនោះមានអ្នកចូលរួមទាំងអស់ចំនួន ២០នាក់ (ស្រី៤នាក់) ដែលជាអ្នកពាក់ព័ន្ធនៅក្នុងកិច្ចពិភាក្សានេះ។ ទោះបីជាយ៉ាងណាក៏ដោយ យើងឃើញថាមានអ្នកចូលរួមចំនួន ១៦នាក់ ប៉ុណ្ណោះ ដែលបានចូលរួមយ៉ាងសកម្ម និងយល់ពីខ្លឹមសារនៃកិច្ចប្រជុំនេះច្បាស់។ តាមរយៈកិច្ចប្រជុំនេះ អ្នកចូលរួមទាំងអស់ បានធ្វើការគាំទ្រលើការបញ្ចប់នូវការកំណត់ព្រំប្រទល់ភូមិឡាអិន។ អ្នកចូលរួម បានចែករំលែកលទ្ធផល នៃកិច្ចប្រជុំទៅអ្នកភូមិដទៃទៀតនៅក្នុងសហគមន៍របស់ខ្លួន ក៏ដូចជាពន្យល់ពួកគេអំពីទំហំដីស្របច្បាប់ ដែលសហគមន៍ភូមិឡាអិនធ្វើការស្នើសុំចុះបញ្ជីបាននៅពេលអនាគត។ ទន្ទឹមនឹងនេះ យើងឃើញថាសមាជិកសហគមន៍ភាគច្រើន មានការយល់ដឹងច្រើនទៅលើវិសាលភាពនៃទំហំដីភូមិរបស់ខ្លួន ក៏ដូចជាយល់ថាដីណាជាដីរដ្ឋ ដីសាធារណៈរបស់រដ្ឋ និងដីណាជាដីសហគមន៍ជនជាតិដើមភាគតិច។

◊ **ការបញ្ជាក់ពីការប្រើប្រាស់ដីនៅកំរិតឃុំ :**

នៅក្នុងឆ្នាំ២០០៩ ដោយមានការសហការយ៉ាងជិតស្និទ្ធិជាមួយនឹងមន្ត្រីមកពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត **ឌីភីអេ-រតនគីរី** បានធ្វើការគាំទ្រ និងសំរបសំរួលសហគមន៍ក្នុងការរៀបចំកិច្ចប្រជុំមួយ ដើម្បីបញ្ជាក់ពីទំហំនៃការប្រើប្រាស់ដីនៅភូមិឡាអិន ដោយរួមបញ្ចូលទាំងដីរដ្ឋ និងដីសហគមន៍នៅកំរិតឃុំ ដោយមានអ្នកចូលរួមចំនួន០៩នាក់ ដែលសុទ្ធសឹងជាអ្នកភូមិឡាអិន។ គោលបំណងសំខាន់នៃការរៀបចំកិច្ចប្រជុំនេះ គឺដើម្បីបង្ហាញអំពីនីតិវិធីនៃការប្រើប្រាស់សដីរដ្ឋ និងដីសហគមន៍។ ការកំណត់ទំហំដីភូមិ ឡាអិន ត្រូវបានធ្វើឡើង តាមរយៈការប្រើប្រាស់ឧបករណ៍ ជីភីអេស និងយូធីអឹម (UTM)។ ហេតុនេះអ្នកចូលរួមទាំងអស់ ត្រូវបានគេ បង្រៀនអំពីរបៀបនៃការប្រើប្រាស់ ជីភីអេស(GPS) និងការកំណត់យូធីអឹម(UTM)។ ជាលទ្ធផលពួកគាត់មានការយល់ដឹងច្រើនអំពីរបៀបប្រើប្រាស់ ជីភីអេស និងយូធីអឹមនេះ។

◊ **សំរបសំរួលសហគមន៍នៅក្នុងដំណើរការនៃការកំណត់អត្តសញ្ញាណកម្មដីរដ្ឋ :**

នៅក្នុងឆ្នាំ២០០៩ **ឌីភីអេ-រតនគីរី** បានជួយសំរបសំរួលសហគមន៍ភូមិឡាអិន នៅក្នុងការរៀបចំកិច្ចប្រជុំមួយ ដើម្បី-ពិភាក្សាអំពី ការកំណត់អត្តសញ្ញាណកម្មដីរដ្ឋនៅក្នុងសហគមន៍ ដោយមានចូលរួមចំនួន ០៦នាក់ (បុគ្គលិកឌីភីអេ-រតនគីរី ២នាក់ , មន្ត្រីមកពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណត់ និងសុរិយោដីខេត្តរតនគីរី ២នាក់ និងអ្នកភូមិឡាអិន ចំនួន ២នាក់)។ នៅក្នុងកិច្ចប្រជុំ មន្ត្រីជំនាញបានពន្យល់ដល់អ្នកចូលរួមទាំងអស់ពីនីតិវិធីនៅក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ, ដីឯកជនរបស់រដ្ឋ ដីសាធារណៈរបស់រដ្ឋ នៅក្នុងដែនដីរបស់ភូមិឡាអិន។ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរតនគីរី គឺជាអ្នករៀបចំធ្វើផែនទីភូមិឡាអិន។ ផែនទីផ្លូវការនេះ ត្រូវបានធ្វើរួចរាល់នៅដើមឆ្នាំ ២០១០។ ដោយឡែក **ឌីភីអេ-រតនគីរី** បានធ្វើការសហការជាមួយនឹងសហគមន៍នៅភូមិឡាអិន និងអ្នកភូមិជិតខាងឡាអិន នៅក្នុងការរៀបចំដាក់តាំងបង្ហាញនូវគំនូសផែនទីភូមិឡាអិន ជាសាធារណៈ។ ការបិតផ្សាយជាសាធារណៈនេះ ត្រូវបានធ្វើឡើងរយៈពេល១ខែ ដើម្បីអាចអោយសហគមន៍ជិតខាង និងសមាជិកភូមិ អាចធ្វើការតវ៉ាទៅតំណាងគណៈកម្មាធិការសហគមន៍ នៅក្នុងករណីដែលមានការត្រួតស៊ីគ្នាទៅនឹងព្រំប្រទល់ភូមិជិតខាង ដីឯកជន ដីរដ្ឋ ឬ ដីសាធារណៈរបស់រដ្ឋ ដោយយោងទៅតាមគំនូសផែនទីនេះ។

◊ **រៀបចំវគ្គបណ្តុះបណ្តាលស្តីពី នីតិវិធីនៃការស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចនៅថ្នាក់ខេត្ត :**

ជាការចូលរួមចំណែកជំរុញអោយដំណើរការ នៃការចុះបញ្ជីដីសំរាប់សហគមន៍ជនជាតិដើមភាគតិចមានលក្ខណៈកាន់តែប្រសើរនោះ **ឌីភីអេ-រតនគីរី** បានរៀបចំវគ្គបណ្តុះបណ្តាលមួយស្តីពី នីតិវិធីនៃការស្នើសុំចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចនៅថ្នាក់ខេត្ត ដោយមានអ្នកចូលរួមចំនួន១៧នាក់ (២នាក់) ដែលមកពីភូមិឡាអិន។ ជាលទ្ធផល យើងឃើញថា មានអ្នកចូលរួមចំនួន១៣នាក់ បានយល់ច្បាស់អំពីនីតិវិធី និងដំណើរការនៃការស្នើសុំចុះបញ្ជីដីសហគមន៍ ជនជាតិដើមភាគតិច។ មួយវិញទៀត អ្នកចូលរួមទាំងអស់បានចូលរួមយ៉ាងសកម្មនៅក្នុងការស្នើសុំចុះបញ្ជីដីនេះ ដើម្បីធ្វើអោយប្រាកដថាសហគមន៍របស់ពួក

គេ នឹងអាចទទួលបាននូវប័ណ្ណកម្មសិទ្ធិដីធ្លីស្របច្បាប់ពីរាជរដ្ឋាភិបាល ។ តាមរយៈការសំភាសន៍ជាមួយនឹងពួកគាត់ យើងឃើញថា ៦៥ភាគរយនៃអ្នកចូលរួមពួកគាត់មានសមត្ថភាពគ្រប់ គ្រាន់ចូលរួមក្នុងដំណើរការនៃការស្នើសុំចុះបញ្ជីដីនេះដូចជា ការប្រើប្រាស់ឧបករណ៍យូធីអឹម ការពង្រាងលក្ខន្តិកៈ ការដោះស្រាយទំនាស់ និងផ្សព្វផ្សាយចំនេះដឹងផ្សេងៗទាក់ទងនឹងច្បាប់ស្តីពីភូមិបាលទៅដល់អ្នកភូមិផ្សេងៗទៀតផងដែរ ។

◊ **សំរបសំរួលសហគមន៍នៅក្នុងការរៀបចំកិច្ចប្រជុំរយៈពេលមួយថ្ងៃស្តីពីការធ្វើចំណាត់ថ្នាក់គំនូសផែនទីដីរដ្ឋនៃដីសហគមន៍ភូមិឡាអិននៅថ្នាក់ឃុំ ៖**

នៅពាក់កណ្តាលឆ្នាំ២០១០ **ឌីភីអេ_រតនគិរី** បានគាំទ្រមន្ត្រីមកពីមន្ទីររៀបចំ នគរូបនីយកម្ម និងសំណង់ ខេត្តរតនគិរី នៅក្នុងការរៀបចំដាក់តាំងបង្ហាញគំនូសផែនទីភូមិឡាអិន ដែលការដាក់បង្ហាញនេះ មានរយៈពេល១ខែ ។ គោលបំណងនៃការដាក់បង្ហាញគំនូសផែនទីនេះ គឺដើម្បីអញ្ជើញអ្នកភូមិឡាអិន និងអ្នកភូមិជិតខាងភូមិឡាអិនទាំងអស់ ធ្វើការពិនិត្យឡើងវិញ និងផ្តល់ជាមតិយោបល់ផ្សេងៗទៅលើគំនូសផែនទីនេះ ដែលមានបញ្ចូលទាំងដីសហគមន៍ ដីរដ្ឋ ដីបំរុងទុក ដីកប់ខ្មោច ដីឯកជនរបស់រដ្ឋ និងដីលំនៅដ្ឋានដែលគ្រប់គ្រងដោយភូមិឡាអិន ។ ជាលទ្ធផល នៅក្នុងរយៈពេលមួយខែនេះ មិនមានជំលោះ រឺ ប្តឹងតវ៉ាទៅលើទិន្នន័យ និងគំនូសផែនទីនោះទេ ។ ទាំងអ្នកភូមិឡាអិន និងភូមិជិតខាង បានធ្វើការឯកភាព និងទទួលស្គាល់លើគំនូសផែនទីនេះ ។

◊ **ផ្សព្វផ្សាយគំនូសផែនទីភូមិឡាអិនទៅកាន់អ្នកពាក់ព័ន្ធ ៖**

នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១០ **ឌីភីអេ_រតនគិរី** បានសំរបសំរួលអ្នកភូមិ៤នាក់មកពីឃុំតឺន ដែលក្នុងនោះ ២ នាក់ ជាសមាជិកគណៈកម្មាធិការដីធ្លី មេភូមិ និងមេឃុំតឺន ដើម្បីចូលរួមកិច្ចប្រជុំផ្សព្វផ្សាយគំនូសផែនទីដីរដ្ឋ និងដីសហគមន៍ជនជាតិដើមភាគតិច នៅភូមិឡាអិនទៅកាន់អ្នកពាក់ព័ន្ធនៅថ្នាក់ស្រុក ។ បន្ទាប់មកទៀត នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១០ **ឌីភីអេ_រតនគិរី** បានរៀបចំកិច្ចប្រជុំរយៈពេលមួយថ្ងៃ ដើម្បីធ្វើការផ្សព្វផ្សាយគំនូសផែនទីដីរដ្ឋ និងដីសហគមន៍ភូមិឡាអិន ដែលមានអ្នកភូមិចូលរួមទាំងអស់ចំនួន ៥៥ នាក់ ។ គោលបំណងនៃការរៀបចំកិច្ចប្រជុំនេះ គឺដើម្បីបង្ហាញទៅដល់អ្នកភូមិទាំងអស់ដែលបានចូលរួមអំពីទំហំផ្ទៃដី ដែលបញ្ជាក់យ៉ាងច្បាស់អំពីដីរដ្ឋ ដែលមានទីតាំងស្ថិតនៅក្នុងភូមិឡាអិន ក៏ដូចជាដើម្បីបង្ហាញពួកគេអំពីទំហំដីឯកជនរបស់រដ្ឋ ដីបំរុងទុក និងដីព្រៃឈើជាដើម ។ បន្ថែមពីលើនេះទៀត កិច្ចប្រជុំនេះមានគោលបំណងសំខាន់ គឺដើម្បីបង្ហាញ និងជូនដំណឹងដល់អ្នកភូមិគោលដៅទាំងអស់ថា ចាប់ពេលនេះវានឹងលែងមានការទន្ទ្រានកាន់កាប់ រឺ រំលោភដីធ្លីពីសំណាក់អ្នកខាងក្រៅ រឺក៏អ្នកភូមិគ្នាឯង ដែលរស់នៅក្នុងភូមិឡាអិនបន្តទៅទៀតហើយ ។ នៅចុងបញ្ចប់នៃកិច្ចប្រជុំ បុគ្គលិក **ឌីភីអេ_រតនគិរី** និងមន្ត្រីជំនាញមកពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត បានសង្កេតឃើញថា អ្នកភូមិទាំងអស់ ដែលបានមកចូលរួមបានចូលរួមយ៉ាងសស្រាក់សស្រាំតាមរយៈការលើកជាសំណួរ និងកង្វល់ផ្សេងៗរបស់ពួកគេទាក់ទិនទៅនឹងបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងការអនុវត្តគំរោងចុះបញ្ជីដីធ្លីនេះ ជាពិសេសនៅពេលដែលពួកគេអាចទទួលបាន

នូវប័ណ្ណកម្មសិទ្ធិស្របច្បាប់ក្នុងការកាន់កាប់ដីធ្លីនាពេលអនាគតពីរាជរដ្ឋាភិបាល។ យោងតាមការប៉ាន់ប្រមាណរបស់អ្នក សំរបសំរួល ឃើញថាយ៉ោងហោចណាស់ ៧០ ភាគរយនៃអ្នកភូមិទាំងអស់ដែលបានមកចូលរួម គឺមានការយល់ដឹងច្បាស់លាស់ទៅលើដីណាដែលជាដីរដ្ឋ និងដីណាដែលជាដីសហគមន៍ ហើយពួកគេក៏មានការយល់ច្រើនលើគំនូសផែនទីភូមិឡាអិន ដែលរៀបចំដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ផងដែរ។

◊ **ការធ្វើអត្តសញ្ញាណកម្មព្រំប្រទល់ភូមិឡាអិន និងគំនូសផែនទីភូមិនៅថ្នាក់ខេត្ត ៖**

ចាប់ពីខែមីនា ដល់ខែមេសា ឆ្នាំ២០១០ អ្នកភូមិឡាអិនចំនួន១៧៦នាក់ (ស្ត្រី ៧៦នាក់) បានសហការជាមួយនឹងមន្ត្រីជំនាញចំនួនពីរនាក់មកពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ធ្វើការបោះបង្គោលចំនួន ២៧៦ នៅតាមព្រំប្រទល់ភូមិ។ អ្នកភូមិឡាអិនទាំងអស់ គឺបានចូលរួមយ៉ាងសកម្មក្នុងការសហការជាមួយនឹងមន្ត្រីជំនាញដើម្បីកំណត់ទីកន្លែង រឺ កំណត់ព្រំសីមាដែនដីរបស់ពួកគេ ក៏ដូចជាធ្វើការចរចារជាមួយនឹងអ្នកភូមិផ្សេងៗទៀត ស្វែងរកនូវកិច្ចព្រមព្រៀងជាមួយគ្នានៅមុនពេលដែលពួកគេចាប់ផ្តើមបោះបង្គោល។ ជាសរុបមក អ្នកភូមិ ទាំង១៧៦នាក់ ដែលបានចូលរួមនេះ គឺបានចូលរួមយ៉ាងសកម្មនៅក្នុងការកំណត់ព្រំប្រទល់ភូមិ និងបោះបង្គោលព្រំ តាមរយៈការការប្រើប្រាស់ យូធីអឹម (UTM)។ មន្ត្រីជំនាញមកពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត បានធ្វើការវាស់វែងដោយប្រើប្រាស់នូវឧបករណ៍ យូធីអឹម (UTM) និងកំណត់ឡើងដោយសហគមន៍ ដែលសកម្មភាពនេះត្រូវបានធ្វើឡើងមានរយៈពេល ០២ខែ (មករា-កុម្ភៈ)។ លទ្ធផលនៃការវាស់វែងនេះ ត្រូវបានប្រើប្រាស់សំរាប់ចុះបញ្ជី និងផ្តល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីដល់សហគមន៍ជនជាតិដើមភាគតិចទំពួននៅភូមិឡាអិន។ ឆ្លើយតបទៅនឹងកត្តានេះ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត បានរៀបចំកិច្ចប្រជុំពិសេសមួយនៅក្នុងខែសីហា ឆ្នាំ២០១០ ជាមួយនឹងសហគមន៍ឡាអិន ដើម្បីបញ្ជាក់ជាលើកចុងក្រោយទៅលើព្រំប្រទល់ក្បាលដីនីមួយៗ ដែលគ្រប់គ្រងដោយសហគមន៍ឡាអិន នៅមុនពេលផ្តល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីដល់ពួកគាត់។

◊ **សំរបសំរួលសហគមន៍ឡាអិន នៅក្នុងការស្នើសុំទទួលប័ណ្ណកម្មសិទ្ធិស្របច្បាប់នៅក្នុងការកាន់កាប់ដីធ្លី និងរៀបចំផែនការអភិវឌ្ឍន៍រយៈពេលវែងនៅថ្នាក់ខេត្ត ៖**

ពីថ្ងៃទី០៧ ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ **ឌីភីអេ-រតនគិរី** បានសហការជាមួយនឹងមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីធ្វើការពិនិត្យព្រំប្រទល់ភូមិឡាអិនឡើងវិញ ជាមួយនឹងសហគមន៍គោលដៅ ដែលបច្ចុប្បន្នពួកគេមានដីចំការស្ថិតនៅក្នុងភូមិឡាអិន។ គោលបំណងនៃការពិនិត្យឡើងវិញនេះ គឺដើម្បីធ្វើអោយប្រាកដថា អ្នកភូមិទាំងអស់ឯកភាព និងយល់ព្រមលើព្រំប្រទល់ក្បាលដី ដែលរំលេចឡើងនៅលើផែនទីភូមិឡាអិន ដោយមិនមានការតវ៉ា រឺ មិនយល់ស្របទៅនឹងព្រំប្រទល់ក្បាលដីនេះ នៅមុនពេលដាក់ស្នើសុំចុះបញ្ជី និងផ្តល់ប័ណ្ណកម្មសិទ្ធិកាន់កាប់ដីធ្លីអោយទៅសហគមន៍។ នៅកិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីមន្ត្រីមកពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត ចំនួន៣នាក់ សមាជិកគណៈ

កម្មាធិការដីធ្លីចំនួន៣ នាក់ និងតំណាងសហគមន៍ចំនួន៥នាក់។ ជាលទ្ធផល ក្បាលដីចំការចំនួន ៣៧ ត្រូវបានធ្វើការផ្តល់បន្ថែម និងពិនិត្យឡើងវិញ។

## ៣.៤ ការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី



នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ **ឌីភីអេ-រតនគិរី** បានសហការយ៉ាងជិតស្និទ្ធិជាមួយនឹងមន្ត្រីមកពីមន្ទីរ និង ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីថ្នាក់ខេត្ត និងថ្នាក់ស្រុក រៀបចំពិធីប្រគល់វិញ្ញាបនបត្រទទួលស្គាល់កម្មសិទ្ធិសមូហភាព របស់សហគមន៍ជនជាតិដើមភាគតិចនៅភូមិឡាអិន និងភូមិឡាអឺនក្រៃន។ ពិធីទទួលស្គាល់នេះត្រូវបានរៀបចំធ្វើឡើងនៅភូមិឡាអឺនក្រៃង ឃុំអូរជុំ ស្រុកអូរជុំ ខេត្តរតនគិរី ដែលមានអ្នកចូលរួមសរុបទាំងអស់ចំនួន ៣៥០ នាក់ ដែលក្នុងនោះ ៣១នាក់ (ស្រី១០នាក់) មកពីភូមិឡាអិន។ នៅក្នុងឱកាសដ៏វិសេសវិសាលនេះ **ឯកឧត្តម ប៉ាវ ហាមផាន** អភិបាលខេត្តរតនគិរី បានលើកឡើងអំពីប្រវត្តិ និងសមិទ្ធិផលទាំងឡាយដែលបានទទួលនៅក្នុងអំឡុងពេលនៃការអនុវត្តការចុះបញ្ជីដីសំរាប់សហ-គមន៍ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនគិរី នេះ។ ស្របពេលជាមួយគ្នានេះដែរ នាយកប្រតិបត្តិអង្គការ ឌីភីអេ និងតំណាងអង្គការជីអាយហ្ស៊ិត (GIZ) ក៏បានអញ្ជើញចូលរួមថ្លែងមតិយោបល់ពីកិច្ចសហការយ៉ាងជិតស្និទ្ធរវាងគ្នានឹងគ្នានៅក្នុងដំណើរការការងារដ៏យូរអង្វែងមួយ ដើម្បីគាំទ្រសហគមន៍ នៅឡាអិន និងឡាអឺនក្រៃង នៅមុនពេលប្រគល់តួនាទីជូនដល់ **ឯកឧត្តម ទេសរដ្ឋមន្ត្រី អ៊ឹម ឈុនលឹម** រដ្ឋមន្ត្រីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ថ្លែងចំណាប់អារម្មណ៍។

ជាលទ្ធផលតាមរយៈការទទួលបាននេះ សហគមន៍ជនជាតិដើមភាគតិច នឹងមានសិទ្ធិស្របច្បាប់ក្នុងការការពារដីធ្លីរបស់ពួកគេពីការរំលោភបំពាន និងការដណ្តើមដីធ្លីដោយខុសច្បាប់ពីសំណាក់អ្នកកេងប្រវ័ញ្ចដី និងឈ្មួញកណ្តាលមួយចំនួន។ សហគមន៍ឡាអិន មាន ១២៩ គ្រួសារ ដែលក្នុងនោះមានប្រជាជនសរុបចំនួន ៦៣៨នាក់ (ស្រី៣១៧នាក់) បានទទួលដីកាន់កាប់ស្របច្បាប់ចំនួន ១,២១៨.៥៦ ហិចតា រួមបញ្ចូលទាំង ដីលំនៅដ្ឋានមានចំនួន ១១.៨០ ហិចតា , ដីបំរុងទុកមានចំនួន ៧៣៥.៧៩ហិចតា , ដីស្រែមានចំនួន ៣៣.២៤ហិចតា , ដីចំការមានចំនួន ៤២៥.១១ ហិចតា , ដីអារក្សមានចំនួន ៧ ហិចតា , ដីកប់ខ្មោចមានចំនួន ៣.៣១ ហិចតា និងដីទុកសំរាប់សាងសង់សាលារៀនមានចំនួន ២.៣១ ហិចតា។

ជាក់ស្តែង សហគមន៍នៅភូមិឡាអិន មានការសាទរយ៉ាងខ្លាំងចំពោះលទ្ធផល និងទទួលបានទូវប័ណ្ណកម្មសិទ្ធិស្របច្បាប់បែបនេះ។ នេះ គឺជាផ្នែកមួយដែលបញ្ជាក់ពីការខិតខំប្រឹងប្រែងរបស់សហគមន៍ ដើម្បីអភិវឌ្ឍន៍សហគមន៍របស់ពួកគេអោយរីកចំរើន ជា

ពិសេសអាចការពារប្រើប្រាស់ និងថែរក្សាដីសំរាប់កូនចៅជំនាន់ក្រោយ ។

តាមរយៈបទពិសោធន៍រៀនសូត្រនេះ យើងសង្កេតឃើញថា ការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិចធ្វើឡើង គឺផ្អែកទៅលើលទ្ធផលដែលមានស្រាប់ពីការធ្វើផែនការនៃការប្រើប្រាស់ដីធ្លីដោយមានការចូលរួម (PLUP)។ យើងអាចទទួលយកបានថាលទ្ធផលនៃការធ្វើផែនការនៃការប្រើប្រាស់ដីធ្លីដោយមានការចូលរួមក្នុងភូមិឡាអិន គឺបានមកពីការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេសគឺខាងរដ្ឋបាលព្រៃឈើ។ ពីដំបូងដោយសារមិនមានការចូលរួមពីសំណាក់ផ្នែករដ្ឋបាលព្រៃឈើ បានធ្វើឱ្យមានការត្រួតស៊ីគ្នានៃព្រំប្រទល់ក្បាលដីព្រៃប្រមាណ ៤.០០០ហិចតា នៅក្នុងភូមិឡាអិននៃខេត្តរតនគិរី ដែលការកំណត់ព្រំប្រទល់ក្បាលដីនៅក្នុងភូមិនេះមិនអាចយកជាការបានទេ ហើយវាតម្រូវឱ្យធ្វើការអនុវត្តជាថ្មីឡើងវិញ។ កត្តានេះ ជាហេតុធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការរៀបចំនិងកំណត់ព្រំប្រទល់ភូមិ និងការគូសផែនទី ដែលយើងត្រូវចំណាយពេលអស់រយៈពេលជាងមួយឆ្នាំ។

ដោយមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ជាលទ្ធផល គឺមិនមានជម្លោះលើការត្រួតស៊ីគ្នានៃព្រំខណ្ឌសីមា ដែលបានកំណត់រវាងដីរដ្ឋ និងដីសហគមន៍នោះឡើយ ។

ទន្ទឹមនឹងនេះ ដំណើរការនិងនីតិវិធីនៃការចុះបញ្ជីដីធ្លីសហគមន៍នេះមានចែងលំអិតនៅក្នុងជំពូកទី២ ស្តីពីគោលការណ៍នៃការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច ជំពូកទី៣ស្តីពី ដីដែលត្រូវចុះបញ្ជីជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច និងជំពូកទី៤ស្តីពី នីតិវិធី និងយន្តការនៃការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិចនៃអនុក្រឹត្យលេខ ៨៣ អនក្រ.បក ស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីសហគមន៍សហគមន៍ជនជាតិដើមភាគតិច ។

## ២. បញ្ហាប្រឈម

*តើអ្វីខ្លះដែលជាការប្រឈម ឬ ការលំបាកដែលបានពេបប្រទះក្នុងអំឡុងពេលអនុវត្តគំរោងចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច?*

ឆ្លងតាមបទពិសោធន៍និងការសិក្សាស្រាវជ្រាវកន្លងមក យើងបានរកឃើញការប្រឈមដូចខាងក្រោម ៖

### ២.១- ការប្រឈមរបស់សហគមន៍ជនជាតិដើមភាគតិច

- គណៈកម្មាធិការ និងសមាជិកសហគមន៍ភាគច្រើនមិនចេះអក្សរ
- គណៈកម្មាធិការពុំមានជំនាញគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ដឹកនាំ និងអភិវឌ្ឍន៍សហគមន៍
- ប្រជាសហគមន៍មានការយល់ដឹងតិចតួចទាក់ទងទៅនឹងច្បាប់ និងដំណើរការនៃការចុះបញ្ជីដីធ្លី
- ប្រជាសហគមន៍មួយចំនួនមិនទាន់មានការយល់ច្បាស់អំពីគោលបំណងនៃការចុះបញ្ជីដីធ្លី
- ការចូលកាន់កាប់ដីធ្លីរបស់សហគមន៍ពីអ្នកខាងក្រៅនៅតែមានជាបន្ត
- ជីវភាពរស់នៅពឹងផ្អែកទាំងស្រុងទៅនឹងធនធានធម្មជាតិ

- អ្នកភូមិ ពិសេសបងប្អូនជនជាតិដើមភាគតិចមួយចំនួនតូចបានបន្តលក់ដីរបស់ខ្លួនទៀត ហើយមិនមានជំនឿចិត្ត និងខ្វះការគាំទ្ររបស់ខ្លួនលើគំរោង ក៏ដូចជាក្រុមការងារនៃគំរោង

## ២.២- ការប្រឈមរបស់ក្រុមការងារសម្របសម្រួលក្នុងការចុះបញ្ជីដីធ្លីសហគមន៍ជនជាតិដើមភាគតិច ខេត្តរតនគិរី

- ការពិនិត្យព្រំប្រទល់រដ្ឋបាលឃុំ និងការកសាងគំនូសព្រាងផែនទីប្រើប្រាស់ដីភូមិ-ឃុំ។ សហគមន៍ជនជាតិដើមភាគតិចមានការយល់ដឹងតិចតួចណាស់ទាក់ទងទៅនឹងច្បាប់ និងដំណើរការនៃការចុះបញ្ជីនេះ ទោះបីជាកន្លងមក យើងបានខិតខំកសាងសមត្ថភាពដល់ពួកគាត់យ៉ាងណាក៏ដោយ។ កត្តានេះ បានធ្វើឱ្យជនខិលខូចមួយចំនួន បានឆ្លៀតឱកាសប្រើប្រាស់នូវគ្រប់រូបភាព ដើម្បីព្រុះព្រុង និងទាក់ទាញឱ្យសហគមន៍លក់ដីរបស់ខ្លួន។ ដោយសារតែបញ្ហានេះ អ្នកភូមិ ជាពិសេសបងប្អូនជនជាតិដើមភាគតិចមួយចំនួនតូច បានបន្តលក់ដីរបស់ពួកគាត់ ដែលបញ្ហានេះនាំមកនូវការបាត់បង់ជំនឿចិត្ត និងការគាំទ្ររបស់ខ្លួនមកលើគំរោង ក៏ដូចជាទៅលើក្រុមការងារនៃគំរោងផងដែរ។ ទន្ទឹមនឹងនេះ វាក៏ធ្វើឱ្យមានផលប៉ះពាល់ទៅដល់ការងាររៀបចំវាស់វែង និងការកសាងគំនូសព្រាងផែនទីប្រើប្រាស់ដីភូមិ-ឃុំ ដែលក្រុមការងារត្រូវចំណាយពេលវេលាយ៉ាងយូរ ដើម្បីចុះទៅរៀបចំវាស់វែង និងកសាងគំនូសព្រាងផែនទីសារជាថ្មីឡើងវិញ មុននឹងបញ្ជូនទៅក្រសួងមហាផ្ទៃដើម្បីសុំការទទួលស្គាល់។
- ការរៀបចំបទបញ្ជាផ្ទៃក្នុងសំរាប់សហគមន៍ គឺជួបការលំបាកមែនទែន ដោយក្រុមការងារសម្របសម្រួល ក៏ដូចជាអង្គការ **ឌីភីអេ** ដែរ គឺត្រូវការចំណាយពេលវេលាយ៉ាងយូរក្នុងការរៀបចំ និងបង្ហាត់បង្ហាញឱ្យពួកគាត់យល់អំពីខ្លឹមសារ និងប្រការសំខាន់ៗដែលត្រូវចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង ដែលសមាជិកសហគមន៍ទាំងអស់ត្រូវគោរព និងអនុវត្តតាម។ ប៉ុន្តែទន្ទឹមនឹងការរៀបចំនេះ គឺមានសមាជិកសហគមន៍មួយចំនួននៅតែបន្តលក់ដី របស់ខ្លួនជាបន្តបន្ទាប់ទៀត ដែលជាហេតុធ្វើឱ្យពួកគាត់ត្រូវបានគេកាត់ចេញពីសមាជិកភាពរបស់សហគម៏។ កត្តានេះ ធ្វើឱ្យក្រុមការងារសម្របសម្រួលមានការលំបាកយ៉ាងខ្លាំង ក្នុងការពន្យល់ឱ្យពួកគាត់ទាំងអស់គ្នាយល់ អំពីអ្វីដែលហៅថាកម្មសិទ្ធិសមូហភាព។
- ការផ្លាស់ប្តូរសមាជិកគណៈកម្មាធិការសហគមន៍ ឬអាជ្ញាធរប្រពៃណី។
- ការចំណាយពេលវេលាយូរក្នុងការរៀបចំទម្រង់លិខិត និងសំណុំបែបបទ ដែលពាក់ព័ន្ធទៅនឹងដំណើរការនៃការចុះបញ្ជីដីធ្លីជាសមូហភាពសំរាប់សហគមន៍ជនជាតិដើមភាគតិច។
- ស្ថាប័ននីមួយៗមានទម្រង់ និងសំណុំបែបបទផ្សេងៗគ្នា ដែលធ្វើឱ្យពិបាកក្នុងការបំពេញ ពីព្រោះដោយសារតែគំរោងចុះបញ្ជីដីធ្លីជាសមូភាពនេះ គឺជាគំរោងសាកល្បងថ្មីមួយ ហើយជាជំហានមុនដំបូង យើងមិនទាន់មានទម្រង់ និងសំណុំបែបបទរួមណាមួយដើម្បីបំពេញសំរាប់ដំណើរការស្នើសុំចុះបញ្ជីដីធ្លីសមូហភាពនេះនៅឡើយ។ ហេតុនេះហើយ បានជា

ជំនាញនីមួយៗ ឧទាហរណ៍នៅខាងក្រសួងមហាផ្ទៃ គឺមានទម្រង់និង បែបបទផ្សេង ចំណែកខាងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ មានបែបបទផ្សេង ដែលបញ្ហានេះធ្វើឱ្យមានភាពមិនស៊ីសង្វាក់គ្នា។

- ទំនាក់ទំនងជាមួយសហគមន៍និងអាជ្ញាធរមូលដ្ឋានមានការពិបាក ដោយសារតែប៉ះពាល់ទៅនឹងផលប្រយោជន៍មួយចំនួនរបស់ពួកគាត់។
- ខ្វះមធ្យោបាយធ្វើដំណើរក្នុងដំណើរការចុះបញ្ជីដីធ្លីសមូហភាព។ ម៉ូតូមួយជិះគ្នាបីនាក់ ផ្លូវរអិលពិបាកធ្វើដំណើរ ដែលមិនធានាដល់សុវត្ថិភាព។

## ២.៣- ការប្រឈមរបស់អង្គការ ឌីភីអេ ជាមួយស្ថាប័នពាក់ព័ន្ធ និងដៃគូផ្សេងទៀត

- គណៈកម្មាធិការដែលត្រូវបានជ្រើសរើស ភាគច្រើនពួកគាត់មិនសូវចេះអក្សរ ដែលបណ្តាលឱ្យការដឹកនាំ និងការគ្រប់គ្រងរបស់គាត់មិនសូវមានប្រសិទ្ធភាព។ ហេតុនេះ យើងត្រូវការពេលវេលាច្រើនក្នុងការកសាងសមត្ថភាពរបស់ពួកគាត់បន្ថែមទៀត ដើម្បីឱ្យពួកគាត់អាចពន្យល់និងផ្សព្វផ្សាយចំណេះដឹងផ្សេងៗដែលពួកគាត់ បានរៀនសូត្រទៅដល់សមាជិកសហគមន៍ផ្សេងទៀត ជាពិសេសគឺការពាក់ព័ន្ធទៅនឹងដីធ្លី។ ហេតុនេះ នៅរាល់ដំណាក់កាលទាំងអស់នៅក្នុងការចុះបញ្ជីដីធ្លីនេះ យើងត្រូវជួយសម្របសម្រួលដល់ពួកគាត់ទាំងអស់ ដែលរួមបញ្ចូលទាំងការប្រជុំរៀបចំផែនការ ការធ្វើលក្ខន្តិកៈ ការរៀបចំបទបញ្ជាផ្ទៃក្នុង និងការរៀបចំសំណុំបែបបទផ្សេងទៀត។
- ស្របពេលជាមួយគ្នានេះដែរ ការចូលរួមរបស់មន្ទីរជំនាញហាក់ដូចជានៅមានកំរិត ដោយសារថាពួកគេមានការងារជាច្រើនដែលត្រូវបំពេញ ដែលធ្វើឱ្យមានភាពយឺតយ៉ាវនៅក្នុងការអនុវត្តការងារ។
- នៅក្នុងអំឡុងពេលនៃការចុះផ្សព្វផ្សាយអំពីការចុះបញ្ជីដីធ្លីនេះ មានសមាជិកសហគមន៍មួយចំនួនតូចនៅតែមិនទាន់យល់ច្បាស់លាស់អំពីសារៈសំខាន់នៃការចុះបញ្ជីដីធ្លីជាសមូហភាពនេះនៅឡើយ ពីព្រោះពួកគាត់យល់ឃើញថា វាអាចបាត់បង់ ឬ ប៉ះពាល់ដល់ផលប្រយោជន៍និងដីធ្លីរបស់ពួកគាត់។
- នៅក្នុងអំឡុងពេលនៃដំណើរការចុះបញ្ជីដីធ្លីនេះ យើងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្របសម្រួលសហគមន៍ជនជាតិដើមភាគតិចនៅភូមិឡាអិន ដើម្បីដោះស្រាយបញ្ហាផ្សេងៗ ជាពិសេស ការពាក់ព័ន្ធទៅនឹងទំនាស់ផលប្រយោជន៍រវាងសហគមន៍ជាមួយនឹងអ្នកខាងក្រៅ (ឈ្មួញ ក្រុមហ៊ុន និងអ្នកមានអំណាច)។ យើងក៏មានការប្រឈមយ៉ាងខ្លាំងជាមួយនឹងអ្នកទាំងនោះ ហើយមានការបារម្ភចំពោះសុវត្ថិភាពផ្ទាល់ខ្លួន។
- បទពិសោធន៍នៅក្នុងការធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមនៅមានកំរិតពីដំបូង។

- ជំហាន ឬ ដំណាក់កាលនៃគោលការណ៍ចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិច មានការកែប្រែប្រួលជាច្រើនសារ ដោយបានប្តូរពី១២ជំហាន (២០០៤) មកត្រឹម៨ជំហានវិញ (២០០៧) ដែលជាហេតុធ្វើអោយយើងមានការពិបាកនៅក្នុងការអនុវត្ត និងផ្សព្វផ្សាយទៅសហគមន៍ឡើងវិញទាក់ទងនឹងជំហាននីមួយៗ ដែលបានកែប្រែនេះ។

## ៣. ដំណោះស្រាយចំពោះការប្រឈមកន្លងមក

- ដោយមានជំនួយពីអង្គការសហប្រតិបត្តិការអន្តរជាតិដើម្បីកម្ពុជា ហៅកាត់ថា **អាយស៊ីស៊ី (ICC)** ក្នុងខេត្តរតនគីរី ការអប់រំទ្វិភាសា (ការយកតួរអក្សរភាសាខ្មែរដើម្បីសរសេរប្រកបជាភាសាជនជាតិ) សំរាប់បងប្អូនជនជាតិដើមភាគតិច មានការរីកចំរើនច្រើន ហើយជាបន្តបន្ទាប់ ក្រុមការងារបានបង្កើតសំភារៈអប់រំទាក់ទងទៅនឹងសិទ្ធិដីធ្លី ជាភាសាជនជាតិដើមមួយចំនួន។ កត្តានេះ គឺជាវិភាគទានយ៉ាងសំខាន់មួយក្នុងការធ្វើឱ្យប្រសើរឡើងនូវការយល់ដឹង និងបង្កើនការចូលរួមរបស់ប្រជាជននៅក្នុងសហគមន៍លើផ្នែកភូមិបាល និងការចុះបញ្ជីដីធ្លី។ បន្ថែមពីលើនេះទៀត ការរៀបចំ និងកសាងសមត្ថភាពសហគមន៍ឱ្យយល់ដឹងអំពីក្របខណ្ឌ និងលិខិតបទដ្ឋានច្បាប់ ក៏ដូចជាគោលនយោបាយផ្សេងៗតាមរយៈ ការរៀបចំសិក្ខាសាលា ការបណ្តុះបណ្តាល និងយុទ្ធនាការផ្សព្វផ្សាយនានា គឺមានសារៈសំខាន់ណាស់នៅក្នុងការលើកកំពស់ចំណេះដឹងដល់សហគមន៍ដែលពាក់ព័ន្ធទៅនឹងគំរោងចុះបញ្ជីដីធ្លីនេះ។
- ម៉្យាងវិញទៀត ការមានកិច្ចសហការល្អប្រសើរ និងការជឿជាក់គ្នាទៅវិញទៅមកក្នុងក្រុមការងារ ដែលរួមមាន ស្ថាប័នរដ្ឋាភិបាល និងអង្គការដែលពាក់ព័ន្ធ វាក៏ជាផ្នែកមួយយ៉ាងសំខាន់ ដើម្បីធ្វើឱ្យមានបរិយាកាសការងារប្រកប ដោយសាមគ្គីភាព និងទទួលបានលទ្ធផលជាផ្លែផ្កា។
- កសាងសាមគ្គីភាព និងការស្រុះស្រួលឆន្ទៈនៅក្នុងសហគមន៍។
- ធ្វើការអប់រំផ្សព្វផ្សាយម្តងហើយម្តងទៀតអំពី សារៈប្រយោជន៍នៃការចុះបញ្ជីដីធ្លីជាសម្ធូហភាព ក៏ដូចជាច្បាប់ និងគោលនយោបាយដែលពាក់ព័ន្ធផ្សេងៗទៀតដល់សហគមន៍។
- រៀនបណ្តើរធ្វើបណ្តើរ
- អនុវត្តបណ្តើរ និងកែលំអបណ្តើរ

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការអនុវត្តគំរោងនេះ យើងអាចសន្និដ្ឋានបានថា វាគឺជាជោគជ័យដ៏ធំធេង ដែលអង្គការ ឌីភីអេ ដៃគូសហការ និង សហគមន៍ជនជាតិដើមភាគតិចទទួលបាន។ ជាតឹកតាង សហគមន៍ជនជាតិដើមភាគតិចនៅភូមិឡាអិន នៃខេត្តរតនគីរីទទួលបាននូវ កម្មសិទ្ធិកាន់កាប់ដីធ្លីសមូហភាព ដែលនេះបង្ហាញឱ្យឃើញពីការប្រឹងប្រែង និងបទពិសោធន៍រៀនសូត្រ ដែលអាចយកទៅអនុវត្តនៅ ភូមិគោលដៅ ឬ តំបន់ផ្សេងទៀតដែលមានស្ថានភាពប្រហាក់ប្រហែល។ តែទោះជាយ៉ាងនេះក្តី យើងបានជួបប្រទះបញ្ហាមួយចំនួន ដែលត្រូវដោះស្រាយ និងកែលម្អចំពោះគំរោងបន្ទាប់។ នៅក្នុងរបាយការណ៍នេះ គឺបានផ្តល់នូវអនុសាសន៍មួយចំនួន ដែលអាចជួយជំនះ លើបញ្ហាដែលជួបប្រទះទាំងនោះ។

សរុបសេចក្តីមក តាមរយៈការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃការវាយតម្លៃការគ្រប់គ្រងការប្រើប្រាស់ដី ការអភិវឌ្ឍ លក្ខន្តិកៈ ការចូលរួមវគ្គបណ្តុះបណ្តាល ការផ្សព្វផ្សាយ ការហ្វឹកហាត់ និងទស្សនកិច្ចសិក្សាទៅកាន់ទីកន្លែងផ្សេងៗ យើងឃើញថាអ្នក ភូមិភាគច្រើនមានការយល់ដឹងច្រើនទាក់ទងនឹងផលប៉ះពាល់បណ្តាលមកពីការបាត់បង់ដីធ្លី និងព្រៃឈើ ហើយពួកគាត់ក៏យល់ច្បាស់ពី សារៈសំខាន់នៅក្នុងការចូលរួមរៀបចំផែនការប្រើប្រាស់ដីធ្លី និងសហគមន៍ព្រៃឈើ ដែលអាចជួយ និងផ្តល់អំណាចដល់ពួកគាត់ ដើម្បី ការពារដីធ្លី និងធនធានព្រៃឈើ។ យ៉ាងណាមិញ សកម្មភាពទាំងអស់នេះ ក៏បានចូលរួមចំណែកជួយដល់សហគមន៍ ដើម្បីអោយពួកគាត់ អាចប្រើប្រាស់ធនធានធម្មជាតិទាំងនោះប្រកបដោយនិរន្តរភាព ព្រមទាំងអាចធ្វើអោយមានភាពល្អប្រសើរឡើងនូវកិច្ចព្រមព្រៀងរួម គ្នាមួយរវាងអ្នកស្រុកនៅក្នុងភូមិ ជាមួយនឹងភូមិជិតខាងលើការប្រើប្រាស់ដីធ្លីនៅពេលបច្ចុប្បន្ន និងនៅអនាគតប្រកបដោយភាពសុខ ដុម រួមជាមួយនឹងទិសដៅអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានធម្មជាតិទាំងអស់នោះ។

ដូចគ្នាផងដែរ តាមរយៈការអនុវត្តការគ្រប់គ្រង និងការរៀបចំផែនការប្រើប្រាស់ដីដោយមានការចូលរួម (PLUP ) និងការ ចុះបញ្ជីដីជាសមូហភាព គឺជាយុទ្ធសាស្ត្រមួយ ដែលអាចការពារការលក់ដូរដី ការបាត់បង់ដីធ្លី ការដណ្តើម និងការទន្ទ្រានយកដី ព្រម ទាំងអាចធ្វើអោយប្រសើរឡើងនូវការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព និងអាចលើកកំពស់នូវសិទ្ធិរបស់សហគមន៍ជនជាតិដើម ភាគតិចនៅក្នុងការកាន់កាប់ដីធ្លី ជាពិសេសអាចពង្រឹងសាមគ្គីភាពនៅក្នុងសហគមន៍។

# អនុសាសន៍

- បង្កើនចំនួនសូចនករត្រួតពិនិត្យរួម សំរាប់ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចអោយបានច្រើនជាងពេលបច្ចុប្បន្ន
- ដើម្បីឱ្យដំណើរការចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិចបានលឿន គំរោងចុះបញ្ជីលើកក្រោយ គួរតែសម្រេចអនុម័តត្រឹមស្ថាប័នរដ្ឋាភិបាលនៅក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធថ្នាក់ខេត្ត។ ការកំណត់មកត្រឹមក្រុមការងារថ្នាក់ខេត្តនឹងធ្វើឱ្យដំណើរការកាន់តែលឿន។
- គួរមានកិច្ចសហការល្អប្រសើរ និងការជឿជាក់គ្នាទៅវិញទៅមកក្នុងក្រុមការងារដែលរួមមានស្ថាប័នរដ្ឋាភិបាល និងអង្គការដែលពាក់ព័ន្ធ។ ទង្វើបែបនេះនឹងនាំឱ្យមានបរិយាកាសការងារប្រកបដោយសាមគ្គីភាពនិងទទួលបានលទ្ធផលជាផ្លែផ្កា។
- បន្តសហការជាមួយអង្គការសហប្រតិបត្តិការអន្តរជាតិដើម្បីកម្ពុជា ហៅកាត់ថា **អាយស៊ីស៊ី** ក្នុងខេត្តរតនគីរី ដើម្បីប្រើប្រាស់ទ្វិភាសា និងសម្ភារៈអប់រំដែលទាក់ទងទៅនឹងសិទ្ធិដីធ្លីជាភាសាជនជាតិដើមភាគតិច ដែលជួយសម្រួលក្នុងការងារផ្សព្វផ្សាយកាន់តែប្រសើរឡើងទៅដល់សហគមន៍ជនជាតិដើមភាគតិចលើផ្នែកភូមិបាល និងការចុះបញ្ជីដីធ្លី។
- ពង្រឹងសមត្ថភាពសហគមន៍ និងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច តាមរយៈសិក្ខាសាលា ការបណ្ដុះបណ្ដាល និងយុទ្ធនាការនានាសំរាប់បងប្អូនជនជាតិដើមភាគតិច គឺជាការលើកទឹកចិត្តដ៏សំខាន់ ដើម្បីបញ្ឈប់ចលនាលក់ដីធ្លីរបស់ពួកគេ និងជំរុញឱ្យពួកគេគាំទ្រគំរោងចុះបញ្ជីដីធ្លី។ ការពង្រឹងសមត្ថភាពទាំងនេះរួមមាន ការយល់ដឹងអំពីក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានច្បាប់មុននឹងសហគមន៍បង្ហាញពីសក្ដីភាពនៃជំរើសកម្មសិទ្ធិ និងការរៀបចំលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិច។
- ធ្វើទំនាក់ទំនង និងពិគ្រោះយោបល់ជាប្រចាំរវាងក្រុមការងារថ្នាក់ខេត្ត និងក្រុមការងារថ្នាក់ជាតិដែលពាក់ព័ន្ធ ដើម្បីជួយជំរុញឱ្យមានការគាំទ្រ និងពន្លឿនដំណើរការរៀបចំលក្ខន្តិកៈ និងការចុះបញ្ជីដីធ្លីសហគមន៍។
- ត្រៀមលក្ខណៈឱ្យបានគ្រប់ជ្រុងជ្រោយ ដោយមានការពិគ្រោះយោបល់នៅគ្រប់កំរិត ចងក្រងឯកសារ និងរៀបចំបែបបទរដ្ឋបាលឱ្យទាន់ពេលវេលា ដើម្បីកាត់បន្ថយការអូសបន្លាយពេលវេលា។
- បង្រៀនអក្សរដល់គណៈកម្មាធិការសហគមន៍ដែលអាចធ្វើឱ្យពួកគាត់ចេះអាននិងចេះសរសេរបានខ្លះៗ។ ការជ្រើសរើសគណៈកម្មាធិការដែលចេះអក្សរស្រាប់អាចលើកឡើងជាសំណូមពរចំពោះសមាជិកសហគមន៍ផងដែរ ដើម្បីពន្លឿនការងារចុះបញ្ជីដីធ្លី។

- បំប៉នបន្ថែមចំពោះគណៈកម្មាធិការលើជំនាញគ្រប់គ្រង ដឹកនាំ និងអភិវឌ្ឍន៍សហគមន៍តាមបែបសម័យ។ ការប្រើទ្វិភាសា-អាចជួយទៅដល់ការពង្រឹងសមត្ថភាពនេះ។ ផ្ដល់ការអប់រំបន្ថែមដល់សហគមន៍ជនជាតិដើមភាគតិច ជាពិសេសគណៈកម្មា-ធិការ អំពីច្បាប់នានាដែលពាក់ព័ន្ធទៅនឹងបញ្ហាដីធ្លី បរិស្ថាន និងធនធានធម្មជាតិ គោលបំណងនិងដំណើរការនៃការចុះបញ្ជីដីធ្លី

និងសិទ្ធិនៃការប្រើប្រាស់ដីធ្លីសម្ហូហភាព។ ការងារនេះ ក៏ជួយជំរុញដល់ការកាត់បន្ថយភាពញឹកញាប់ក្នុងការផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការសហគមន៍ផងដែរ។

- បង្ហាត់បង្ហាញរបៀបគូសផែនទី ការពិនិត្យនិងកំណត់ព្រំប្រទល់រដ្ឋបាលឃុំ ត្រូវធ្វើឡើងដោយសម័ញ្ញ និងសមស្របដែលអាចធ្វើឱ្យសហគមន៍ជនជាតិដើមភាគតិចងាយយល់អំពីបច្ចេកទេស ជាពិសេសគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចតែម្តង។
- សហការជាមួយអាជ្ញាធរមូលដ្ឋាន រួមទាំងអង្គការដៃគូរផ្សេងទៀត ដើម្បីលើកទឹកចិត្តប្រជាសហគមន៍ជនជាតិដើមភាគតិច ក្នុងការទប់ស្កាត់ការញុះញង់ពីអ្នកខាងក្រៅនិងការលក់ដីធ្លីទៅឱ្យពួកឈ្មួញ។ វាក៏ជួយកាត់បន្ថយការធ្វើការងារដដែលជាច្រើនសារ ដូចជាការវាស់វែង ឬការកំណត់ព្រំដែន ជាដើម ។ល។

# ឯកសារយោង

* របាយការណ៍ប្រចាំឆ្នាំ ២០០៤-២០០៥ នៃគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះខេត្តរតនគីរី អង្គការឌីភីអេ
* របាយការណ៍ប្រចាំឆ្នាំ ២០០៦-២០០៨ នៃគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះខេត្តរតនគីរី និងមណ្ឌលគីរី អង្គការឌីភីអេ
* របាយការណ៍បីឆ្នាំ ២០០៩-២០០១១ នៃគំរោងកម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះខេត្តរតនគីរី និងមណ្ឌលគីរី អង្គការឌីភីអេ
* នុយ បូរ៉ា ទីប្រឹក្សា *"ការពិនិត្យឡើងវិញពីដំណើរការ និងការគាំទ្រការអភិវឌ្ឍផែនការការងារលើការចុះបញ្ជីដីធ្លីសំរាប់សហគមន៍ជនជាតិដើមភាគតិចនៅខេត្តរតនគីរី និងមណ្ឌលគីរី" ថ្ងៃទី ១៥ មករា ២០១០*
* ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤/៣០.៨.២០០១ ស្តីពីច្បាប់ដីធ្លី
* អនុក្រឹត្យលេខ ៨៣ អនក្រ/បក/៩.០៦.២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី នីតិវិធីនៃការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច
* អង្គការពលកម្មអន្តរជាតិ (ILO) *"ការអភិវឌ្ឍលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិច"*
* គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍន៍ជនជាតិដើមភាគតិច ឆ្នាំ២០០៩
* ក្រុមការងារសម្របសម្រួល និងអនុវត្តគម្រោងចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល *"កម្រងឯកសារ ស្តីពីគម្រោងគាំទ្រ និងចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានីតិបុគ្គល" ឆ្នាំ២០១១*
* សារាចរអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីវិធានការការពារបណ្តោះអាសន្ននូវដីដែលសហគមន៍ជនជាតិដើមភាគតិចស្នើសុំចុះបញ្ជីក្នុងពេលរង់ចាំការចុះបញ្ជីដីនោះជាកម្មសិទ្ធិសមូហ-ភាពរបស់សហគមន៍ត្រូវបានបញ្ចប់តាមនីតិវិធី ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១១
* ម៉ែន ប្រាជ្ញវុទ្ធី (Men Prachvuthy) *"ការទទួលបានដីធ្លី ដោយតួអង្គក្រៅមូលដ្ឋាន និងសារៈសំខាន់នៃការអភិវឌ្ឍន៍មូលដ្ឋាន ៖ ផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ចលើជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិច នៅតំបន់ ភូមិ-ភាគឦសាន នៃប្រទេសកម្ពុជា" ខែមីនា ឆ្នាំ២០១១" ("Land Acquisition by Non-Local Actors and Consequences for Local Development: Impacts of Economic Land Concession on the Livelihoods of Indigenous Communities in Northest Province of Cambodia", March 2011)*

## ឧបសម្ព័ន្ធទី១ : ដំណើរការនិងជំហាននៃការរៀបចំផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ( ឆ្នាំ២០០៩)

| ជំហាន និងសកម្មភាព | វិធីសាស្ត្រ និងឧបករណ៍ |
|---|---|
| **ជំហានដំបូង :**<br>**ចាប់ផ្តើមរៀបចំធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម** | • ប្រឹក្សាជាមួយអ្នកពាក់ព័ន្ធទាំងឡាយដើម្បីសកម្មភាពគាំទ្រធនធាន និងទិន្នន័យដែលមានស្រាប់របស់ពួកគេ ។<br>• ប៉ាន់ប្រមាណទៅលើធនធានដែលត្រូវការ និងសម្ភារៈដែលចាំបាច់ ។<br>• កំណត់ភូមិនិងឃុំគោលដៅ ។<br>• បង្កើតជាគំរោង ។<br>• បង្កើតក្រុមសម្របសម្រួលធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមនៅថ្នាក់ខេត្ត ហើយបណ្តុះបណ្តាលទៅដល់ពួកគេ ។<br>• ធ្វើបទបង្ហាញអំពីគំរោងធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ដែលបានស្នើសុំ ។<br>• ធ្វើបទបង្ហាញអំពីដំណើរការនៃការធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ។<br>• ប្រមូលសេចក្តីព្រមព្រៀង និងការគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងនាយកដ្ឋានខ្សែបណ្តោយដែលពាក់ព័ន្ធ ។<br>**( ការងារនេះអាចធ្វើក្នុងរយៈពេលពី ៤ ទៅ ៧សប្តាហ៍)** |
| **ជំហានទី១ :**<br>**បង្កើតនិងបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងធនធានធម្មជាតិ** | • ធ្វើបទបង្ហាញអំពីគំរោងធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមទៅដល់ថ្នាក់ឃុំ ។<br>• ជ្រើសរើសគណៈកម្មាធិការគ្រប់គ្រងធនធានធម្មជាតិថ្នាក់ឃុំ ។<br>• បង្កើតឱ្យមាននូវតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងធនធានធម្មជាតិថ្នាក់ឃុំ ។<br>• រៀបចំដីការឃុំសម្រាប់គណៈកម្មាធិការគ្រប់គ្រងធនធានធម្មជាតិថ្នាក់ឃុំ ដើម្បីឱ្យមានការទទួលស្គាល់ដោយក្រុមប្រឹក្សាឃុំ ។<br>**( ការងារនេះអាចធ្វើក្នុងរយៈពេល ២ថ្ងៃ ក្នុងមួយឃុំ)**<br>• ផ្សព្វផ្សាយអំពី :<br>* គោលការណ៍ និងជំហាននៃការធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមសម្រាប់ជនជាតិតំបន់ភ្នំ ។<br>* សិទ្ធិជនជាតិដើមភាគតិច ដែលពាក់ព័ន្ធទៅនឹងច្បាប់ភូមិបាលនិងច្បាប់ព្រៃឈើ<br>* ដំណោះស្រាយទំនាស់ ។<br>* ការធ្វើផែនការ និងការប្រើប្រាស់ជីភីអែស ។<br>* ការប្រមូលព័ត៌មាន ( ដោយប្រើឧបករណ៍វាយតំលៃជនបទដោយមានការចូលរួម) - PRA ។ |

| ជំហាន និងសកម្មភាព | វិធីសាស្ត្រ និងឧបករណ៍ |
|---|---|
| | * រៀបចំទស្សនៈកិច្ចសិក្សាសម្រាប់គណៈកម្មាធិការគ្រប់គ្រងធនធានធម្មជាតិថ្នាក់ភូមិឃុំ។<br>**(ការងារនេះអាចធ្វើក្នុងរយៈពេលពី ៥ ទៅ ៧ថ្ងៃ ក្នុងមួយឃុំ)** |
| **ជំហានទី២ :**<br>**តម្រង់ទិសគំរោងនៅថ្នាក់សហគមន៍** | • ផ្តល់កិច្ចការទៅដល់សមាជិកក្រុមសម្របសម្រួលធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម។<br>• ធ្វើបទបង្ហាញអំពី គំរោងធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួមដែលបានស្នើសុំ។<br>• គូសបញ្ជាក់ឡើងវិញអំពីសំណើរនៅក្នុងផែនការអភិវឌ្ឍន៍សហគមន៍/ផែនការវិនិយោគឃុំ ហើយបង្កើតជាកិច្ចសន្យា។<br>• ធ្វើបទបង្ហាញអំពីគោលទស្សនៈនៃការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ (ការប្រើប្រាស់ បញ្ហា ទស្សនៈវិស័យ និងការធ្វើផែនការ)។<br>• ជ្រើសរើសជនបង្គោលគ្រប់គ្រងធនធានធម្មជាតិថ្នាក់ភូមិ។<br>• បណ្តុះបណ្តាលជនបង្គោលគ្រប់គ្រងធនធានធម្មជាតិថ្នាក់ភូមិទាំងនោះ ស្តីពីវិធីសាស្ត្រនៃការអនុវត្តផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ការប្រមូលព័ត៌មាន (ដោយប្រើឧបករណ៍វាយតំលៃជនបទដោយមានការចូលរួម) ការបកស្រាយផែនទី និងការប្រើឧបករណ៍ជីភីអែស។<br>• ពិភាក្សាអំពីបញ្ហាដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ និងយែនឌ័រ ហើយកំណត់នូវទស្សនៈវិស័យសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ។<br>• ធ្វើទស្សនៈកិច្ចសិក្សា។<br>**(ការងារនេះអាចធ្វើក្នុងរយៈពេល ៥ថ្ងៃ)** |
| **ជំហានទី៣ :**<br>**ប្រមូលព័ត៌មាន និងវិភាគស្ថានភាពភូមិ ដោយប្រើឧបករណ៍វាយតំលៃជនបទ ដោយមានការចូលរួម** | **ដំណាក់កាលទី១ : ការវាយតំលៃដោយមានការចូលរួម និងការប្រមូលព័ត៌មាន**<br>• ប្រមូលទិន្នន័យ និងវិភាគស្ថានភាពសេដ្ឋកិច្ចសង្គម<br>• ប្រមូលទិន្នន័យ និងវិភាគស្ថានភាពសហគមន៍<br>• ប្រមូលទិន្នន័យ និងវិភាគការប្រើប្រាស់ធនធានធម្មជាតិបច្ចុប្បន្ន<br>• ប្រមូលទិន្នន័យ និងវិភាគទំនាស់ដីធ្លីនិងធនធានធម្មជាតិ<br>• ចងក្រងឯកសារនូវរាល់គំហើញ និងធ្វើបទបង្ហាញទៅដល់សហគមន៍ ដើម្បីផ្ទៀងផ្ទាត់ និងកែសម្រួល<br>• ចងក្រងឯកសារនូវបញ្ហាទាំងនោះ ហើយផ្តល់ជូនអ្នកពាក់ព័ន្ធទាំងឡាយនៅថ្នាក់ខេត្ត។<br>**(ការងារនេះអាចធ្វើក្នុងរយៈពេល ៥ថ្ងៃក្នុងមួយភូមិ)** |

| ជំហាន និងសកម្មភាព | វិធីសាស្ត្រ និងឧបករណ៍ |
|---|---|
| | **ដំណាក់កាលទី២ : ការបង្កើតព្រំប្រទល់ភូមិឃុំទៅតាមទម្លាប់**<br>• ធ្វើបទបង្ហាញ និងកែតម្រូវទៅលើផែនទីពង្រាងគ្រប់គ្រងធនធានធម្មជាតិថ្នាក់ភូមិ ។<br>• ធ្វើបទបង្ហាញផែនទីពង្រាង និងបម្លែងព្រំប្រទល់ធ្វើតាមទម្លាប់ ឱ្យទៅជាផែនទីមានរាងជាសណ្ឋាន ហើយបើសិនជាចាំបាច់ ត្រូវធ្វើការកែសម្រួលជាមួយអ្នកភូមិ ។<br>• រៀបចំសិក្ខាសាលាថ្នាក់ភូមិ/ឃុំ ដើម្បីពិភាក្សា ហើយកែសម្រួលព្រំប្រទល់ភូមិដែលធ្វើតាមទម្លាប់ ជាមួយភូមិ/ឃុំដែលនៅជិតខាង ។<br>• កំណត់ព្រំប្រទល់និងកន្លែងត្រួតស៊ីគ្នាដែលមិនមានអ្វីជាក់ចំណាំជាក់លាក់ ដោយធ្វើការគូស ឬ បោះបង្គោលចំណាំព្រំប្រទល់ ហើយចរចារឱ្យមានការឯកភាពគ្នាទៅលើព្រំប្រទល់ នោះ ។<br>• ប្រមូលផ្តុំចំណុចទាំងឡាយដែលបានចុច ជីភីអែស នៅក្នុងកន្លែងដែលបានធ្វើជាក់ស្តែងទៅតាមលក្ខណៈដែលមានពីមុនមក ដើម្បីកំណត់ទ្រង់ទ្រាយព្រំប្រទល់ឱ្យបានជាក់លាក់ ។<br>• ចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងអ្នកភូមិទៅលើព្រំប្រទល់ដែលបានឯកភាព ។<br>• បង្កើតផែនទីដែលមានមាត្រដ្ឋាន ។<br>**(ការងារនេះអាចធ្វើក្នុងរយៈពេល ៣០ថ្ងៃ)**<br>**ដំណាក់កាលទី៣ : សេចក្តីប្រកាសតំបន់ភូមិ/ឃុំដែលបានធ្វើការវិនិច្ឆ័យរួច**<br>• ធ្វើការបង្ហាញផែនទីដែលមានព្រំប្រទល់ និងកិច្ចព្រមព្រៀងទៅដល់ការិយាល័យរដ្ឋបាល ភូមិបាល ។<br>• មន្ត្រីវិនិច្ឆ័យធ្វើការសិក្សាទៅលើកិច្ចព្រមព្រៀងនិងផែនទី ផ្ទៀងផ្ទាត់ព័ត៌មាន ហើយប្រកាសតំបន់នោះជាតំបន់ដែលបានធ្វើវិនិច្ឆ័យរួច ។<br>**(ការងារនេះអាចធ្វើក្នុងរយៈពេល ១៤ថ្ងៃ)**<br>**ដំណាក់កាលទី៤ : ការបង្កើតផែនទីប្រើប្រាស់ដីធ្លីលម្អិត**<br>• វិភាគស្ថានភាពភូមិ និងការប្រើប្រាស់បរិវេណនិមួយៗ ។<br>• កំណត់និងបោះបង្គោលព្រំលើបរិវេណដីនៃការប្រើប្រាស់លម្អិត ដែលថិតនៅក្នុងព្រំដែននៅក្នុងផែនទីមាត្រដ្ឋាន និងផែនទីផ្កាយរណប ។<br>• កំណត់តំបន់ដែលសមស្របសម្រាប់ការផ្តល់កម្មសិទ្ធិដីធ្លីសហគមន៍ ។<br>• តម្រង់ទិស និងប្រមូលផ្តុំចំណុចដែលបានចុច ជីភីអែស នៅតាមព្រំប្រទល់នៃបរិវេណនីមួយៗ ។<br>• ផ្តល់ព័ត៌មានត្រឡប់ដើម្បីកែតម្រូវ និងឯកភាពទៅលើព្រំប្រទល់បរិវេណជាមួយអ្នកភូមិទាំងនោះ ។<br>• ផ្ទេរព័ត៌មាន និងទិន្នន័យ ហើយបង្កើតជាផែនទីមាត្រដ្ឋាន ។ |

| ជំហាន និងសកម្មភាព | វិធីសាស្ត្រ និងឧបករណ៍ |
| --- | --- |
| **ជំហានទី៤ :**<br>**កំណត់អត្តសញ្ញាណដំបូងនៃតំបន់ដីធ្លីសហគមន៍ និងភាពសមស្របនៃដីធ្លីសំរាប់សហគមន៍** | • ពិភាក្សា និងប៉ាន់ប្រមាណនូវជម្រើសទាំងឡាយដើម្បីប្រើប្រាស់និងគ្រប់គ្រងបរិវេណនិមួយៗ។<br>• បើអាចទៅរួច ត្រូវធ្វើការប៉ាន់ប្រមាណបច្ចេកទេសសមស្រប។<br>• ប៉ាន់ប្រមាណភាពសមស្របនៃដី រួចហើយបង្កើតផែនទី។<br>• ផ្តល់ព័ត៌មានត្រឡប់ទៅឱ្យសហគមន៍ ហើយត្រូវធ្វើឱ្យមានការឯកភាពគ្នា។<br>**(ការងារនេះអាចធ្វើក្នុងរយៈពេល ២០ថ្ងៃ)** |
| **ជំហានទី៥ :**<br>**ជ្រើសរើសគណៈកម្មាធិការគ្រប់គ្រងធនធានធម្មជាតិភូមិ** | • ជ្រើសរើសភូមិសម្រាប់បង្កើតគណៈកម្មាធិការគ្រប់គ្រងធនធានធម្មជាតិភូមិ រួចហើយ បង្កើតរចនាសម្ព័ន្ធនិងលក្ខន្តិកៈ។<br>• កសាងសមត្ថភាពទៅដល់គណៈកម្មាធិការគ្រប់គ្រងធនធានធម្មជាតិភូមិ។<br>**(ការងារនេះអាចធ្វើក្នុងរយៈពេល ៤ថ្ងៃ)** |
| **ជំហានទី៦ : រៀបចំផែនការប្រើប្រាស់ដីធ្លីនាពេលអនាគត បទបញ្ជាផ្ទៃក្នុងភូមិ និងផែនការគ្រប់គ្រងលម្អិត** | • ពិនិត្យជម្រើសឡើងវិញដើម្បីប្រើប្រាស់និងគ្រប់គ្រងបរិវេណនិមួយៗ (កំណត់ប្រភេទ ដីរដ្ឋ ដីឯកជន និងដីសហគមន៍) សម្រាប់រៀបចំផែនការមេក្នុងការប្រើប្រាស់ដីធ្លីនាពេលអនាគត។<br>• បង្កើតវិន័យនិងបទបញ្ជាផ្ទៃក្នុងសម្រាប់ផែនការមេក្នុងការប្រើប្រាស់ដីធ្លី។<br>• ផ្តល់ព័ត៌មានត្រឡប់ទៅដល់សហគមន៍ ហើយត្រូវធ្វើឱ្យមានការឯកភាពគ្នាទៅលើផែនការមេក្នុងការប្រើប្រាស់ដីធ្លី បទវិន័យនិងបទបញ្ជាផ្ទៃក្នុង។ |
| **ជំហានទី៧ :**<br>**ដាក់សំណើរផែនការប្រើប្រាស់ដីធ្លី បទបញ្ជាផ្ទៃក្នុងភូមិ និងផែនការគ្រប់គ្រង ដើម្បីសុំចំណារនិងការយល់ព្រម ពីថ្នាក់ឃុំ និងថ្នាក់ខេត្ត** | **ដំណាក់កាលទី១ : សិក្ខាសាលាថ្នាក់ឃុំ**<br>• រៀបចំសិក្ខាសាលាស្តីពីបទវិន័យនិងបទបញ្ជាផ្ទៃក្នុង និងការធ្វើផែនការប្រើប្រាស់ដីធ្លី។<br>• ដាក់សំណើរពីថ្នាក់ភូមិនិងថ្នាក់ឃុំជូនដល់អាជ្ញាធរខេត្តដែលពាក់ព័ន្ធ។<br>**(ការងារនេះអាចធ្វើក្នុងរយៈពេល ២ថ្ងៃ)**<br>**ដំណាក់កាលទី២ : សិក្ខាសាលាថ្នាក់ឃុំ**<br>• រៀបចំសិក្ខាសាលាថ្នាក់ខេត្ត ដើម្បីបង្ហាញផែនទីនិង R&R សម្រាប់ការធ្វើផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម។<br>• ពង្រាងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធ ដើម្បីទទួលស្គាល់ការប្រើប្រាស់ដីធ្លីថ្នាក់ភូមិ និងឃុំ។<br>• ចុះបញ្ជីរាល់ប្រភេទនៃធនធានដីធ្លីនៅថ្នាក់ខេត្ត។<br>• ធ្វើឱ្យមានការយល់ព្រម និងឯកភាពពីសំណាក់ក្រុមប្រឹក្សាឃុំ អាជ្ញាធរស្រុក និងមន្ទីរពាក់ព័ន្ធ ហើយចុះហត្ថលេខានៅលើទម្រង់ដែលបានដាក់បញ្ញត្តិ<br>**(ការងារនេះអាចធ្វើក្នុងរយៈពេល ២ថ្ងៃ)** |

| ដំហាន និងសកម្មភាព | វិធីសាស្ត្រ និងឧបករណ៍ |
|---|---|
| **ជំហានទី៨ :**<br>**ត្រួតពិនិត្យ និងវាយតំលៃ** | • ពិនិត្យឡើងវិញនូវការជំរុញអនុវត្តផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ។<br>• ពិនិត្យឡើងវិញនូវការជំរុញអនុវត្តបទវិន័យនិងបទបញ្ជាផ្ទៃក្នុង ។<br>• កំណត់អាទិភាពទៅលើដំណោះស្រាយ ។<br>• រៀបចំផែនការខែ ផែនការត្រីមាស និងផែនការឆ្នាំ ។<br>• កសាងសមត្ថភាពលើក្របខណ្ឌច្បាប់នៃការគ្រប់គ្រងធនធានធម្មជាតិ និងកិច្ចការរដ្ឋបាល ។ |

## ឧបសម្ព័ន្ធទី២ ៖ នីតិវិធីក្នុងការបង្កើតសហគមន៍ និងការរៀបចំលក្ខន្តិកៈ

- **<u>ការសិក្សាស្រាវជ្រាវអំពីអត្តសញ្ញាណ (ផ្អែកតាមមាត្រា២៣ និង២៤ នៃច្បាប់ភូមិបាល )</u>**

ប្រពៃណីវប្បធម៌ នៃការរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច (និយមន័យ និងអត្តសញ្ញាណ )

- រចនាសម្ព័ន្ធនៃការគ្រប់គ្រងជាប្រពៃណី
- ប្រពៃណី និងទំនៀមទំលាប់នៃការប្រើប្រាស់ដីធ្លីជាសមូហភាព
- ចំនួនគ្រួសារជាក់ស្តែងនៃជនជាតិមួយ និងជនជាតិផ្សេងទៀតដែលរស់នៅក្នុងសហគមន៍តែមួយដូចគ្នា
- លក្ខណៈវិនិច្ឆ័យកំណត់អំពីសមាជិករបស់សហគមន៍

- **<u>ការរៀបចំសេចក្តីព្រាងលក្ខន្តិកៈ (ពិនិត្យទម្រង់នៃវិធីសាស្ត្រ)</u>**

- ការស្វែងយល់អំពីការរៀបចំលក្ខន្តិកៈ
- ខ្លឹមសារនៃលក្ខន្តិកៈ និងគោលបំណង
- សមាសភាពគណៈកម្មាធិការ និងនីតិវិធីជ្រើសរើសគណៈកម្មាធិការ
- លក្ខខណ្ឌនៃការចូលជាសមាជិកសហគមន៍ និងការចេញពីសហគមន៍
- របៀបនៃការគ្រប់គ្រងសហគមន៍
- សិទ្ធិ និងការធ្វើសេចក្តីសំរេចរបស់សហគមន៍
- សិទ្ធិ និងសេចក្តីសំរេចរបស់ប្រធានគណៈកម្មាធិការ

- **<u>ការរៀបចំកិច្ចប្រជុំសហគមន៍ទាំងមូល ឬ សមាជសហគមន៍</u>**

- រៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍ និងគ្រួសារ (ពាក្យសុំចូល និងបញ្ជីឈ្មោះចូលជាសមាជិក ដោយគ្មានការបង្ខំ)
- ការត្រៀមរៀបចំកិច្ចប្រជុំ (ពិនិត្យ កែសំរួលលក្ខន្តិកៈចុងក្រោយ និងការជ្រើសរើសគណកម្មាធិការសហគមន៍របស់ខ្លួនដោយវិធីសាមញ្ញទៅតាមប្រពៃណី)
- រៀបចំការប្រជុំផ្លូវការ (អនុម័តលើលក្ខន្តិកៈនិងសមាសភាពគណៈកម្មាធិការសហគមន៍ ដោយមានការចូលរួមពីអាជ្ញាធររដ្ឋ-បាលដែលពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល)

- **<u>ការរៀបចំបែបបទស្នើសុំចុះបញ្ជីសហគមន៍តាមផ្លូវច្បាប់</u>**

- គំរូទម្រង់បែបបទ និងសេចក្តីជូនដំណឹងលេខ ៤៧៤ សជណ ចុះថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ១៩៩៤ របស់ក្រសួងមហាផ្ទៃ
- សហគមន៍ធ្វើលិខិតស្នើទៅក្រុមប្រឹក្សាឃុំដែលខ្លួនតាំងនៅ ដើម្បីឱ្យឃុំទទួលស្គាល់លក្ខន្តិកៈ និងគណៈកម្មាធិការសហគមន៍
- ភ្ជាប់ឯកសារដែលពាក់ព័ន្ធទៅជាមួយពេលចុះបញ្ជីសហគមន៍

- **<u>ការរៀបចំសំណុំឯកសារស្នើសុំចុះបញ្ជីសហគមន៍</u>**

- កំណត់ហេតុសង្ខេបនៃរបាយការណ៍ និងឯកសារពាក់ព័ន្ធទៅនឹងសមាជរបស់សហគមន៍
- ប្រវត្តិរូបរបស់ប្រធាន និងសមាជិកគណៈកម្មាធិការសហគមន៍ដែលមានបិទរូបថត ចំនួន៣ច្បាប់ (គំរូរបស់ក្រសួងមហាផ្ទៃ)
- អត្តសញ្ញាណប័ណ្ណថតចម្លងរបស់ប្រធាន និងសមាជិកគណៈកម្មាធិការសហគមន៍ ដោយមានការបញ្ជាក់អំពី នីត្យានុកូលកម្មពីសាលាខេត្តម្នាក់ៗ ចំនួន៣ច្បាប់
- បញ្ជីឈ្មោះសមាជិកនិងគ្រួសារសហគមន៍ ពាក្យសុំចូលជាសមាជិក លិខិតស្នើសុំចុះបញ្ជីសហគមន៍តាមរយៈឃុំ ស្រុក និងខេត្តទៅក្រសួងមហាផ្ទៃសម្រាប់ការទទួលស្គាល់ជាផ្លូវការ
- ការទទួលបានសេចក្តីជូនដំណឹង (សជណ) របស់ក្រសួងមហាផ្ទៃស្តីអំពីការអនុញ្ញាត្តិចុះញ្ជី និងការឱ្យធ្វើសកម្មភាព
- សហគមន៍ជនជាតិដើមភាគតិចត្រូវមានលក្ខន្តិកៈក្នុងភាពជានីតិបុគ្គល និងត្រូវមានបុគ្គលរូបវ័ន្តតំណាងឱ្យនីតិបុគ្គលរបស់ខ្លួនដែលបានការចុះញ្ជីសហគមន៍នៅក្រសួងមហាផ្ទៃ។

- **<u>គោលការណ៍បង្កើតសហគមន៍ជនជាតិដើមភាគតិច (លក្ខខណ្ឌសំខាន់ៗ នៃសេចក្តីព្រាងលក្ខន្តិកៈ)</u>**

- *<u>សេចក្តីផ្តើម ឬ សេចក្តីថ្លែងហេតុ</u>*

**ទិដ្ឋភាពទូទៅ ៖**

* ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវភាពឯករាជ្យនៃជាតិពន្ធុ សង្គមវប្បធម៌ និងសេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាត និងទំនៀមទំលាប់នៃការប្រើប្រាស់ជាសមូហភាព។
* ការរស់នៅរបស់ជនជាតិដើមភាគតិចភាគច្រើននៅភូមិភាគឥសាន្តដែលជាតំបន់ព្រៃភ្នំ ហើយជាតំបន់ជនបទដាច់ស្រាយាលនៃព្រះរាជាណាចក្រកម្ពុជា។
* ជាកសិករ និងដើរប្រមូលផលធនធានអនុផលព្រៃឈើសំរាប់ចិញ្ចឹមជីវិត។
* បច្ចុប្បន្ន ការកាប់បំផ្លាញព្រៃឈើខុសច្បាប់ និងការកាប់ព្រៃទន្រ្ទានយកដីខុសច្បាប់ មានទំហំធំគួរឱ្យចាប់អារម្មណ៍
* មានជនខិលខូចបំផុសទិញដីរបស់សមូហភាពជនជាតិដើមភាគតិច។
* បានធ្វើសកម្មភាពស៊ីឈ្នួលជនខិលខូចដោយកាប់ និងដុតព្រៃដើម្បីទន្រ្ទានយកដីខុសច្បាប់ក្រោមរូបភាពកាប់ចំការពនេចរតាមប្រពៃណីដោយអនាធិបតេយ្យ។
* ផលប៉ះពាល់ដល់តំបន់ព្រៃឧទ្យានជាតិ ដែលជាព្រៃអភិរក្សសំរាប់ជាជំរកសត្វព្រៃ ផលប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថាន និងសម្បត្តិសាធារណៈរបស់រដ្ឋ ពិសេសធ្វើឱ្យដីធ្លីរបស់សមូហភាពជនជាតិដើមភាគតិចមានការបាត់បង់អស់នាពេលអនាគត និងប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគាត់។

- *ក្របខ័ណ្ឌគោលនយោបាយ*

* ក្រុមប្រឹក្សាគោលនយោបាយដីរដ្ឋ បានរៀបចំគោលនយោបាយកំណែទំរង់ដីរដ្ឋ ប្រមូលផ្តុំជាសំខាន់លើវិធានការ ប្រព័ន្ធគ្រប់គ្រងបែងចែក និងការប្រើប្រាស់ដីដោយសមធម៌ ។
* ជំរុញការចុះបញ្ជីដីធ្លីជាប្រព័ន្ធ និងដាច់ដោយដុំ ពិសេសបានបង្កើតក្រុមការងារចំរុះថ្នាក់ជាតិសំរាប់ការចុះបញ្ជីដីធ្លីសមូហភាពដល់ជនជាតិដើមភាគតិច ។
* យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលស្តីអំពីការពង្រឹងអភិបាលកិច្ចមូលដ្ឋាន ដោយមានការចូលរួមពីប្រជាពលរដ្ឋ
* អនុវត្តតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ តាមរយៈការអភិវឌ្ឍន៍ជនបទដោយនិរន្តរភាព ។

- *ក្របខ័ណ្ឌច្បាប់*

* រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ មាត្រា៤២ ស្តីអំពីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងការបង្កើតសមាគម និងគណបក្សនយោបាយ
* ច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៣ ផ្នែកទី២ មាត្រា២៣ ដល់មាត្រា២៨ ស្តីអំពីសិទ្ធិប្រើប្រាស់ដីតាមប្រពៃណីរបស់ជនជាតិដើមភាគតិច ។ ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈរបស់សហគមន៍ ក្រុមដែលមានជាក់ស្តែងមកដល់បច្ចុប្បន្ននេះនឹងបន្តគ្រប់គ្រងសហគមន៍និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណី ហើយត្រូវអនុវត្តតាមបញ្ញត្តិនៃច្បាប់នេះ ។
* ច្បាប់ព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជា ជំពូក៩ មាត្រា៤០ ដល់ មាត្រា៤៦ ស្តីអំពីសិទ្ធប្រើប្រាស់ និងប្រមូលអនុផលព្រៃឈើតាមប្រពៃណីរបស់ជនជាតិដើមភាគតិច ។

- *វិធីសាស្ត្រទម្រង់ (អ្នកតាក់តែងត្រូវផ្តោតទៅលើខ្លឹមសារជាមូលដ្ឋាន៤)*

លំនាំដើម :

◊ ក្បាលលិខិត : ព្រះរាជាណាចក្រកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

◊ អំពីចំណងជើងនៃអត្ថបទ : ឈ្មោះលក្ខន្តិកៈ

* អំពីមូលបទ : ឯកសារយោង ជាឯកសារគតិយុត្តមានច្បាប់ដែលពាក់ព័ន្ធ
* អត្ថបទ ឬ ខ្លឹមសារ : តួសេចក្តី ជំពូក មាត្រា
* រូបមន្តបញ្ចប់ : អវសានបញ្ញត្តិ

- *ខ្លឹមសារអប្បបរិមាក្នុងការរៀបចំអត្ថបទ*

សហគមន៍ជនជាតិដើមភាគតិចនីមួយៗត្រូវរៀបចំលក្ខន្តិកៈ និងគោលការណ៍សំខាន់ៗសំរាប់ការគ្រប់គ្រង និងការចូល ឬ ចេញពីសមាជិកជាលាយលក្ខអក្សរដូចមានចំណុចសំខាន់ៗយ៉ាងតិចណាស់ដូចខាងក្រោម :

### ក- លក្ខន្តិកៈត្រូវមាន :

១- ឈ្មោះជាអក្សរពេញ និងទីស្នាក់ការ

២- ព្រំដែនសមត្ថកិច្ច និងក្របខណ្ឌច្បាប់

៣- គោលបំណង និងទិសដៅ

៤- វចនាសម្ព័ន្ធ សិទ្ធិ និងភារកិច្ច

៥- សមាសភាពគណៈកម្មាធិការសហគមន៍

៦- ការជ្រើសរើសគណៈកម្មាធិការសហគមន៍តំណាងសហគមន៍

៧- សិទ្ធិរបស់សហគមន៍ និងប្រធានសហគមន៍

៨- ការចូលជាសមាជិក ការបាត់បង់ និងការចូលរបស់សមាជិកថ្មី

៩- ការទទួល និងការបាត់បង់ពីមុខតំណែង

១០- ការប្រជុំ និងការបំពេញការងាររបស់តំណាងសហគមន៍

១១- ទ្រព្យសម្បត្តិសហគមន៍

១២- ការចាត់ចែងការងារ និងការទទួលខុសត្រូវ

១៣- ការធ្វើវិសោធនកម្មលក្ខន្តិកៈ

១៤- លក្ខខណ្ឌនៃការរំសាយសហគមន៍

### ខ- គោលការណ៍សំខាន់ៗ

១- ការគ្រប់គ្រងដីជាកម្មសិទ្ធិរបស់សហគមន៍

២- ការកំណត់លក្ខខណ្ឌ និងលក្ខណៈវិនិច្ឆ័យចូលជាសមាជិក ការចេញពីសមាជិកតាមប្រពៃណី ទំនៀមទំលាប់ និងការចេញពីសមាជិកសហគមន៍ដោយបង្ខំ

៣- ការកំណត់បទបញ្ជាផ្ទៃក្នុង

- *<u>លក្ខខណ្ឌសំខាន់ៗនៃសេចក្តីព្រាងគំរូលក្ខន្តិកៈ</u>*

* បុព្វកថា
* ៩ជំពូក ឬ លើស
* ២៣មាត្រា ឬ លើស
* ជំពូក១ អាចមាន៥មាត្រា ដែលមានខ្លឹមសារដូចខាងក្រោម : ឈ្មោះ ក្របខណ្ឌច្បាប់ ទីស្នាក់ការ និងក្របខណ្ឌគ្រប់គ្រង :

  ១- ឈ្មោះ

  ២- ក្របខណ្ឌច្បាប់

  ៣- និយមន័យ

  ៤- វិសាលភាព និងក្របខណ្ឌគ្រប់គ្រង

៥- ទីស្នាក់ការ

* ជំពូក២ អាចមាន១មាត្រា ដែលមានខ្លឹមសារបញ្ជាក់អំពី : គោលបំណង និងទិសដៅ
* ជំពូក៣ អាចមាន២មាត្រា ដែលមានខ្លឹមសារដូចខាងក្រោម : រចនាសម្ព័ន្ធ តួនាទី មុខងារ និងភារកិច្ច :

១- រចនាសម្ព័ន្ធ តួនាទី មុខងារ និងភារកិច្ចរបស់សហគមន៍

២- សមាសភាពគណៈកម្មាធិការសហគមន៍

៣- តួនាទី ភារកិច្ចរបស់គណៈកម្មាធិការសហគមន៍ និងអាជ្ញាធរប្រពៃណី

៤- តួនាទី ភារកិច្ចរបស់ប្រធានគណៈកម្មាធិការសហគមន៍

## រចនាសម្ព័ន្ធសហគមន៍



*សមាសភាពនៃគណៈកម្មាធិការសហគមន៍*

| | |
|---|---|
| *១- តំណាងចាស់ទុំភូមិ (មេកន្ទ្រាញ)* | *ជាប្រធាន* |
| *២- មេភូមិរដ្ឋបាល* | *ជាសមាជិកអចិន្ត្រៃយ៍* |
| *៣- ក្រុមចាស់ទុំភូមិ* | *ជាសមាជិក* |
| *៤- តំណាងស្ត្រីក្នុងភូមិ* | *ជាសមាជិក* |
| *៥- តំណាងក្រុមប្រឹក្សាឃុំ* | *ជាសមាជិក* |
| *៦- ប្រធាន ឬ តំណាងគណៈកម្មការរៀបចំផែនការប្រើប្រាស់ដីធ្លី* | *ជាសមាជិក* |

*៧- គណៈកម្មការផ្សេងៗទៀត*

* ជំពូក៤អាចមាន៤មាត្រា ដែលមានខ្លឹមសារបញ្ជាក់អំពីការចូលជាសមាជិក និងការបាត់បង់សមាជិកភាព :

១- សមាជិកភាព

២- ការបាត់បង់សមាជិកភាព

៣- ការចូលសមាជិកភាពថ្មី

៤- ការចូលជាសមាជិកថ្មី

*ការចូលជាសមាជិក ការបាត់បង់ និងការចូលជាសមាជិកថ្មី :*

- *ការកំណត់វិនិច្ឆ័យចូលជាសមាជិក*
- *ការកំណត់លក្ខណៈវិនិច្ឆ័យការចេញ ឬ ចូលជាសមាជិកតាមប្រពៃណី*
- *ការកំណត់លក្ខណៈវិនិច្ឆ័យការបាត់បង់ពីសមាជិកដោយបង្ខំ*

* ជំពូក៥ អាចមាន៣មាត្រា ដែលមានខ្លឹមសារទាក់ទងនឹងការទទួល និងការបាត់បង់ពីមុខតំណែង :

១- ការទទួលមុខតំណែង

២- ការបាត់បង់មុខតំណែង

៣- ការបំពេញមុខតំណែងដែលនៅទំនេរ

*ការទទួល និងការបាត់បង់ពីមុខតំណែង :*

- *នីតិវិធីជ្រើសតាំងអោយទទួលមុខតំណែង ធ្វើឡើងដោយវិធីសាមញ្ញ*
- *នីតិវិធីដកចេញពីមុខតំណែងតាមករណីណាមួយដូចជា : មរណៈភាព ដាក់ពាក្យជាលាយលក្ខអក្សរ បាត់បង់សម្បទាវិជ្ជាជីវៈ ជាប់ទោសពីបទឧក្រិដ្ឋ មិនគោរពលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ។*

* ជំពូក៦ អាចមាន២មាត្រា ដែលមានខ្លឹមសារទាក់ទងនឹង ការប្រជុំ និងការបំពេញការងារ :

១- ការរៀបចំសមាជសហគមន៍ប្រចាំឆ្នាំ

២- ការប្រជុំ និងការបំពេញការងាររបស់គណៈកម្មាធិការសហគមន៍

* ជំពូក៧ អាចមាន៤មាត្រា ដែលមានខ្លឹមសារទាក់ទងនឹង ប្រព័ន្ធហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សហគមន៍ (រៀបចំសរសេរដោយខ្មែរ) :

១- អចលនទ្រព្យរបស់សហគមន៍

២- ប្រភពចំណូលរបស់សហគមន៍

៣- ការបែងចែកដីសំរាប់ប្រើប្រាស់

៤- កិច្ចការគណនេយ្យ និងគណនេយ្យសហគមន៍

**ឧបសម្ព័ន្ធទី៧ : បទបញ្ញាផ្ទៃក្នុង**
**ការគ្រប់គ្រងដីធ្លីសម្បូហភាពសហគមន៍ជនជាតិដើមភាគតិចទំពួនភូមិឡាអ៊ិន ខេត្តរតនគីរី**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**សហគមន៍ជនជាតិដើមភាគតិចទំពួន**
**បទបញ្ញាផ្ទៃក្នុង**
**ស្តីពី**
**ការគ្រប់គ្រងដីជាសម្បូហភាពសហគមន៍ជនជាតិដើមភាគតិចទំពួន**
**ភូមិឡាអិន ឃុំតឺន ស្រុកកូនមុំ ខេត្តរតនគីរី**

## ជំពូកទី១
## បទបញ្ញត្តិទូទៅ

### ប្រការ១ :

បទបញ្ញាផ្ទៃក្នុងនេះ សំរាប់អនុវត្តលើរបៀបនៃការប្រើប្រាស់ និងគ្រប់គ្រងដីធ្លីសម្បូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចទំពួននៃភូមិឡាអិន ឃុំតឺន ស្រុកកូនមុំ ខេត្តរតនគីរី ស្របតាមប្រពៃណី ទំនៀមទំលាប់រស់នៅជាសម្បូហភាព ដូចមានចែងក្នុងប្រការ២ នៃលក្ខន្តិកៈ និងមាត្រា២៦ នៃច្បាប់ភូមិបាលឆ្នាំ២០០១។

### ប្រការ២ :

ការបង្កើតបទបញ្ញាផ្ទៃក្នុងនេះក្នុងគោលបំណងគ្រប់គ្រង និងប្រើប្រាស់ដីកម្មសិទ្ធិសម្បូហភាព និងអភិវឌ្ឍន៍សហគមន៍ ដោយសហគមន៍ មិនបង្កទំនាស់ផ្ទៃក្នុងសហគមន៍ដោយបានរក្សានូវអត្តសញ្ញាណ វប្បធម៌ ប្រពៃណី ទំនៀមទំលាប់ល្អ ក្នុងការប្រើប្រាស់ និងគ្រប់គ្រងដីធ្លី ព្រមទាំងធនធានធម្មជាតិដោយនិរន្តរភាព និងរួមចំណែកដល់ការអភិវឌ្ឍន៍សហគមន៍ និងសង្គមជាតិ។

### ប្រការ៣ :

ដីសម្បូហភាពរបស់សហគមន៍ រួមមាន ដីកប់ខ្មោច ដីព្រៃអារក្ស ដីចំការដំណាំយុទ្ធសាស្ត្រ ដីចំការវិលជុំ ដីលំនៅដ្ឋាន ដូចមានចែងក្នុងលក្ខន្តិកៈសហគមន៍ក្នុងប្រការ៣ នៃលក្ខន្តិកៈ។

## ឧបសម្ព័ន្ធ២

## គោលការណ៍នៃកម្មសិទ្ធិសមូហភាព

ប្រការ៤ :

សមាជិកសហគមន៍ជនជាតិដើមភាគតិចទំពួននៃភូមិឡាអិន គឺជាម្ចាស់កម្មសិទ្ធិលើចំណែកដីសមូហភាព ដែលពួកគេមានបុព្វសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើចំណែកដីសមូហភាព ដែលបុគ្គលជាសមាជិកចូលកាន់កាប់ស្របតាមប្រពៃណីរបស់សហគមន៍។ **(មានចែងក្នុងលក្ខន្តិកៈសហគមន៍)**

ប្រការ៥ :

បុគ្គលជាសមាជិកសហគមន៍ ដែលមានឈ្មោះក្នុងបញ្ជីសមាជិក ហើយទទួលស្គាល់ដោយគណៈកម្មាធិការសហគមន៍ និងមេឃុំតឺន មានសិទ្ធិស្របច្បាប់ក្នុងការបន្តបុព្វសិទ្ធិលើចំណែកដីសមូហភាពរបស់ខ្លួន មុននឹងលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងនេះចូលជាធរមាន។

ប្រការ៦ :

ការរំលោភដោយរូបវ័ន្តបុគ្គល ឬ នីតិបុគ្គលលើបុព្វសិទ្ធិនៃចំណែកដីសមូហភាពរបស់សមាជិកសហគមន៍ ត្រូវបានការពារសិទ្ធិតាមរយៈប័ណ្ណកម្មសិទ្ធិសមូហភាពនៅចំពោះមុខច្បាប់។ **(មានចែងក្នុងលក្ខន្តិកៈសហគមន៍)**

ប្រការ៧ :

ការរំលោភលើបុព្វសិទ្ធិនៃចំណែកដីសមូហភាពដោយសមាជិកសហគមន៍ណាម្នាក់ៗជាម្ចាស់ ត្រូវដោះស្រាយដោយគណៈកម្មា-ធិការសហគមន៍ ឬ អាជ្ញាធរប្រពៃណីរបស់សហគមន៍។ **(មានចែងក្នុងលក្ខន្តិកៈសហគមន៍)**

ប្រការ៨ :

កម្មសិទ្ធិសមូហភាពរបស់សហគមន៍មិនអាចធ្វើលទ្ធកម្ម ដោយលក់ ដូរ ធ្វើប្រទានកម្ម និងសន្និកម្មដល់រូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលមិនមែនជាសមាជិករបស់សហគមន៍បានទេ។ **(មានចែងក្នុងច្បាប់ភូមិបាល)**

ប្រការ៩ :

ប្រភេទក្បាលដីដែលប្រើប្រាស់ជាសាធារណៈនៅក្នុងសហគមន៍រួមមាន ព្រៃកប់ខ្មោច ព្រៃប្រមូលអនុផលព្រៃឈើ (ព្រៃ និងឫស្សី) ដីសាលារៀន និងដីព្រៃអារក្ស។ វាជាចំណែកមួយនៃកម្មសិទ្ធិសមូហភាពរបស់សហគមន៍ ដែលជាកម្មវត្ថុហាមប៉ះពាល់ជាដាច់ខាតសំរាប់គោលបំណងរានដីធ្វើចំការ សាងសង់លំនៅដ្ឋាន ការកាប់ឈើសំរាប់ធ្វើអាជីវកម្ម និងសកម្មភាពដែលធ្វើឱ្យរំខានដល់ប្រព័ន្ធជំនឿសាសនា។

ប្រការ១០ :

ព្រៃកប់ខ្មោច និងព្រៃអារក្ស គឺជាដីប្រើប្រាស់តាមទំនៀមទំលាប់ប្រពៃណី ដូចជាការបញ្ចុះសពនិងគោរពបូជា និងប្រមូលអនុ-ផលព្រៃឈើ។ **(យោងតាមច្បាប់ព្រៃឈើ និងសេចក្តីព្រាងគោលនយោបាយស្តីពីការចុះបញ្ជីដីសហគមន៍ ជនជាតិដើមភាគតិច)**

ប្រការ១១ :

សមាជិកសហគមន៍ពុំមានបុព្វសិទ្ធិលើប្រភេទក្បាលដីព្រៃកប់ខ្មោចនិងដីព្រៃអារក្សទេ ប៉ុន្តែពួកគេត្រូវចូលរួមការពារ ថែទាំ ប្រយោជន៍រួម ការចំណាយលើការគ្រប់គ្រង ការបង់ពន្ធ និងបន្ទុកផ្សេងៗទៀតទៅតាមការកំណត់របស់ច្បាប់។

***(សេចក្តីព្រាងគោលនយោបាយស្តីពីការចុះបញ្ជីដីសហគមន៍ ជនជាតិដើមភាគតិច)***

## ជំពូក៣

## លទ្ធកម្មនៃកម្មសិទ្ធិសមូហភាព

## ផ្នែកទី១ : ការផ្ទេរចំណែកដីនៃកម្មសិទ្ធិសមូហភាព

ប្រការ១២ :

ដីសមូហភាពរបស់សហគមន៍ អាចផ្ទេរជាកម្មសិទ្ធិឯកជនបាននូវចំណែកបុព្វសិទ្ធិរបស់សមាជិកសហគមន៍ណាម្នាក់ ដែលមានបំណងចាកចេញពីសហគមន៍ ដើម្បីទទួលបានជាកម្មសិទ្ធិឯកជន **(មាត្រា២៨ នៃច្បាប់ភូមិបាល)**។ ចំណែកដី ដែលកាត់ចេញពីដីសមូហភាព គឺជាចំណែកដី ឬ បុព្វសិទ្ធិដែលខ្លួនបានមកដោយការចូលរួមកាន់កាប់ដោយការដូរ ដោយសន្ទិកម្ម និងមិនមែនជាដីដែលបានមកដោយការផ្ទេរដោយការទិញ និងការផ្ទេរដោយប្រទានកម្មនៅក្នុងសហគមន៍។ ម្ចាស់បុព្វសិទ្ធិ ដែលបានចាកចេញមានកាតព្វកិច្ចចេញសោហ៊ុយក្នុងការរៀបចំកាត់ឈ្មោះ និងធ្វើប័ណ្ណកម្មសិទ្ធិឯកជនដោយខ្លួនឯងផ្ទាល់។ **(មានចែងក្នុងលក្ខន្តិកៈសហគមន៍ និងច្បាប់ភូមិបាល)**

ប្រការ១៣ :

ដីសមូហភាពសហគមន៍អាចធ្វើលទ្ធកម្មកម្មសិទ្ធិបាន ប្រសិនបើសមាជិកសហគមន៍ទាំងអស់បានឯកភាពព្រមព្រៀងគ្នាមួយរយភាគរយ តាមនីតិវិធីច្បាប់សំរាប់ធ្វើលទ្ធកម្មកម្មសិទ្ធិសមូហភាពដល់រូបវ័ន្ត ឬ នីតិបុគ្គលដែលមិនមែនជាសមាជិកសហគមន៍។ ទោះជាក្នុងករណីណាក៏ដោយ ការធ្វើលទ្ធកម្មនេះមិនអាចធ្វើចំពោះក្បាលដីកប់ខ្មោច និងព្រៃអារក្សបានទេ។ **(មានចែងក្នុងច្បាប់ភូមិ-បាល មាត្រា ២៦ អាចផ្ទុយពីប្រការខាងលើ)**

ប្រការ១៤ :

កម្មសិទ្ធិសមូហភាព អាចកាត់ចេញនូវចំណែកដីណាមួយសំរាប់គោលបំណងបំរើផលប្រយោជន៍សាធារណៈរបស់រដ្ឋ ដោយអនុវត្តន៍តាមនីតិវិធី និងទំរង់ការច្បាស់លាស់។ ម្ចាស់បុព្វសិទ្ធិ និងសមាជិកសហគមន៍ក្នុងសហគមន៍ជាម្ចាស់កម្មសិទ្ធិសមូហភាព មានសិទ្ធិទទួលបាននូវសំណងសមស្របពីការបាត់បង់ស្របតាមយន្តការបែងចែកសំណង ដែលបានទទួលពីសហគមន៍។ **(មានចែងក្នុងច្បាប់ភូមិបាល)**

## ផ្នែកទី២ : ការផ្ទេរ ឬ លទ្ធកម្មនៃបុព្វសិទ្ធិ

ប្រការ១៥ :

បុព្វសិទ្ធិនៃដីសមូហភាពភូមិឡាអិន ជាកម្មសិទ្ធិប្រើប្រាស់និងអាស្រ័យផលផ្ដាច់មុខរបស់សមាជិកសហគមន៍របស់ភូមិ ឡាអិន លើចំណែកដីនៃកម្មសិទ្ធិសមូហភាព។ ការផ្ទេរបុព្វសិទ្ធិ គឺជាដំណើរការផ្លាស់សិទ្ធិនៃម្ចាស់បុព្វសិទ្ធិផ្ទៃក្នុងកម្មសិទ្ធិសមូហភាព ដោយមានការដឹងឮ និងយល់ព្រមដោយសហគមន៍។ (**មាត្រា ១០ នៃច្បាប់ភូមិបាល**)

សហគមន៍ជនជាតិដើមភាគតិចទំពួននៃភូមិឡាអិន អាចអនុវត្តការផ្ទេរបុព្វសិទ្ធិដីសមាជិកសហគមន៍ ដែលបានកាន់កាប់នៅក្នុងសហគមន៍។ ការផ្ទេរបុព្វសិទ្ធិដីរបស់សហគមន៍ រួមមាន ការផ្ទេរដោយការដូរវវាងបុព្វសិទ្ធិនិងបុព្វសិទ្ធិ ការផ្ទេរដោយសន្តិកម្ម និងការផ្ទេរដោយប្រទានកម្ម។ ការផ្ទេរទាំងនេះ ត្រូវអនុលោមទៅតាមយន្តការនៃការសំរេច និងយល់ព្រមដោយគណៈកម្មាធិការសហគមន៍ និងបំពេញទៅតាមទម្រង់លិខិតយថាភូតរបស់សហគមន៍ (ឧបសម្ព័ន្ធ)។

## ផ្នែកទី៣ : ការផ្ទេរដោយការដូរដី

ប្រការ១៦ :

បុគ្គលជាសមាជិកដែលមានបុព្វសិទ្ធិលើដីសហគមន៍ អាចដោះដូរដីជាមួយសមាជិកផ្សេងទៀតទៅតាមការព្រមព្រៀងដូរដី និងដីទៅវិញទៅមក។ ការដូរដីត្រូវមានការដឹងឮ និងយល់ព្រមពីសហគមន៍។ (**បុព្វសិទ្ធិនៃចំណែកដីសហគមន៍ មិនអាចដោះដូរគ្នាជា-មួយសំភារៈបានឡើយ**)។

## ផ្នែកទី៤ : ការផ្ទេរដោយសន្តិកម្ម និងការស្នងមរតកដីធ្លី

ប្រការ១៧ :

បុគ្គលជាសមាជិកដែលមានបុព្វសិទ្ធិលើដីសហគមន៍ អាចផ្ទេរដីរបស់ខ្លួនតាមរយៈការស្នងមរតកដីដោយមានបណ្ដាំ ឬ គ្មានបណ្ដាំ (អំណោយដីកេរ្តិ៍) តាមលក្ខណៈដូចខាងក្រោម :

- ដីដែលអ្នកស្លាប់បានកាន់កាប់ និងដឹងឮដោយសមាជិកជិតខាងក្នុងសហគមន៍
- ដីដែលអ្នកស្លាប់បានទទួលអំណោយពីសមាជិកក្នុងសហគមន៍
- ដីដែលអ្នកស្លាប់មានសិទ្ធិប្រើប្រាស់ និងអាស្រ័យផល និងដីដែលបានដាក់បញ្ចាំសំរាប់ការធានាបំណុល

ប្រការ១៨ :

ការស្នងមរតកដីរបស់សមាជិកសហគមន៍ទៅសមាជិកដទៃទៀត ត្រូវមានការដឹងឮពីសមាជិកភាគច្រើននៃវង្សត្រកូល និង គណៈកម្មាធិការសហគមន៍ ឬលិខិតបណ្ដាំមានស្នាមមេដៃ។

ប្រការ១៩ :

ដីមរតកជាលំនៅដ្ឋានរបស់គ្រួសារអ្នកស្លាប់ ឬដីប្រើប្រាស់សំរាប់ផ្គត់ផ្គង់ជីវភាពដោយផ្ទាល់ អ្នកស្នងមរតកមិនអាចស្នើសុំបែងចែក ឬ សំរេចដីនោះបានទេ លើកលែងតែមានការយល់ព្រមពីក្រុមអ្នកទទួលស្នងមរតកទាំងអស់។ ក្នុងករណីមានការជំទាស់ពីការបែងចែកដីមរតក សមាជិកនៃក្រុមអ្នកស្នងមរតកត្រូវប្តឹងទៅគណៈកម្មាធិការសហគមន៍ ដើម្បីដោះស្រាយទៅតាមប្រពៃណី។

ការដូរ ឬ ការធ្វើអំណោយនូវចំណែកសិទ្ធិរបស់អ្នកទទួលស្នងមរតកណាម្នាក់ ត្រូវចាត់ទុកមិនបានការ ប្រសិនបើការលក់ ការដូរ ឬ ធ្វើអំណោយនោះពុំមានការយល់ព្រមពីសមាជិកដទៃទៀតនៃក្រុមអ្នកទទួលស្នងមរតក។ រាល់ការបំពារបំពាន ត្រូវទទួលការផាកពិន័យទៅតាមប្រពៃណីរបស់សហគមន៍។

ប្រការ២០ :

ដីរបស់អ្នកស្លាប់ ដែលមិនបានប្រគល់ស្នងមរតកដល់សមាជិកណាម្នាក់ក្នុងសហគមន៍ជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកជាដីរបស់សហគមន៍ ហើយជាកម្មវត្ថុនៃការបែងចែករបស់សហគមន៍ដល់អ្នកដែលគ្មានដី។ ទង្វើនេះ ត្រូវធ្វើឡើងតាមរយៈ ការប្រជុំពេញអង្គរបស់សហគមន៍។ ចំពោះដីរបស់អ្នកស្លាប់ដែលគ្មានអ្នកស្នងមរតក ត្រូវចាត់ទុកដីនោះជាដីរបស់សហគមន៍ ហើយវាជាកម្មវត្ថុនៃការបែងចែករបស់សហគមន៍ដល់អ្នកគ្មានដី។ ទង្វើនេះត្រូវធ្វើឡើងទៅតាមរយៈការប្រជុំពេញអង្គរបស់ សហគមន៍។

## ផ្នែកទី៩ : ការផ្ទេរដោយប្រទានកម្ម (ការឱ្យ)

ប្រការ២១ :

ការធ្វើអំណោយដីរបស់ម្ចាស់បុព្វសិទ្ធិជាសមាជិកសហគមន៍ ត្រូវធ្វើឡើងដោយមានការដឹងឮពីសមាជិកភាគច្រើននៃវង្សត្រកូលរបស់ខ្លួន ឬ លិខិតផ្ទេរសិទ្ធិដែលមានការដឹងឮ និងយល់ព្រមពីគណៈកម្មាធិការសហគមន៍។

## ជំពូក៤
## សិទ្ធិ និងភារកិច្ចនៃកម្មសិទ្ធិសមូហភាព
## ផ្នែកទី១ : ការអាស្រ័យផលនៃបុព្វសិទ្ធិ

ប្រការ២២ :

ម្ចាស់បុព្វសិទ្ធិនៃដី មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងដីរបស់ខ្លួនតែជាមួយសមាជិកនៅក្នុងសហគមន៍តែប៉ុណ្ណោះ ហើយដែលមិនផ្ទុយពីអ្វីដែលច្បាប់ហាមឃាត់។ ការល្មើសនៃម្ចាស់បុព្វសិទ្ធិទៅនឹងច្បាប់ហាមឃាត់ គឺជាការទទួលខុសត្រូវរបស់ម្ចាស់បុព្វសិទ្ធិនោះ មិនមែនជាការទទួលខុសត្រូវរបស់សហគមន៍ទេ។

ប្រការ ២៣ :

ម្ចាស់បុព្វសិទ្ធិនៃដីមិនអាចប្រើប្រាស់ដីរបស់ខ្លួនដើម្បីព្យាបាទ ឬធ្វើឱ្យរំខានដល់អ្នកជិតខាងក្នុងសហគមន៍បានទេ។ ការដាំដំណាំធម្មតាតាមប្រពៃណីមិនចាត់ទុកជាការរំខានដល់អ្នកជិតខាងឡើយ។

ប្រការ២៤ :

ម្ចាស់បុព្វសិទ្ធិនៃដីអាចប្រើប្រាស់ដីសម្រាប់រាល់ការដាំដុះ ការកែប្រែ ការរៀបចំ និងការសាងសង់តាមបំណងរបស់ខ្លួនដោយស្របតាមប្រពៃណី និងលក្ខខណ្ឌច្បាប់ ។

ប្រការ២៥ :

ម្ចាស់បុព្វសិទ្ធិនៃដី ជាម្ចាស់នៃផ្នែកក្រោមដី និងវត្ថុអចិន្ត្រៃយ៍ដែលស្ថិតនៅពីលើដី ។ ម្ចាស់បុព្វសិទ្ធិអាចកាប់មែកឈើ ឬបេះផ្លែឈើអ្នកជិតខាងដែលលយចូលក្នុងដីរបស់ខ្លួន ។

ប្រការ២៦ :

ម្ចាស់បុព្វសិទ្ធិនៃដីអាចធ្វើកិច្ចសន្យាដាក់ធានាសងបំណុលជាមួយសមាជិកក្នុងសហគមន៍ដោយការដាក់បញ្ចាំ ឬ ការដាក់ធានាតាមលក្ខខណ្ឌប្រពៃណីដោយមានការដឹងឮពីគណៈកម្មាធិការសហគមន៍ ។

## ផ្នែកទី២ : ឧបាគមន៍ផលិតផល និងផលទុននៃបុព្វសិទ្ធិ

ប្រការ២៧ :

ម្ចាស់បុព្វសិទ្ធិនៃដី មានសិទ្ធិទទួលផលគ្រប់បែបយ៉ាងនៅលើដីរបស់ខ្លួន ទាំងផលដែលកើតពីធម្មជាតិ និងផលដែលកើតពីការដាំដុះ ។

## ផ្នែកទី៣ : ការកើនឡើងនៃបុព្វសិទ្ធិ

## ក- ការកើនឡើងដោយអំពើរបស់ម្ចាស់បុព្វសិទ្ធិ

ប្រការ២៨ :

សំណង់ ដំណាំ និងការងារទាំងឡាយដែលបានធ្វើនៅលើនិងក្រោមដី ត្រូវចាត់ទុកថាបានធ្វើដោយម្ចាស់បុព្វសិទ្ធិ លើកលែងតែមានភស្តុតាងផ្ទុយពីនេះ ។

ប្រការ២៩ :

កាលបើដំណាំ សំណង់ និងការរៀបចំទាំងឡាយរបស់ម្ចាស់បុព្វសិទ្ធិត្រូវបានធ្វើឱ្យខូចខាតដោយសមាជិកដទៃទៀត នោះជនល្មើសត្រូវចេញថ្លៃសោហ៊ុយលើការខូចខាត ដើម្បីបង់សងទៅម្ចាស់បុព្វសិទ្ធិទៅតាមទំហំនៃការខូចខាត ។

## ខ- ការកើនឡើងនៃបុព្វសិទ្ធិដោយធម្មជាតិ

ប្រការ៣០ :

ផលដំណាំដែលកើនឡើងដោយធម្មជាតិក្នុងចំណែកដីនៃម្ចាស់បុព្វសិទ្ធិ គឺជាការកើនឡើងនៃកម្មសិទ្ធិសមូហភាព ដែលសមាជិកក្នុងសហគមន៍អាចប្រមូលផលបាន ។ ការចូលប្រមូលផលត្រូវជូនដំណឹងដល់ម្ចាស់បុព្វសិទ្ធិជាមុនសិន ។ **(អាច ផ្ទុយពីប្រការខាងលើ)**

ប្រការ៣១ :

សមាជិកសហគមន៍ទាំងអស់មានសិទ្ធិប្រើប្រាស់ និងអាស្រ័យផលលើផលធម្មជាតិដែលបានកើតឡើងក្នុងដីព្រៃកប់ខ្មោច ដីសាលារៀន ព្រៃប្រមូលអនុផលព្រៃឈើ និងព្រៃអារក្សស្របតាមប្រពៃណី។ ប្រសិនបើការប្រើប្រាស់ និងអាស្រ័យផលលើដីព្រៃកប់ខ្មោចនិងព្រៃអារក្សបានធ្វើឱ្យប៉ះពាល់ដល់ប្រពៃណី បុគ្គលនោះត្រូវទទួលខុសត្រូវចំពោះមុខអាជ្ញាធរប្រពៃណី។

## ផ្នែកទី៨ : ការជួលបុព្វសិទ្ធិ

ប្រការ៣២ :

ម្ចាស់បុព្វសិទ្ធិអាចជួលដីរបស់ខ្លួនទៅឱ្យសមាជិកដទៃទៀតក្នុងសហគមន៍ និងក្រៅសហគមន៍បាន។ ការជួលត្រូវធ្វើឡើងដោយមានការកំណត់ពេល និងមានលិខិតបញ្ជាក់ពីគណៈកម្មាធិការសហគមន៍។ កិច្ចសន្យានេះធ្វើឡើងដោយផ្ទាល់មាត់ ត្រូវចាត់ទុកជាបណ្ដោះអាសន្ន ហើយអាចត្រូវបញ្ឈប់គ្រប់ពេលដោយជូនដំណឹងជាមុន។

## ផ្នែកទី៩ : សេវភាព

ប្រការ៣៣ :

ម្ចាស់បុព្វសិទ្ធិជាសមាជិកសហគមន៍ ត្រូវបន្តឱ្យមានសេវភាពតាមប្រពៃណី ដើម្បីធានាការបំរើដល់ម្ចាស់នៃបុព្វសិទ្ធិជាសមាជិកសហគមន៍ផ្សេងទៀតក្នុងនោះរួមមាន ដីបំរើ (ផ្លូវដើរ) ផ្លូវទឹកហូរ។

## ជំពូក៥

## ការដោះស្រាយវិវាទ

ប្រការ៣៤ :

រាល់វិវាទ ឬទំនាស់ដែលកើតមានឡើងនៅក្នុងសហគមន៍ ត្រូវដោះស្រាយតាមរយៈការផ្សះផ្សា ឬសម្រុះសម្រួលដោយចាស់ទុំគណៈកម្មាធិការសហគមន៍តាមបែបប្រពៃណី និងតាមផ្លូវច្បាប់។

វិវាទទាំងឡាយដែលដោះស្រាយដោយគណៈកម្មាធិការសហគមន៍មិនបានសំរេច គឺត្រូវបញ្ជូនវិវាទនោះទៅអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ។

ប្រការ៣៥ :

ប្រភេទវិវាទ ឬទំនាស់ដែលដោះស្រាយដោយគណៈកម្មាធិការសហគមន៍មានដូចជា ដីធ្លី ជម្លោះគ្រួសារ ការប្រព្រឹត្តិខុសប្រពៃណីទំនៀមទំលាប់ ការលែងលះ និងវិវាទរដ្ឋប្បវេណីតូចតាច។

ប្រការ៣៦ :

វិវាទ ឬ ទំនាស់ដែលជាបទល្មើសធ្ងន់ធ្ងរ គឺត្រូវដោះស្រាយតាមរយៈប្រព័ន្ធច្បាប់ជាតិ (ប្រព័ន្ធតុលាការ) ហើយវាមិនមែនជាសមត្ថកិច្ចដោះស្រាយរបស់គណៈកម្មាធិការសហគមន៍ឡើយ។

## ជំពូក៦
## ការកែប្រែបទបញ្ជាផ្ទៃក្នុង

ប្រការ៣៧ :

ការកែប្រែបទបញ្ជាផ្ទៃក្នុងនេះ ត្រូវធ្វើឡើងទៅតាមសំណើររបស់គណៈកម្មាធិការសហគមន៍ ឬ សមាជិកសហគមន៍ភូមិឡាអិនដែលមានសម្លេងយ៉ាងតិច ៥០បូក១។

ប្រការ៣៨ :

បទបញ្ជាផ្ទៃក្នុងនេះ នឹងត្រូវអនុវត្តចាប់ពីថ្ងៃដែលសមាជិកសហគមន៍ភូមិឡាអិនបានអនុម័ត។

ភូមិឡាអិន, ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៧

ស្នាមមេដៃប្រធានសហគមន៍

ង៉ែន ភេន

**លេខ : ២១៥/០៧**

**បានឃើញ និងទទួលតំកល់នៅសាលាឃុំតឺន**

**សាលាឃុំតឺន,ថ្ងៃទី១៥ មីនា ឆ្នាំ២០០៧**

**មេឃុំ**

**ចាម៉ៅ ផាង**

## ឧបសម្ព័ន្ធទី៤ ៖ បញ្ជីឯកសារច្បាប់នានា ដែលពាក់ព័ន្ធនឹងការចុះបញ្ជីដីធ្លីសមូហភាព ជនជាតិដើមភាគតិច

- សារាចរណែនាំលេខ ០៩៧៤កអជ/២២.៧.២០០៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទស្តីពី នីតិវិធីនិងវិធីសាស្ត្រសំរាប់អនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍន៍ និងការកំណត់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច
- អនុក្រឹត្យលេខ ៨៣អនក្រ.បក/៩.០៦/២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពី នីតិវិធីនៃការចុះបញ្ជីដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច
- គោលនយោបាយស្តីពី ការចុះបញ្ជីដីធ្លី និងសិទ្ធិប្រើប្រាស់ដីធ្លីសមូហភាពសហគមន៍ជនជាតិដើមភាគតិច អនុម័តកាលពីថ្ងៃទី២៤ មេសា ២០០៩ ដោយទីស្តីការគណៈរដ្ឋមន្ត្រី
- គោលនយោបាយជាតិស្តីពី ការអភិវឌ្ឍន៍ជនជាតិដើមភាគតិចរបស់រាជរដ្ឋាភិបាលកម្ពុជា អនុម័តកាលពីថ្ងៃ ទី២៤ មេសា ២០០៩ ដោយទីស្តីការគណៈរដ្ឋមន្ត្រី
- អនុក្រឹត្យលេខ ១១៨អនក្រ/បក/៧.១០.២០០៥ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការគ្រប់គ្រងដីរដ្ឋ
- ប្រកាសលេខ ១៣៦បក/កអជ/១១.០៩.២០០២ ស្តីពីតួនាទី ការទទួលខុសត្រូវ និងការដំណើរការនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិដើមភាគតិច
- ប្រកាសលេខ ១៩៥០បក/០៧.៥.២០០២ របស់ក្រសួងមហាផ្ទៃស្តីពីតួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
- អនុក្រឹត្យលេខ ៤៦អនក្រ/បក/៣១.០៥.២០០២ ស្តីពី នីតិវិធីនៃការបង្កើតផែនទី និងការចុះបញ្ជីដីធ្លី
- អនុក្រឹត្យលេខ ៤៨អនក្រ/បក/៣១.០៥.២០០២ ស្តីពីការចុះបញ្ជីដីធ្លី
- អនុក្រឹត្យលេខ ៥១អនក្រ/បក/២១.៦.២០០១ ស្តីពីការផ្តល់សច្ចាប័នលើអនុក្រឹត្យលេខ ៧៨អនក្រ.បក/០១.១២.១៩៩៧ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃក្រសួងអភិវឌ្ឍន៍ជនបទ
- ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤/.៣០.៨.២០០១ ស្តីពីច្បាប់ដីធ្លី
- អនុក្រឹត្យលេខ ៨៨អនក្រ/បក/០១.១២.២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាសំរាប់គោលនយោបាយដីធ្លី
- ប្រកាសលេខ ០៩៥បក/០៧.៥.១៩៩៤ របស់ក្រសួងមហាផ្ទៃស្តីពីតួនាទី ការទទួលខុសត្រូវ និងរចនាសម្ព័ន្ធនៃក្រសួងមហាផ្ទៃ

- លិខិតលេខ ៤៧៤/០៧.៧.១៩៩៤ របស់ក្រសួងមហាផ្ទៃដែលបានជូនដំណឹងអំពីការចុះបញ្ជីជាមួយនឹងទំរង់បែបបទ
- អនុក្រឹត្យលេខ ៧២អនក្រ/បក/១២.៥.២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ-សង្កាត់
- ក្រឹត្យច្បាប់លេខ/១០០ក/១៣ តុលា ១៩៩២ ស្តីពីច្បាប់ភូមិបាលឆ្នាំ១៩៩២

**ការិយាល័យ ឌីភីអេ កម្ពុជា**

ផ្ទះលេខ 69 z, ផ្លូវលេខ 450, ទួលទំពូង II, ភ្នំពេញ, កម្ពុជា

ប្រអប់សំបុត្រលេខ 5, ភ្នំពេញ, កម្ពុជា

ទូរស័ព្ទ : (855) 23-216 369/216 945

អ៊ីមែល : dpa.reception@dpacam.org

គេហទំព័រ : www.dpacam.org



**គាំទ្រដោយ : អង្គការ ត្រូឃែរ**